សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université royale de droit et des sciences économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក យស់ សីលា**

**កញ្ញា យឹម ស្រីភា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ពៅ សារឿន**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **យស់ សីលា** និង **យឹម ស្រីភា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ក្រុមP4C2 នៃ**សកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ឆ្នាំសិក្សា២០២០-២០២៤។

យើងខ្ញុំទាំងពីរនាក់សូមធ្វើការថ្លែងអំណរគុណ និងសម្តែងថ្លែងអំណរគុណចំពោះ៖

- លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកជាអ្នកមានគុណយ៉ាងធំធេងក្រៃលែង ចំពោះកូនដែលមានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះថាលោកទាំងពីរជាអ្នកដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបកូនៗតាំងពីថ្ងៃដែលកូនបានចាប់កំណើតនៅក្នុងផ្ទៃ រហូតមកដល់ពេលកូនកើត និងរហូតមកដល់កូនធំដឹងក្តីបន្តិចឡើង លោកទាំងពីរបានអប់រំទូន្មាន ណែនាំ ប្រៀនប្រដៅ ដាស់តឿនកូនឱ្យក្លាយជាកូនល្អប្រព្រឹត្តិតែអំពើល្អ សេពគប់មិត្តល្អជាដើម លើសពីនេះទៅទៀតលោកទាំងពីរបានខិតខំធ្វើការហាលក្តៅហាលភ្លៀងថ្ងៃរងារត្រជាក់សព្វគ្រប់បែបយ៉ាង ដើម្បីបានថវិកាមកទំនុកបម្រុងការសិក្សារៀនសូត្ររបស់កូន ព្រមទាំងផ្តល់ក្តីស្រលាញ់ការ ថ្នាក់ថ្នម ភាពកក់ក្តៅ និងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរដល់កូនៗទាំងអស់គ្នា ទាំងនេះគឺជាមហាគុណបំណាច់ដ៏ធំធេងដែលកូនពុំអាចបំភ្លេចបានបានឡើយក្នុងមួយឆាកជីវិតរបស់កូន។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូអ្នកគ្រូសាស្រ្តាចារ្យគ្រប់រូបនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ដោយមានទំនួលខុសត្រូវយ៉ាងខ្ពស់ចំពោះការសិក្សារបស់និស្សិតទាំងអស់ដោយលោកពុំគិតពីបញ្ហាលំបាកនឿយហត់អ្វីមួយឡើយ។ លោកគ្រូអ្នកគ្រូសាស្រ្តាចារ្យគ្រប់រូបក៏តែងតែខិតខំប្រឹងប្រែងក្នុងការសិក្សាស្រាវជ្រាវរិះរកបកគំហើយថ្មីៗបន្ថែមដើម្បីផ្ទេរនូវពុទ្ធិ និងបទពិសោធន៍ល្អៗដល់សិស្សនិស្សិតគ្រប់គ្នាផងដែរ។
- ជាពិសេសខ្ញុំថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្រ្តាចារ្យ **ពៅ សារឿន** ដែលជាសាស្រ្តាចារ្យណែនាំរបស់យើងខ្ញុំទាំងពីរនាក់ ដែលតែងតែផ្តល់នូវគ្រឹះការអនុវត្តក្នុងការសិក្សាស្វែងយល់ពីរបៀបក្នុងការធ្វើសារណារបស់យើងខ្ញុំ សាស្រ្តាចារ្យថែមទាំងព្យាយាមពន្យល់ណែនាំ និងប្រាប់នូវបទពិសោធន៍ល្អៗ ព្រមទាំងវិធីសាស្រ្តផ្សេងៗដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនេះផងដែរ។

# អារម្ភកថា

ការបំពុលបរិស្ថាន គឺជាបញ្ហាមួយដ៏សំខាន់របស់ប្រទេសទូទាំងសកលលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដែលក្នុងនោះមានប្រទេសកម្ពុជាផងដែរ។ ចំពោះការកើនឡើងសំណង់អគារ រោងចក្រ សហគ្រាស និងគម្រោងអភិវឌ្ឍន៍នានាក៏មានការរីកដុះដាលជាលំដាប់។ ការកើនឡើងបែបនេះហើយ វាបានធ្វើឱ្យមានការប៉ះពាល់ទៅដល់បរិស្ថានរបស់កម្ពុជាជាក់ជាមិនខាន ប្រសិនបើមិនមានការទប់ស្កាត់ និងពិនិត្យឱ្យបានម៉ត់ចត់ទៅលើគម្រោងប៉ះពាល់ទាំងនោះទេ។ ឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះទើបក្រសួងបរិស្ថានបាននឹងកំពុងធ្វើការងារយ៉ាងសកម្មទៅលើបញ្ហាប៉ះពាល់ទាំងនេះតាមរយៈ **នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**។

ក្នុងនាមជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានជ្រើសរើសជំនាញផ្នែក **រដ្ឋបាលសាធារណៈ** បានរៀបចំនូវសារណាបញ្ចប់ការសិក្សាបរិញ្ញាបត្រក្រោមប្រធានបទស្តីពី "**កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**"។ ការរើសយកនូវប្រធានបទមួយនេះឡើងគឺមានការគាំទ្រ និងមានការជួយជម្រុញទឹកចិត្ត ពន្យល់ណែនាំ និងកែតម្រូវយ៉ាងពេញទំហឹងពីសំណាក់លោកសាស្ត្រាចារ្យ **ពៅ សារឿន** ដែលជាសាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឆន្ទៈនៅក្នុងការចងក្រងសារណាមួយនេះនឹងចូលរួមវិភាគទានដ៏សំខាន់នូវក្នុងការផ្តល់ជាចំណេះដឹង និងបកស្រាយចម្ងល់ទៅដល់មិត្តអ្នកអាន និស្សិត ក៏ដូចជាទុកជាឯកសារសម្រាប់សិស្សប្អូនជំនាន់ក្រោយបានសិក្សាស្វែងយល់បន្ថែមឱ្យកាន់តែស៊ីជម្រៅអំពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ យើងខ្ញុំសូមខន្តីអភ័យទោស រាល់កំហុសខុសឆ្គងដោយអចេតនាទាំងឡាយក្នុងការប្រើប្រាស់វាក្យស័ព្ទ និងបច្ចេកទេសនៃការរៀបចំឡើងនូវសារណាមួយនេះ យើងខ្ញុំរីករាយជានិច្ចរាល់មតិរិះគន់ទាំងឡាយមកកាន់យើងខ្ញុំក្នុងនៃកែលម្អ ជាពិសេសការស្តាបនាពីសាស្ត្រាចារ្យដើម្បីឱ្យសារណាមួយនេះកាន់តែមានភាពសុក្រឹត្យ និងបែបវិទ្យាសាស្ត្រ ។

យើងខ្ញុំសូមថ្លែងអំណរគុណមិត្តអ្នកអានទាំងអស់ ដែលបានចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃនូវក្នុងការអាននូវឯកសារមួយនេះ និងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់សាស្ត្រាចារ្យដែលបានលះបង់ពេលវេលា និងកម្លាំងកាយចិត្តក្នុងការស្វះស្វែងបង្ហាត់បង្ហាញយ៉ាងយកចិត្តទុកដាក់ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំសូមធ្វើការជូនពរទៅដល់សាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិតអ្នកអានគ្រប់រូបសូមឱ្យជួបប្រទះតែសំណាងល្អ ភាពសុដុមរមនា រុងរឿងចុំច្រើន និងមានសុភមង្គលកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីថ្លែងអំណរគុណ**........................................................................................

**អារម្ភកថា**........................................................................................

**មាតិកា** ........................................................................................i

**បញ្ជីអក្សរកាត់**........................................................................................iv

**បញ្ជីតារាង**........................................................................................v

**សេចក្តីផ្តើម**........................................................................................១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................................................១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................................................................២

៣. គោលបំណងនៃការស្រាវជ្រាវ ........................................................................................២

៤. ដែនកំណត់នៃការស្រាវជ្រាវ ........................................................................................២

៥. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................២

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ........................................................................................ ៣

៦.១ វិធីសាស្រ្តប្រមូលទិន្នន័យ ........................................................................................ ៣

៦.២ វិធីសាស្រ្តវិភាគទិន្នន័យ........................................................................................ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................................៤

## ជំពូកទី១

## លក្ខណៈទូទៅស្តីអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១.១ គោលបំណង ........................................................................................៥

១.២ អ្វីទៅជាបរិស្ថាន ........................................................................................៥

១.២.១ និយមន័យបរិស្ថាន........................................................................................៥

១.២.២ ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ........................................................................................៦

១.២.៣ បញ្ហាបរិស្ថាននៅជុំវិញពិភពលោក........................................................................................៦

១.៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)........................................................................................ ៧

១.៣.១ និយមន័យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ........................................................................................៩

១.៣.២ ដើមកំណើតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន........................................................................................ ១០

១.៣.៣ គោលការណ៍សំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ១០
១.៤ ក្របខណ្ឌច្បាប់ ...... ១១

## ជំពូកទី២
## ស្ថានភាពទូទៅនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

២.១ បទបញ្ញត្តិផ្សេងៗទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ១២
២.២ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ១៤
២.២.១ ប្រវត្តិនៃការបង្កើតក្រសួង ...... ១៤
២.២.២ ចក្ខុវិស័យ និងបេសកកម្ម ...... ១៤
២.២.៣ រចនាសម្ព័ន្ធក្រសួង ...... ១៦
២.២.៤ បុព្វហេតុនៃការបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ១៩
២.២.៥ រចនាសម្ព័ន្ធនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ២០
២.២.៦ តួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ២១
២.៣ ផលប៉ះពាល់បរិស្ថានមកលើកម្ពុជា ...... ២២
២.៣.១ ការបំពុលខ្យល់ ...... ២៣
២.៣.២ ការបំពុលទឹក ...... ២៥
២.៣.៣ កាកសំណល់រឹង ...... ២៨
២.៣.៤ បម្រែបម្រួលអាកាសធាតុ ...... ២៩

## ជំពូកទី៣
## ការវិភាគ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៣.១ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ...... ៣១
៣.១.១ លក្ខណៈវិនិច្ឆ័យ ...... ៣២
៣.១.២ លក្ខខណ្ឌដែលក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញ ...... ៣៣
៣.១.៣ ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ...... ៣៤
៣.២ ប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ៣៥
៣.៣ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... ៤០
៣.៣.១ គម្រោងស្នើសុំ ...... ៤១
៣.៣.២ ការជ្រើសរើសគម្រោង ...... ៤១

៣.៣.៣ ការកំណត់វិសាលភាព ......... ៤២
៣.៣.៤ ការវិភាគហេតុប៉ះពាល់បរិស្ថាន ......... ៤៣
៣.៣.៥ វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ......... ៤៤
៣.៣.៦ ការរៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន ......... ៤៥
៣.៣.៧ ធនធានបរិស្ថានដែលមានស្រាប់ ......... ៤៦
៣.៣.៨ ការពិនិត្យ និងធ្វើសេចក្តីសម្រេចលើរបាយការណ៍ ......... ៤៨
៣.៣.៩ ការពិនិត្យតាមដានគម្រោង ......... ៤៩
៣.៤ គំរូក្របខ័ណ្ឌទំនួលខុសត្រូវនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន ......... ៤៩
៣.៤.១ សេចក្តីផ្តើម ......... ៥០
៣.៤.២ គោលបំណងរបស់ក្របខ័ណ្ឌទំនួលខុសត្រូវ ......... ៥០
៣.៤.៣ ការពិពណ៌នារបស់គម្រោង ......... ៥០
៣.៤.៤ វិសាលភាព និងវិធីសាស្ត្រនៃការសិក្សា ......... ៥២
៣.៤.៥ ការកំណត់ទម្រង់របាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ......... ៥៨
៣.៤.៦ សមាសភាគនៃក្រុមការងារសិក្សា ......... ៦០
៣.៤.៧ កាលវិភាគការងារ/សកម្មភាពការងារសិក្សា ......... ៦០
៣.៤.៨ ឧបសម្ព័ន្ធ ......... ៦០
៣.៥ បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តច្បាប់ការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ......... ៦០
៣.៥.១ បញ្ហាប្រឈម ......... ៦០
៣.៥.២ ដំណោះស្រាយ ......... ៦១
**សេចក្តីសន្និដ្ឋាន** ......... ៦២
**អនុសាសន៍** ......... ៦៣
**ឯកសារយោង** .........
**ឧបសម្ព័ន្ធ** .........

# បញ្ជីអក្សរកាត់

| | |
|---|---|
| **EIA** | Environment Impact Assessment<br>ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| **EPI** | Environment Performance Index<br>សន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន |
| **PM 2.5** | Particulate matter / Particle Pollution<br>ភាគល្អិតគីមីដែលមានទំហំតូចជាង 2.5 មីក្រូម៉ែត្រ |
| **OECD** | Organization for Economic Co-operation Development<br>អង្គការសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច |
| **ODC** | Open Development Cambodia<br>អង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| **UNICEF** | United Nations International Children's Emergency Fund<br>មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| **USAID** | United States Agency for International Development<br>ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |

# បញ្ជីតារាង


តារាងទី១ បញ្ជីឈ្មោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

តារាងទី២ ចំណាត់ថ្នាក់គម្រោងដែលតម្រូវឲ្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

តារាងទី៣ មាតិកានៃរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បើយើងសង្កេតទៅមើលតាមភាពរីកចម្រើននៃសាកលភាវូបនីយកម្ម បរិស្ថានក៏មានការផ្លាស់ប្ដូរទៅតាមការអភិវឌ្ឍនៃសង្គម និងសម័យកាលនីមួយៗផងដែរ។ បរិស្ថានត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់សម្រាប់ពិភពលោក។

ប្រទេសកម្ពុជាធ្លាប់ត្រូវបានគេទទួលស្គាល់ថា គឺជាប្រទេសដែលសម្បូរទៅដោយធនធានធម្មជាតិដ៏មហាសាលមហិមារួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ និងសត្វព្រៃ។ល។ ប្រហែលបីភាគបួននៃប្រជាជនកម្ពុជាពឹងផ្អែកលើកសិកម្ម ទិន្នផលព្រៃឈើ និងនេសាទដើម្បីចិញ្ចឹមជីវិត។ ដូច្នេះហើយការថែរក្សាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិឱ្យបានសមស្របពិតជាមានសារៈសំខាន់ណាស់។

ប្រទេសកម្ពុជាបានចាប់ផ្ដើមការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ និងព្យាមយាមទាក់ទាញវិនិយោគទុនបរទេសមកវិនិយោគនៅកម្ពុជាបានបង្កឱ្យមានការផ្លាស់ប្ដូរយ៉ាងខ្លាំងចាប់តាំងពីចុងឆ្នាំ១៩៩៨ មកម្ល៉េះ។ លើសពីនេះទៅទៀតកម្ពុជាក៏បានប្រើប្រាស់នូវធនធានធម្មជាតិមួយចំនួនដើម្បីបម្រើឱ្យការអភិវឌ្ឍផងដែរ។

ប្រទេសកម្ពុជា មានការលូតលាស់ផ្នែកសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាងពីរទសវត្សរ៍មកហើយ។ ក្រោយពីបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥ កម្ពុជាបានកំណត់គោលដៅរបស់ខ្លួនក្នុងការឈានទៅ សម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។ ដោយសារការអភិវឌ្ឍលើគ្រប់វិស័យបានធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជាមានកំណើនក្នុង អត្រាប្រចាំឆ្នាំជាមធ្យម ៧,៧ភាគរយ ពីចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០១៩ ដែលជាអត្រាមួយធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតក្នុងពិភពលោក។ ថ្វីត្បិតតែការកើនឡើងនេះមានផលល្អដល់កំណើនសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែទោះជាយ៉ាងនេះក្ដីរាល់ការអភិវឌ្ឍបរិស្ថានសុទ្ធតែមានការប៉ះពាល់ដល់បរិស្ថាន និងសង្គមប្រសិនបើការអភិវឌ្ឍនោះមិនបានគិតពីហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់នោះ។

ទាំងអស់នេះហើយវាសុទ្ធសឹងតែជាបញ្ហាប្រឈម ដែលធ្វើឱ្យសាធារជនមានការព្រួយបារម្ភជាខ្លាំង។ មួយវិញទៀត ប្រសិនបើការបំពុលដែលចេញពី រោងចក្រ សហគ្រាស ឬអាជីវកម្មទាំងនោះខ្លាំងលើសកម្រិតទៀតសោត ច្បាស់ណាស់នៅថ្ងៃអនាគតបរិស្ថានរបស់កម្ពុជា វានឹងមានផលអាក្រក់យ៉ាងខ្លាំងដល់កម្ពុជា។ ហើយក្នុងនាមយើងខ្ញុំគឺជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំពិតជាចង់បាននូវចីរភាពក្នុងការអភិវឌ្ឍ ដែលការអភិវឌ្ឍនៅថ្ងៃនេះ មានផលល្អនៅថ្ងៃខាងមុខ មិនប៉ះពាល់ដល់ការអភិវឌ្ឍ និងការរស់នៅមនុស្ស សត្វ និងរុក្ខជាតិនៅនាពេលអនាគត។ ហេតុដូចនេះហើយទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសនៅប្រធានបទមួយដែលមានចំណងជើងថា **កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** មកធ្វើការសិក្សា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បរិស្ថាន គឺជាធនធានដ៏សំខាន់សម្រាប់ទ្រទ្រង់ភាវៈមានជីវិត។ ក្នុងជីវិតប្រចាំត្រូវការចាំបាច់បំផុតគឺបរិស្ថាន ព្រោះបរិស្ថានបានផ្តល់ជា ជម្រក ខ្យល់បរិសុទ្ធ និងផ្តល់នូវប្រភពទឹកផងដែរ។ ប៉ុន្តែសព្វថ្ងៃនេះយើងដឹងហើយថាការអភិវឌ្ឍន៍ ភាពជឿនលឿន និងការរីចម្រើនរបស់សង្គមគឺធ្វើឱ្យមានការប៉ះពាល់ទៅដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរជាហេតុដែលបង្កឱ្យមានបំពុលបរិស្ថាន។

ដោយសារតែការមើលឃើញបែបនេះហើយទើបយើងខ្ញុំកើតនូវសេចក្តីក្តីព្រួយបារម្ភ និងបានចោទចេញជាសំណួរដូចជា៖

- តើក្រសួងបរិស្ថានមានបានគិតគូរ និងកំពុងធ្វើអ្វីខ្លះពាក់ព័ន្ធនឹងបញ្ហានេះ?
- តើត្រូវមានវិធានការបែបណាដើម្បីកាត់បន្ថយការបំពុលបរិស្ថាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ បានផ្តោតសំខាន់ទៅលើហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា។ ដូចនេះហើយគោលបំណងជារួមធំបំផុតរបស់ប្រធានបទមួយនេះគឺស្វែងរកមូលហេតុចម្បងៗ ដែលបណ្តាលឱ្យមានការប៉ះពាល់បរិស្ថានបង្ហាញអំពីនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងរកដំណោះស្រាយ ឬវិធានការបែបណាក្នុងការទប់ស្កាត់នូវបញ្ហាប្រឈមផ្សេងៗ កុំឱ្យមានការបង្កទៅជាផលអាក្រក់ដល់បរិស្ថាន។

មួយវិញទៀតរកឃើញឱ្យកាន់តែច្បាស់អំពីផលប៉ះពាល់ទៅលើសង្គមជាតិទាំងបច្ចុប្បន្ន និងអនាគតដែលបណ្តាលមកពីការធ្វេសប្រហែស និងមិនយកចិត្តទុកដាក់របស់ប្រជាពលរដ្ឋទៅលើការរក្សាសណ្តាប់ធ្នាប់បរិស្ថាន។

ដើម្បីដោះស្រាយចម្ងល់នៃបញ្ហាខាងលើនេះ ក្រុមយើងខ្ញុំបានរកឃើញថានាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានកំពុងតែធ្វើការងារពាក់ព័ន្ធនឹងបញ្ហាទាំងអស់នេះ។ មិនតែប៉ុណ្ណោះដើម្បីផ្សាភ្ជាប់នឹងជំនាញរបស់យើងដែលជាហេតុនាំឱ្យយើងខ្ញុំបានលើកយកនូវប្រធានបទ **កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** មកធ្វើការស្រាវជ្រាវ និងលម្អិត។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ដោយផ្អែកលើប្រធានបទបានកំណត់សារណានេះ គឺផ្តោតសំខាន់លើការយកចិត្តទុកដាក់យ៉ាងស៊ីជម្រៅទៅលើប្រព័ន្ធនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រព្រឹត្តទៅយ៉ាងដូចម្តេច យើងខ្ញុំនឹងធ្វើការសិក្សាលម្អិតស៊ីជម្រៅ និងមុតមាំបំផុតនៃប្រធានបទកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ដើម្បីឱ្យការស្រាវជ្រាវប្រព្រឹត្តទៅបានល្អ និងអាចធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយ ហើយវិសាលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានភាពធំទូលាយ និងគ្រប់ដណ្តប់រាល់គម្រោងទាំងអស់នៅកម្ពុជាដែលគម្រោងទាំងអស់នោះបានបែងចែកចេញជាបួនវិស័យផ្សេងៗគ្នាមានដូចជា វិស័្យឧស្សាហកម្ម និងសុខាភិបាល វិស័យរ៉ែ និងថាមពល វិស័យកសិកម្ម និងធនធានទឹក និងចុងក្រោយវិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។ ហេតុដូច្នេះហើយដើម្បីឱ្យមានភាពច្បាស់លាស់ ក្រុមរបស់យើងខ្ញុំបានសម្រេចចិត្តយកវិស័យឧស្សាហកម្មមកធ្វើការវិភាគ និងសិក្សាស្រាវជ្រាវ ដោយសារតែវិស័យមួយនេះកំពុងមានការរីកចម្រើនយ៉ាងខ្លាំង។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារសំខាន់ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ និងចូលរួមវិភាគដ៏សំខាន់នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្វែងយល់អំពីដំណើរការនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននូវកំណែទម្រង់ក្នុងការផ្លាស់ប្តូរវិធានការផ្សេងៗក្នុងកិច្ចដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន ហើយក៏ចងក្រងទុកជាឯកសារ ដែលបំពេញតម្រូវការទៅដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវទាំងអស់ងាយស្រួលនូវក្នុងការសិក្សាស្វែងយល់បន្ថែម។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១ វិធីសាស្ត្រប្រមូលទិន្នន័យ

ដើម្បីសម្រេចបាននូវលទ្ធផលនៃការសិក្សាស្រាវជ្រាវមួយនេះឡើង យើងខ្ញុំបានប្រើវិធីសាស្ត្រស្រាវជ្រាវចំនួនពី ៖

- ទិន្នន័យទីមួយ (Primary Research) ជាប្រភេទទិន្នន័យផ្ទាល់ ដែលបានសាកសួរសំណួរមួយចំនួនទៅមន្រ្តីជំនាញដោយផ្ទាល់តែម្តង និងជាពិសេសសាស្ត្រាណែនាំ ពាក់ព័ន្ធទៅនឹងប្រធានបទរបស់យើងខ្ញុំ។
- ទិន្នន័យទីពីរ (Secondary Research) បានដកស្រង់ចំពោះខ្លឹមសារៗ និងចាំបាច់នានាដែលប្រមូលបានមកពីលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានជាធរមាន សៀវភៅ ព្រឹត្តបត្រ របាយការណ៍ ទស្សនាវដ្ដី នៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ គេហទំព័រនានាដែលយើងខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោងមួយចំនួនទៀត។

### ៦.២ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបាន គឺយកមកវិភាគតាមរយៈការពិពណ៌នាបែបគុណភាពដោយប្រើទិន្នន័យទីពីរ (Secondary Data) ច្រើនលើសលប់ជាងទិន្នន័យទីមួយ ព្រោះថាទិន្នន័យទីពីរយើងខ្ញុំ ប្រមូលបានច្រើន

ដែលជាហេតុធ្វើឱ្យយើងខ្ញុំធ្វើការវិភាគបានគ្រប់ជ្រុងជ្រោយជាងទិន្នន័យទីមួយ (Primary Research)។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះ មានចំនួន៦៣ទំព័រ ហើយត្រូវបែងចែកជា ៣ជំពូក ដូចខាង ក្រោម៖

- **សេចក្តីផ្តើម**

ចំណុចនេះនឹងបង្ហាញពី លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ (មានចំនួនទំព័រ ០៤ទំព័រ ចាប់ពីទំព័រ០១ ដល់ទំព័រ០៤)។

- **ជំពូកទី១៖ លក្ខណៈទូទៅស្តីអំពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

ជំពូកនេះនឹងបង្ហាញលោកអ្នកឱ្យបានដឹងខ្លះៗអំពី គោលបំណង អ្វីទៅជាបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងចុងក្រោយក្របខ័ណ្ឌច្បាប់ ដើម្បីអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ និងសម្រេចបានតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ច្បាប់ (មានចំនួនទំព័រ ០៧ទំព័រ ចាប់ពីទំព័រ០៥ ដល់ទំព័រ១១)។

- **ជំពូកទី២៖ ស្ថានភាពទូទៅនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

ជំពូកនេះនឹងប្រាប់អំពី បទបញ្ញត្តិផ្សេងៗទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្ថានភាពទូទៅនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចជា នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់បរិស្ថានមកលើកម្ពុជា (មានចំនួនទំព័រ១៩ទំព័រ ចាប់ពីទំព័រ១២ ដល់ទំព័រ៣០)។

- **ជំពូកទី៣៖ ការវិភាគ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

សម្រាប់ជំពូកចុងក្រោយនេះនឹងបង្ហាញអំពី ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គំរូក្របខ័ណ្ឌទំនួលខុសត្រូវនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តច្បាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (មានចំនួនទំព័រ៣១ទំព័រ ចាប់ពីទំព័រ៣១ ដល់ទំព័រ៦១)។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖**

យើងខ្ញុំបានធ្វើការសន្និដ្ឋានជារួមនៃប្រធានបទទាំងមូល និងលើកឡើងនូវអនុសាសន៍មួយចំនួន ដែលយើងខ្ញុំបានមកពីការរកឃើញនៅក្នុងសារណានេះ (មានចំនួនទំព័រ ០២ទំព័រ ចាប់ពីទំព័រ៦២ ដល់ទំព័រ៦៣)។

# ជំពូកទី១
# លក្ខណៈទូទៅស្តីអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ១.១ គោលបំណង

គោលបំណងចម្បងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺដើម្បីធានាថាកត្តាពិចារណាផ្នែកបរិស្ថានត្រូវបានយកចិត្តទុកដាក់ច្បាស់លាស់ និងដាក់បញ្ចូលទៅក្នុងដំណើរការធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍ។ ដើម្បីព្យាករណ៍ និងជៀសវាង កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម និងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗទៀតនៃដំណើរការគម្រោងអភិវឌ្ឍន៍។ មួយវិញទៀតដើម្បីការពារផលិតភាព និងសមត្ថភាពនៃប្រព័ន្ធធម្មជាតិ និងដំណើរការអេកូឡូស៊ីដែលថែរក្សាមុខងាររបស់វា និងលើកកម្ពស់ការអភិវឌ្ឍដែលមាននិរន្តភាព និងបង្កើនការប្រើប្រាស់ និងឱកាសគ្រប់គ្រងធនធានជាអតិបរមា។

## ១.២ អ្វីទៅជាបរិស្ថាន

បរិស្ថាន ជាទូទៅសំដៅលើអ្វីដែលនៅជុំវិញខ្លួនយើង ដែលបុគ្គលម្នាក់ៗ និងសហគមន៍ស្ថិតនៅក្នុងនោះ។ បរិស្ថាន គឺជាមូលដ្ឋាននៃជីវិតរស់នៅរបស់មនុស្សជាតិ។ បរិស្ថានផ្តល់នូវលក្ខខណ្ឌសម្រាប់ការរស់រានការអភិវឌ្ឍ និងការរីកចម្រើន ព្រមទាំងគ្រោះថ្នាក់ និងការខូចខាតផងដែរ។ បរិស្ថានរួមមាន ខ្យល់ ទឹក ដី ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី អាកាសធាតុ ដែលមនុស្ស រុក្ខជាតិ និងសត្វរស់នៅ និងមានទំនាក់ទំនង។[1]

យើងក៏ជាផ្នែកមួយនៃធម្មជាតិ យើងអាចរីកចម្រើនទៅបានលុះត្រាតែគំរូសង្គម នយោបាយ វប្បធម៌ និងសេដ្ឋកិច្ចសង្គមគោរព និងធានាដល់បរិស្ថានល្អប្រសើរ។

### ១.២.១ និយមន័យបរិស្ថាន

ពាក្យបរិស្ថានមកពីភាសាបារាំង ( environner ) ដែលវាមានន័យថាជាការព័ទ្ធជុំវិញដែលយើងមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយវាហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថាន ឬជាលក្ខខណ្ឌទាក់ទិនគ្នានៅក្នុងសង្គម និងវប្បធម៌ឥទ្ធិពលលើបុគ្គលណាមួយ ឬសហគមន៍រស់នៅ។ យើងក៏អាចឱ្យនិយមន័យផងដែរថា៖

ទី១ គឺជាដី សមុទ្រ ខ្យល់ អាកាសធាតុ រុក្ខជាតិ និងអ្វីៗដែលនៅជុំវិញខ្លួនយើងដែលមានមនុស្ស សត្វ និងរុក្ខជាតិផងដែរទាំងនេះហៅថា បរិស្ថានរូប។

[1] សេចក្តីផ្តើមអំពីការបញ្រ្ជាបបរិស្ថាន។ បានដកស្រង់ ០៦ មិថុនា ២០២៤

ទី២ គឺកត្តាទាំងឡាយណាដែលមានហេតុប៉ះពាល់លើប្រភេទសារពាង្គកាយណាមួយ ឬក៏ជះឥទ្ធិពលលើប្រភពយើងទាំងមូល។

បរិស្ថានរបស់យើងគឺជាវត្ថុទាំងឡាយដែលនៅជុំវិញ ហើយវាមានឥទ្ធិពលដល់យើងវិញរួមមានទាំងអ្វីដែលបានមកពីធម្មជាតិ ឧទាហរណ៍មាន ដើមឈើ មច្ឆជាតិ ទឹកភ្លៀង គឺបរិស្ថានធម្មជាតិ។ អ្វីៗដែលបង្កើតដោយស្នាដៃមនុស្ស ឧទាហរណ៍ មានដូចជា ទូរស្សន៍ និងរថយន្ត គឺបរិស្ថានបង្កើតដោយមនុស្ស។ ចំណេះដឹង និងជំនឿផ្សេងៗ ហើយនិងក្រុមហ៊ុនទាំងឡាយណាដែលបានរៀបចំឡើង គឺជាបរិស្ថានសង្គម។ ទ្រព្យសម្បត្តិដែលយើងមាន ឬក៏មិនមានហៅថា បរិស្ថានសេដ្ឋកិច្ច ហើយនិងអ្វីៗដែលបានអនុវត្តលើសីលធម៌ដែលវាពិនិត្យលើសុជីវធម៌លើការទទួលខុសត្រូវក្នុងការងាររស់នៅគឺជាក្រមបរិស្ថានក្នុងការរស់នៅ។[2]

### ១.២.២ ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការធ្វើចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍន៍នៅកម្ពុជាដែលតម្រូវឱ្យមានកិច្ចសន្យាការពារបរិស្ថាន និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។ សម្រាប់ការអនុវត្តចំពោះរាល់គម្រោង ឬសកម្មភាពដែលបានស្នើឡើងរួមមានទាំងគម្រោងដែលមានស្រាប់ និងកំពុងដំណើរការរបស់បុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចម្រុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ក្រសួងស្ថាប័នរដ្ឋ។

### ១.២.៣ បញ្ហាបរិស្ថាននៅជុំវិញពិភពលោក

យើងដឹងហើយថា ការរីកចម្រើននៃសង្គមបច្ចុប្បន្នមានការប៉ះពាល់ទៅដល់បរិស្ថានពាសពេញពិភពលោក។ បញ្ហាបរិស្ថាន គឺជាបញ្ហាប្រឈមដ៏ចម្បងមួយដែលពិភពលោកកំពុងមានការព្រួយបារម្ភនឹងយកចិត្តទុកដាក់ខ្លាំងបំផុត។ ការកើតឡើងនូវកំណើនប្រជាជន កំណើនតម្រូវការ ការកាប់បំផ្លាញព្រៃឈើ ការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី ការចាក់ចោលកាកសំណល់ជាច្រើនដែលធ្វើឱ្យបាត់បង់ជីវៈចម្រុះ។ល។ ផលវិបាកដែលស្តែងចេញតាមរយៈ ការបំផ្លាញស្រទាប់អូហ្សូនបណ្តាលឱ្យមានការប្រែប្រួលអាកាសធាតុក្តៅខ្លាំងដែលជះឥទ្ធិផលបំផ្លាញដល់សុខភាពមនុស្ស និងផលិតភាពរបស់ស្ថានប្រព័ន្ធធម្មជាតិ ឬប្រព័ន្ធដែលមនុស្សរស់នៅ។ បរិស្ថាននៅតែបន្តគំរាមគំហែងដល់ពិភពលោក និងមានលក្ខណៈធ្ងន់ធ្ងរទៅៗ ដែលបង្កឲ្យមានភាពព្រួយបារម្ភក្នុងការប្រឈមជាមួយ និងបញ្ហាគ្រោះធម្មជាតិ។

នៅឆ្នាំ២០២២ អាកាសធាតុអាក្រក់ខ្លាំង និងគ្រោះធម្មជាតិបានកើតឡើងជាញឹកញាប់នៅជុំវិញពិភពលោក។ រលកកម្តៅខ្លាំង គ្រោះរាំងស្ងួត និងទឹកជំនន់បំផ្លិចបំផ្លាញក្នុងឆ្នាំ២០២២ បានប៉ះពាល់ដល់មនុស្សរាប់

[2] https://km.wikipedia.org/wiki/។ បានដកស្រង់ ១៦ មិថុនា២០២៤

លាននាក់ និងបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរាប់ពាន់លានដុល្លារសហរដ្ឋអាមេរិក។ [3] បម្រែបម្រួលអាកាសធាតុ គឺជាការគំរាមកំហែងទូទៅចំពោះមនុស្សជាតិទាំងមូល។ កិច្ចសហប្រតិបត្តិការ គឺជាមធ្យោបាយតែមួយគត់ដើម្បីរួមគ្នាដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ។ យោងតាមបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ ប្រទេសទាំងអស់ក្នុងពិភពលោកត្រូវតែ "ទទួលខុសត្រូវរួម ប៉ុន្តែចែកដោយឡែកពីគ្នា "។

មើលទៅលើប្រវត្តិសាស្ត្រ ដំណើរការឧស្សាហូបនីយកម្មនៃប្រទេសអភិវឌ្ឍន៍គឺជា បុព្វហេតុចម្បងនៃបម្រែបម្រួលអាកាសធាតុ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងប្រវត្តិសាស្ត្រប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនបានរួមចំណែកក្នុងការធ្វើឱ្យមានបម្រែបម្រួលអាកាសធាតុ ឥឡូវនេះកំពុងទទួលឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុដោយមិនស្មើភាពគ្នា។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ប្រទេសជិត ២០០ ប្រទេស បានចូលរួមក្នុងសន្និសីទលើកទី២៧ នៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (COP27) ។ [4]

បម្រែបម្រួលអាកាសធាតុ និងបញ្ហាបរិស្ថាននៅជុំវិញពិភពលោកបានក្លាយទៅជាវិបត្តិសកលជាក់ស្តែង និងបន្ទាន់។ ប្រទេសនីមួយៗគួរតែទទួលខុសត្រូវដោយស្មោះត្រង់រៀងៗខ្លួន ហើយធ្វើការរួមគ្នាដើម្បីលើកកម្ពស់ដំណើរការនៃការគ្រប់គ្រងបរិស្ថាននៅជុំវិញពិភពលោក។

## ១.៣ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ( EIA )

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងតំបន់អាស៊ាន ត្រូវបានទទួលស្គាល់បន្ថែមទៀតនៅក្នុងសេចក្តីប្រកាសស្តីពីបរិស្ថានអាស៊ាន នៅទីក្រុងបាងកក ឆ្នាំ ១៩៨៤។ [5] សេចក្តីប្រកាសនេះបានព្យាយាម "ពង្រឹងការប្រើប្រាស់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវិភាគចំណាយ-ចំណេញលម្អិត ដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ និងដើម្បីធានាការពិចារណាត្រឹមត្រូវអំពីគុណតម្លៃបរិស្ថាន និងកម្មវិធីទាំងអស់របស់រដ្ឋាភិបាលដែលអាចនឹងបង្កឱ្យមានផលប៉ះពាល់ផ្នែកបរិស្ថានយ៉ាងធ្ងន់ធ្ងរ និងការពង្រីកជាបណ្តើរៗ របស់រដ្ឋទៅវិស័យឯកជនក្នុងវិស័យឧស្សាហកម្ម"។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានដាក់ឱ្យប្រើប្រាស់នៅសហរដ្ឋអាមេរិក នៅដើមឆ្នាំ១៩៧០ ទៅតាមច្បាប់គោលនយោបាយបរិស្ថានជាតិ។ ចាប់តាំងពីពេលនោះមកគំនិត និងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានការកើនឡើងយ៉ាងខ្លាំង។ ការពិនិត្យឡើងវិញនៅឆ្នាំ១៩៩៦ ដោយសមាគមអន្តរជាតិដើម្បី

[3] របាយការណ៍បណ្តោះអាសន្នស្តីពី "ស្ថានភាពនៃអាកាសធាតុសកលឆ្នាំ២០២២" (Provisional State of the Global Climate 2022)របស់អង្គការឧតុនិយមពិភពលោក (the World Meteorological Organization)។ បានអាន ០៧ មិថុនា ២០២៤

[4] ពិធីបើកសន្និសីទអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (COP27)។ បានអាន ០៧ មិថុនា ២០២៤

[5] Bangkok Declaration of the ASEAN Environment, (29 November 1984)។ បានអាន ០៧ មិថុនា ២០២៤

វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទៅលើបទពិសោធន៍អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទូទាំងពិភពលោក បានស្នើឡើងនូវធាតុផ្សំធំៗបួន សម្រាប់ការអនុវត្តការវាយតម្លៃបរិស្ថានដោយប្រសិទ្ធភាពគឺ ៖[6]

- ការកំណត់ពេលវេលាសមរម្យក្នុងការផ្តួចផ្តើមការវាយតម្លៃ ដើម្បីឱ្យមានការពិនិត្យសំណើគ្រប់គ្រាន់ទាន់ពេលចំពោះវិសាលភាពសម្រាប់ការអភិវឌ្ឍជម្រើសសមហេតុផល
- ការណែនាំជាក់លាក់ច្បាស់លាស់ក្នុងទម្រង់នៃលក្ខខណ្ឌការងារ ឬគោលការណ៍ណែនាំដែលផ្តោតលើបញ្ហាអាទិភាព ពេលវេលា និងឱកាសសម្រាប់ផ្តល់ព័ត៌មាន និងការផ្តល់គំនិតក្នុងដំណាក់កាលធ្វើសេចក្តីសម្រេចសំខាន់ៗ
- ព័ត៌មាន និងផលិតផលមានគុណភាពដែលលើកកម្ពស់ដោយអនុលោមតាមគោលការណ៍ណែនាំតាមនីតិវិធី និងការអនុវត្ត "វិធីអនុវត្តន៍ល្អ" និង
- ការទទួលយកដោយក្រុមអ្នកធ្វើការសម្រេចចិត្ត និងអ្នកគាំទ្រ ចំពោះលទ្ធផលនៃការវាយតម្លៃបរិស្ថានដែលបង្កើតឡើងដោយផ្អែកលើការផ្សព្វផ្សាយល្អ និងគណនេយ្យភាព។

តម្រូវការផ្នែកច្បាប់បឋមសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន Environmental Impact Assessment (EIA) មានគោលបំណងធានាប្រសិទ្ធភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជនដោយមានការចូលរួមជាសាធារណៈសម្តៅបង្ការ បញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គម ដែលបង្កឡើងដោយគម្រោងវិនិយោគ។ វិសាលភាពអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជនមានជាអាទ៍ គម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការដែលអាចបង្កហេតុប៉ះពាល់បរិស្ថាន សុខភាព សេដ្ឋកិច្ច និងវប្បធម៌។ ក្នុងករណីដែលគម្រោងអភិវឌ្ឍអាចបង្កឱ្យមានហេតុប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ចសង្គម និងវប្បធម៌ ម្ចាស់គម្រោងត្រូវធ្វើការសិក្សាបន្ថែមទៅលើហេតុប៉ះពាល់ឆ្លងដែន ដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តជាតិពាក់ព័ន្ធ និងការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែនដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍ ឬសកម្មភាពរបស់រដ្ឋ ដែលបានសម្រេច ឬអនុម័តដោយរាជរដ្ឋាភិបាលឬរដ្ឋសភាដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ ឬគ្រោះមន្តរាយនានា។ រាល់គម្រោងអភិវឌ្ឍត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិជា

[6] សៀវភៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ (បោះពុម្ពលើកទី១ ខែតុលា ឆ្នាំ២០១៦)។ បានដកស្រង់ ១២ មិថុនា ២០២៤

មុនសិន មុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ រាល់ការចេញអជ្ញាបណ្ណ លិខិតអនុញ្ញាត ឬសេចក្ដីសម្រេចលើគម្រោងអភិវឌ្ឍនានាដោយអជ្ញាធរមានសមត្ថកិច្ច ឬក្រសួងសាមី ឬរាជរដ្ឋាភិបាល ត្រូវធ្វើឡើងអនុលោមតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិត និងវិញ្ញាបនត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន។ រាល់អជ្ញាបណ្ណ លិខិតអនុញ្ញាត ឬសេចក្ដីសម្រេចនានាដែលផ្ទុយនឹងបញ្ញត្តិត្រូវទុកជាមោឃៈ។

### **១.៣.១ និយមន័យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** (EIA)

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) គឺជាដំណើរការនៃ ការកំណត់ ការប៉ាន់ស្មាន ការវាយតម្លៃ និងការកាត់បន្ថយហេតុប៉ះពាល់លើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម និងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗទៀតដែលបណ្ដាលមកពីសំណើគម្រោង និងសកម្មភាពរូបវន្តនានាមុនពេលធ្វើសេចក្ដីសម្រេចសំខាន់ៗ និងប្ដេជ្ញាចិត្តអនុវត្តគម្រោង។[7]

និយមន័យខាងលើ ត្រូវបានអនុម័តដោយការពិនិត្យឡើងវិញនៅឆ្នាំ១៩៩៦នោះ និយមន័យនេះវានៅតែសមស្របរហូតមកដល់ពេលបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀតការពិនិត្យឡើងវិញឆ្នាំ១៩៩៦ បានស្នើរឡើងនូវគោលបំណងសំខាន់ពីរក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺ៖[8]

- ទី១ គោលបំណងចំពោះមុខគឺដើម្បីជួយសម្រួលឱ្យមានការធ្វើសេចក្ដីសម្រេចគួរទុកចិត្តបញ្ចូលគ្នាដែលនៅក្នុងការសម្រេចចិត្តនោះ ការគិតអំពីបរិស្ថានត្រូវបានបញ្ចូលយ៉ាងច្បាស់លាស់។ ដំណើរការនៃការវាយតម្លៃបរិស្ថានត្រូវធ្វើដោយផ្ដល់ព័ត៌មានច្បាស់លាស់ និងមានរបៀបរៀបចំយ៉ាងល្អអំពីផលប៉ះពាល់ហានិភ័យ និងផលវិបាកផ្នែកបរិស្ថានដែលបណ្ដាលមកពីជម្រើស និងសំណើរគម្រោងអភិវឌ្ឍន៍។

- ទី២ ដំណើរការនៃការវាយតម្លៃបរិស្ថានជាទូទៅ(ប៉ុន្តែមិនជាសកលទេ) ត្រូវសំដៅទៅរកការសម្រេចបាននូវឬគាំទ្រដល់គោលដៅចុងក្រោយនៃកិច្ចការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តភាព។ សេចក្ដីយោង ឬគោលដៅចុងក្រោយទាំងនេះត្រូវបានរៀបចំ និងបង្កើតឡើងនៅក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយអំពីការវាយតម្លៃបរិស្ថានដូចគ្នា និងការបំពេញបាននូវបំណងជាក់លាក់ដោយដំណើរការនេះ។

[7] សៀវភៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ (បោះពុម្ពលើកទី១ ខែតុលា ឆ្នាំ២០១៦)។ បានដកស្រង់ ១២ មិថុនា ២០២៤

[8] ដូចយោងខាងលើ

### ១.៣.២ ដើមកំណើតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសនៅឆ្នាំ១៩៩១ និងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិឆ្នាំ១៩៩៣ ប្រទេសកម្ពុជា បានចាប់ផ្តើមពិចារណាចំពោះការប្រើប្រាស់ធនធានធម្មជាតិ ដែលសម្បូរបែបឱ្យមាននិរន្តរភាព។ ក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងធ្វើការយ៉ាងសកម្មក្នុងទិសដៅបង្កើតលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន ដែលជាស្ថាប័នកំពូលក្នុងការដឹកនាំអភិរក្ស និងគ្រប់គ្រងបរិស្ថាន។ បន្ទាប់មក នៅឆ្នាំ១៩៩៦ លេខាធិការដ្ឋាននេះបាន ប្រែក្លាយជាក្រសួងបរិស្ថាន។ នាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានត្រូវបង្កើតឡើង និងទទួលស្គាល់ជាផ្លូវការដោយអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧។ វិធីនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។[9]

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គឺតម្រូវឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីចងក្រងជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយរបាយការណ៍នេះគឺត្រូវឆ្លងកាត់ការពិនិត្យ និងផ្តល់យោបល់ពីក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ។

### ១.៣.៣ គោលការណ៍សំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានប្រសិទ្ធភាពបានតាមរយៈការអនុម័ត និងការអនុវត្តគោលការណ៍សំខាន់ៗ ដូចខាងក្រោម ៖[10]

- ដំណើរការដែលបង្កើតឡើងដោយស្របច្បាប់ ច្បាស់លាស់ និងប្រសិទ្ធភាព
- អ្នកស្នើសុំគម្រោង រ៉ាប់រងចំណាយលើដំណើរការអនុវត្ត និងវាយតម្លៃ
- ការចូលរួមជាសាធារណៈនៅគ្រប់ដំណាក់កាលនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធអាចទទួលបានព័ត៌មាន
- មានព័ត៌មានពាក់ព័ន្ធទាំងអស់
- ការធ្វើសេចក្តីសម្រេចដោយបើកចំហ និងមានភស្តុតាងជាមូលដ្ឋាន
- និងការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្តដែលមានប្រសិទ្ធភាព។

---

[9] មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំផលិត២០១២។ បានដកស្រង់ ០៥ មិថុនា ២០២៤

[10] សៀវភៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ (បោះពុម្ពលើកទី១ ខែតុលា ឆ្នាំ២០១៦)។ បានដកស្រង់ ១២ មិថុនា ២០២៤

## ១.៤ ក្របខណ្ឌច្បាប់

ក្នុងក្របខ័ណ្ឌច្បាប់ ម្ចាស់គម្រោងត្រូវពិពណ៌នាអំពីច្បាប់ អនុក្រឹត្យ និងគោលនយោបាយនានាដែលមានការពាក់ព័ន្ធទៅនឹងប្រភេទគម្រោងដែលនឹងត្រូវបានអនុវត្ត។ រាល់ខ្លឹមសារមាត្រានៃច្បាប់ និងបទបញ្ញត្តិដូចបានរៀបរាប់ខាងលើ ត្រូវតែមានការពាក់ព័ន្ធនឹងភារកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងគម្រោងអភិវឌ្ឍន៍។ បទបញ្ញត្តិ និងស្តង់ដាបរិស្ថានដែលត្រូវយកមកអនុវត្តក្នុងគម្រោងត្រូវតែមានឯកសារយោងត្រឹមត្រូវ។[11]

ដើម្បីអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ និងសម្រេចបានតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ច្បាប់ ក្រសួងបរិស្ថានត្រូវផ្អែកលើលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចខាងក្រោម៖[12]

- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨
- អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេងឆ្នាំ២០០០
- ប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការកំណត់ថ្លៃសេវាការងារសម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើល ឆ្នាំ២០១៩
- ប្រកាស ស្តីពីប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងវិនិយោគឯកជន ឆ្នាំ២០២២
- ប្រកាស ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩។

[11] ជំពូក២ ប្រកាសលេខ៣៧៦ ប្រ.ក.ប.ស្ត ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៥ មិថុនា ២០២៤

[12] មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ មិថុនា ២០២៤

# ជំពូកទី២
# ស្ថានភាពទូទៅនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ២.១ បទបញ្ញត្តិផ្សេងៗទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

យោងតាមមាត្រា៦ នៃព្រះរាជក្រមលេខ១២៩៦ នស.រកម.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងបរិស្ថានធម្មជាតិ៖

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពឯកជន ឬសាធារណៈ ហើយត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។
- ការវាយតម្លៃក៏ត្រូវអនុវត្តផងដែរចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការហើយដែលពុំទាន់វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។
- បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។
- ប្រភេទ និងទំហំគម្រោង និងសកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យនឹងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។[13]

បន្ថែមពីនេះ ក្នុងការវាយតម្លៃគម្រោងនេះផងដែរក្រសួងក៏បានបំផុសឱ្យមានការចូលរួមពីសាធារជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មក ធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។ មួយវិញទៀត ក្រសួងតម្រូវម្ចាស់គម្រោងត្រូវធ្វើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគម្រោងដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ បន្ទាប់មកម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ ព្រមទាំងរបាយការណ៍សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន។ មិនត្រឹមតែប៉ុណ្ណោះម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍លទ្ធផលទៅក្រសួងបរិស្ថាន

[13] ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ,ឆ្នាំ១៩៩៦ ។ចូលអាន ០២ កក្កដា ២០២៤

ចំពោះគម្រោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស្តែម សុខភាព និងសុខមាលភាពសាធារណៈ។[14]

ជាពិសេសក្រសួងបានធ្វើប្រតិភូកម្មអំណាចទៅឱ្យមន្ទីរបរិស្ថាន ខេត្ត-ក្រុង មានសិទ្ធពិនិត្យផ្តល់យោបល់ និងសម្រេចលើរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន សម្រាប់គម្រោងវិនិយោគ ដែលមានទំហំទុនវិនិយោគក្រោម ៥(ប្រាំ) លានដុល្លារសហរដ្ឋអាមេរិកចុះ ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។[15]

សម្គាល់៖[16]

- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (វ.ហ.ប.ដ)៖ គឺជាការសិក្សាដំបូងលើ ធនធានបរិស្ថានរូបសាស្ត្រ ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនគឺពឹងផ្អែកទៅ លើទិន្នន័យមានស្រាប់ដែលមាននៅក្នុង និងជុំវិញតំបន់គំរោង ដើម្បីជាមូលដ្ឋានកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើង ដោយសារសកម្មភាពរបស់គម្រោង សំដៅរកវិធានការកាត់បន្ថយនូវហេតុ ប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កម្រិតអតិបរមា។ ប្រសិនបើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង មានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរនោះទាមទារឱ្យម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (វ.ហ.ប)៖ គឺជាការសិក្សាលម្អិតលើ ធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនពឹងផ្អែកទៅលើទិន្នន័យចម្បងដែលមាននៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង សម្តៅរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានអោយដល់កម្រិតអតិបរមា។

[14] អនុក្រឹត្យលេខ ៧២អនក្រ.បក ចុះថ្ងៃទី១១ សីហា ១៩៩៩, ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ចូលអាន០២ កក្កដា ២០២៤

[15] ប្រកាសលេខ៣៥៦ ប្រ.ក.ប.ស្ក ចុះថ្ងៃទី២៣ វិច្ឆកា ២០២២, ស្តីពីប្រតិភូកម្មអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន។ ចូលអាន០២ កក្កដា ២០២៤

[16] ប្រកាសលេខ៣៧៦ ប្រ.ក.ប.ស្ក ចុះថ្ងៃទី០២ កញ្ញា ២០០៩, ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងពេញលេញ។ បានអាន០២ កក្កដា ២០២៤

## ២.២ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ២.២.១ ប្រវត្តិនៃការបង្កើតក្រសួង

ប្រទេសកម្ពុជាជាប្រទេសសម្បូរទៅដោយជីវចម្រុះ ព្រមទាំងពោរពេញទៅដោយសម្បត្តិធម្មជាតិដ៏មានតម្លៃ និងបរិស្ថានដ៏ស្រស់ស្អាត។ ដើម្បីថែរក្សាសម្បត្តិដ៏មានតម្លៃនេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៥៩ បានចែងថា "រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល"។ ក្នុងស្មារតីនេះ **ព្រះបាទ នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិដើម្បីកំណត់អំពីផ្ទៃឧទ្យានធម្មជាតិដែនជម្រកសត្វព្រៃតំបន់ការពារទេសភាព និងតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រមទាំងកំណត់អំពីការទទួលខុសត្រូវលើការគ្រប់គ្រង និងអភិបាលប្រព័ន្ធតំបន់ធម្មជាតិដោយសិទ្ធិអំណាច និងការទទួលខុសត្រូវទាំងនេះ ត្រូវបានប្រគល់ទៅឱ្យរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថានជាអ្នកអនុវត្តន៍។ [17]

ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងដោយព្រះរាជក្រម នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន។ គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ ការពារធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរ អង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការបង្កើតក្រសួងបរិស្ថានដើម្បីកំណត់បេសកម្ម ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងស្ថាប័ន និងបណ្តាអង្គភាពក្រោមឱវាទក្រសួង។[18]

### ២.២.២ ចក្ខុវិស័យ និងបេសកកម្ម

ក្រសួងបរិស្ថាន បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងមានចក្ខុវិស័យច្បាស់លាស់។ ចក្ខុវិស័យរបស់ក្រសួងបរិស្ថាន គឺការលើកស្ទួយកិច្ចគាំពារការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកកែលម្អគុណភាពបរិស្ថាន ទ្រទ្រង់សុខភាពសាធារណៈ វប្បធម៌ជាតិ និងសេដ្ឋកិច្ចសង្គម។ ក្រសួងបរិស្ថានមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងគ្រប់គ្រងការងារ

[17] ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតតំបន់ការពារធម្មជាតិ។ បានអាន ២០ មិថុនា ២០២៤

[18] អនុក្រឹត្យលេខ២០អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។ បានអាន ២០ មិថុនា ២០២៤

បរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មុខងារ និងភារកិច្ចដ៏ចម្បងនេះត្រូវបានចង្អុលឱ្យអនុវត្តតាមរយៈការបំពេញមុខងារអាទិភាពមួយចំនួនដូចជា៖[19]

- រៀបចំទស្សនវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- តាក់តែង និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីធានាការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព
- គ្រប់គ្រងទិន្នន័យបរិស្ថាន និងដឹកនាំសម្របសម្រួលការងារអប់រំ និងការផ្សព្វផ្សាយបរិស្ថាន ព្រមទាំងចាត់ចែងព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងវិស័យបរិស្ថាន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការផ្សព្វផ្សាយព័ត៌មាននិងសកម្មភាពបង្កើនការយល់ដឹងនានា
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា
- ផលិត និងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណជន
- គ្រប់គ្រង និងសម្របសម្រួលកិច្ចគាំពារបរិស្ថាន រួមមានការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសំឡេងនិងរំញ័រ និងការគ្រប់គ្រងការបំភាយកាំរស្មីវិទ្យុសកម្ម និងអេឡិចត្រូម៉ាញ៉េទិក
- រៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន

[19] អនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។ បានអាន និងដកស្រង់ ២០ មិថុនា ២០២៤

- គ្រប់គ្រង និងសម្របសម្រួលការងារការពារ និងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព
- ប្រមូលវិភាគ និងគ្រប់គ្រងទិន្នន័យបរិស្ថាន និងធនធានធម្មជាតិ
- ជំរុញ និងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- កៀរគរ និងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សហការជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀងអនុសញ្ញា និងពិធីសារអន្តរជាតិនានាដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាពព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀងអនុសញ្ញា និងពិធីសារទាំងនេះ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។

### ២.២.៣ រចនាសម្ព័ន្ធក្រសួង

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[20]

យោងអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថាន មានអគ្គនាយកដ្ឋានចំណុះទីស្តីការក្រសួងចំនួន

[20] អនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។ បានអាន ២០ មិថុនា ២០២៤

ប្រាំមួយ(០៦) អគ្គាធិការដ្ឋានមួយ(០១) នាយកដ្ឋានសវនកម្មផ្ទៃក្នុង(០១) និងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន(០១)។[21]

ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក. អង្គភាពថ្នាក់ជាតិ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ
- អគ្គនាយកដ្ឋានគាំពារបរិស្ថាន
- អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ
- អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន
- អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ. អង្គភាពថ្នាក់ក្រោមជាតិ

- មន្ទីរបរិស្ថានរាជធានី ខេត្ត។

គ. គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ

- គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ ក្រសួងបរិស្ថាន។

[21] ក្រសួងបរិស្ថាន។ បានអាន ២០ មិថុនា ២០២៤ , https://www.moe.gov.kh/




*(ដកស្រង់រូបភាពពីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ២៣៤ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន)*

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាននិងអង្គភាពថ្នាក់ស្មើនាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មន្ទីរបរិស្ថានរាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យនីមួយៗ និងអង្គភាពនានាក្រោមឱវាទនាយកដ្ឋាន និងអង្គភាព ថ្នាក់ក្រោមជាតិនៃក្រសួងបរិស្ថានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។[22]

[22] អនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន។ បានអាន ២០ មិថុនា ២០២៤

### ២.២.៤ មូលហេតុនៃការបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

បច្ចុប្បន្ន ពិភពលោកកំពុងប្រឈមមុខនឹងបញ្ហាបរិស្ថានជាច្រើន ហើយបញ្ហាទាំងនោះហាក់ដូចជាកាន់តែអាក្រក់ទៅៗពីមួយឆ្នាំទៅមួយឆ្នាំ ដែលនឹងនាំឱ្យមនុស្សជួបផលវិបាកលើគ្រប់វិស័យ។ ដូច្នេះ វាមានសារៈសំខាន់ណាស់សម្រាប់លើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាំងនេះ ក៏ដូចជាអ្វីដែលអាចធ្វើបាន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើមនុស្សជាតិ។ នាយកដ្ឋាន អង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបង្កើតឡើង និងទទួលស្គាល់ជាផ្លូវការ ដោយអនុក្រឹត្យលេខ៥៧ អនក្រ.ក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧។ រីឯនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

អនុក្រឹត្យនេះមានគោលបំណងៈ[23]

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគម្រោង សកម្មភាពដែលស្នើរឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសារធារណៈដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគម្រោង។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគម្រោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការដែលជាបុគ្គលិកឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចំណុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ក្រសួង ស្ថាប័នរដ្ឋដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសម្រេចដោយរាជរដ្ឋាភិបាល។[24]

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គឺតម្រូវឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីចងក្រងជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយរបាយការណ៍នេះគឺត្រូវឆ្លងកាត់ការពិនិត្យ និងផ្តល់យោបល់ពីក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ មុននឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការអនុម័តលើគម្រោងអភិវឌ្ឍន៍។

[23] មាត្រា១ អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ បានអាន ១០ មិថុនា ២០២៤

[24] មាត្រា២ អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់ បរិស្ថាន។ បានអាន ១០ មិថុនា ២០២៤

### ២.២.៥ រចនាសម្ព័ន្ធនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កាលពីដើមឡើយ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្ថិតនៅក្រោមនាយកដ្ឋានគាំពារបរិស្ថាន ប៉ុន្តែបច្ចុប្បន្នស្ថិតនៅក្រោមរដ្ឋមន្ត្រីក្រសួងបរិស្ថានផ្ទាល់តែម្តង។ នៅក្នុងរចនាសម្ព័ន្ធនាយកដ្ឋានគ្រប់គ្រងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានការិយាល័យចំណុះចំនួន១០(ដប់)ការិយាល័យ មានដូចជា៖[25]

- ការិយាល័យ រដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យនីតិកម្ម
- ការិយាល័យស្រាវជ្រាវ និងបណ្តុះបណ្តាល
- ការិយាល័យចូលរួមសាធារណៈ
- ការិយាល័យមូលនិធិបរិស្ថាន និងសង្គម
- ការិយាល័យពិនិត្យគម្រោងឧស្សាហកម្ម និងសុខាភិបាល
- ការិយាល័យពិនិត្យគម្រោងរ៉ែ និងថាមពល
- ការិយាល័យពិនិត្យគម្រោងកសិកម្ម និងធនធានទឹក
- ការិយាល័យពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍
- ការិយាល័យអង្កេតតាមដានគម្រោង។




*(ដកស្រង់រូបភាពពីឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៣៦ ប្រក.បស្ត ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃការិយាល័យចំណុះឲ្យនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)*

[25] ក្រសួងបរិស្ថាន ,https://www.moe.gov.kh/ ។ បានដកស្រង់ ១០ មិថុនា ២០២៤

### ២.២.៦ តួនាទីរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

យោងតាមអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសេនាធិការឲ្យក្រសួងបរិស្ថាន ក្នុងកិច្ចការពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម[26]៖

- រៀបចំសេចក្តីព្រាងនិងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំ និងអនុវត្តវិធានផ្ទៃក្នុងសម្រាប់គ្រប់គ្រងការពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វិភាគ និងវាយតម្លៃសម្រាប់កំណត់ទីតាំងគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន
- ពិនិត្យ និងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន
- កំណត់លក្ខខណ្ឌការងារ និងគោលការណ៍បច្ចេកទេសសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង កិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាន និងសង្គម
- ពិនិត្យ និងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យ និងរៀបចំកិច្ចសន្យាការពារបរិស្ថាននិងផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន

[26] មាត្រា៥៥ អនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ។ ចូលអាន ១២ មិថុនា ២០២៤

- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជនជំរុញការអនុវត្តការបង់សេវាការងារសាធារណៈ មូលនិធិទាយជ្ជទានបរិស្ថាន និងថវិកាពិន័យអន្តរការណ៍
- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តការប្រមូល និងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម
- គ្រប់គ្រង ទទួលខុសត្រូវ និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ ផែនការថវិការយៈពេលខ្លី មធ្យម និងវែង និងអង្កេតតាមដានការងារផ្ទៃក្នុងរបស់នាយកដ្ឋាន
- ជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជន និងការទទួលបានព័ត៌មាននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- កំណត់នីតិវិធីនិងលក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- សម្របសម្រួលការងារជាមួយបណ្តាអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថាន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំពេញភារកិច្ចពង្រឹងសមត្ថភាពជំនាញការងារវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដល់អង្គភាពថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូរអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍ និងភាគីពាក់ព័ន្ធ
- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចដំណើរការវាយ តម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗ ទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

## ២.៣ ផលប៉ះពាល់បរិស្ថានមកលើកម្ពុជា

កំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កំពុងបង្កឱ្យមានការបំពុលបរិស្ថាននៅកម្ពុជា។ ការបំពុលបរិស្ថាន គឺជាការធ្វើឱ្យកខ្វក់ដល់បរិស្ថានដោយសំណល់ផ្សេងៗ ដែលដែលទុកដាក់មិនបានត្រឹមត្រូវ។ សំណល់ដែលទុកដាក់មិនបានត្រឹមត្រូវអាចធ្វើឱ្យមានការ បំពុលផ្សេងៗមកលើភពផែនដីយើង។ វាគឺជាសកម្មភាពរបស់មនុស្សដែលបណ្តាលឱ្យមានសំណល់កើនឡើង ហើយសំណល់ទាំងនោះឯងដែល

បណ្តាលឱ្យមានការបំពុល។ នៅពេលដែលមានការបំពុលនេះកើតឡើង បរិស្ថានក៏ក្លាយទៅជាកខ្វក់មិនមានផាសុខភាព ហើយវានឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខមនុស្ស សត្វ និងរុក្ខជាតិ ដែលកំពុងរស់នៅក្នុងបរិស្ថាន។[27]

នៅក្នុងប្រទេសកម្ពុជា មានជីវៈចម្រុះដ៏សម្បូរបែប រួមមាន សត្វ និងរុក្ខជាតិចម្រុះជាច្រើនប្រភេទ និងមានធនធានព្រៃឈើ ដែលប្រជាជនក្រីក្រជាច្រើននៅតាមជនបទពឹងពាក់អាស្រ័យលើសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេ។ ទោះជាយ៉ាងណា ប៉ុន្មានឆ្នាំចុងក្រោយនេះធនធានព្រៃឈើកាន់តែស្ថិតក្រោមសម្ពាធពីការប្រើប្រាស់ដីសេដ្ឋកិច្ចខ្លាំងឡើងៗ។ ទន្ទឹមនឹងនោះ ប្រទេសកម្ពុជា ជាប្រទេសងាយរងគ្រោះទៅនឹងផលប៉ះពាល់ នៃបម្រែបម្រួលអាកាសធាតុដោយសារតែសមត្ថភាពនៃការបន្សាំនៅទាប។ ប្រជាជននៅតាមជនបទភាគច្រើនស្ថិតនៅក្នុងហានិភ័យដោយសារតែព្រឹត្តិការណ៍អាកាសធាតុបំផ្លិចបំផ្លាញ ជាពិសេស ទឹកជំនន់ និងគ្រោះរាំងស្ងួត។[28]

ក្រៅពីនេះក៏មានបញ្ហាមួយចំនួនដែលកើតមានឡើងនៅកម្ពុជាផងដែរ។ បញ្ហាទាំងនោះមានដូចជាការបំពុលខ្យល់ ការបំពុលទឹក កាកសំណល់រឹង និងបម្រែបម្រួលអាកាសធាតុ។

### ២.៣.១ ការបំពុលខ្យល់

ផ្សែង និងឧស្ម័នដែលកើតឡើងពីការដុតពីយានយន្ត ពីរោងចក្រទាំងឡាយផ្ទុកទៅដោយសារធាតុគ្រោះថ្នាក់ត្រូវបានបញ្ចេញចោលទៅក្នុងខ្យល់ ហើយធ្វើឱ្យខ្យល់មានភាពកខ្វក់ ឬហៅថា ការបំពុលខ្យល់។ ឧទាហរណ៍៖ នៅពេលយើងដុតថង់ប្លាស្ទិច ផ្សែងដែលហុយឡើងទៅក្នុងអាកាសនោះពោរពេញទៅដោយសារធាតុគីមីបំពុល ដែលមានគ្រោះថ្នាក់ដល់ការដកដង្ហើម។ ផ្សែងពណ៌ខ្មៅដែលភាយឡើងទៅក្នុងអាកាស គឺផ្សំឡើងដោយផ្នែកដែលតូចល្អិតរាប់លាន។ ផ្នែកតូចល្អិតនោះជួនកាលស្ថិតក្នុងអាកាសជាច្រើនម៉ោង ហើយអាចបណ្តាលឱ្យពិបាកដកដង្ហើម។ ផ្សែងដែលបញ្ចេញចោលពីរថយន្ត និងម៉ូតូគ្រប់ប្រភេទក៏អាចបណ្តាលឱ្យមានការបំពុលខ្យល់ផងដែរ។

ការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាស៊ូត និងធ្យូងសម្រាប់ការដឹកជញ្ជូន ការប្រើប្រាស់តាមផ្ទះ និងការប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាស ដែលបង្កឱ្យមានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពរបស់មនុស្ស។

[27] សៀវភៅស្តីពីការអប់រំបរិស្ថាន និងអភិរក្សសត្វក្រៀល។ ចូលអាន ០១ កក្កដា ២០២៤

[28] កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ចូលអាន ០១ កក្កដា ២០២៤

ទោះបីជាប្រទេសកម្ពុជាមិនមែនជាប្រទេសដែលមានឧស្សាហកម្មជឿនលឿនខ្លាំងក៏ដោយ កម្ពុជាស្ថិតក្នុងលំដាប់ទី១៦៤ក្នុងចំណោម១៨០ប្រទេស នៅក្នុងសន្ទស្សន៍នៃការអនុវត្តខាង បរិស្ថាន (EPI) សម្រាប់គុណភាពខ្យល់ ក្នុងឆ្នាំ២០១៨។ សន្ទស្សន៍ EPI សម្រាប់ការវាស់ស្ទង់ គុណភាពខ្យល់ ដែលត្រូវបានបង្កើតឡើងដោយសាកលវិទ្យាល័យYale (វិទ្យាស្ថានYale សម្រាប់ គោលនយោបាយ និងច្បាប់បរិស្ថាន) និងសាកលវិទ្យាល័យ Columbia (វិទ្យាស្ថានសម្រាប់ បណ្ដាញនៃព័ត៌មានវិទ្យាសាស្ត្រផែនដីអន្តរជាតិ) ក្នុងកិច្ចសហប្រតិបត្តិការជាមួយវេទិកាសេដ្ឋកិច្ច ពិភពលោកបានរួមបញ្ចូលនូវសូចនាករចំនួន ៣៖[29]

- ការបំពុលខ្យល់ នៅកម្រិតប៉ះពាល់ជាមធ្យមស្មើ PM2.5 (ភាគល្អិតនិចល)
- ការបំពុលខ្យល់ នៅកម្រិតលើសពី PM2.5
- គុណភាពខ្យល់នៅតាមគេហដ្ឋាន។

PM2.5 គឺជាភាគល្អិតនិចលតូចៗនៅក្នុងខ្យល់ ដែលមានអង្កត់ផ្ចិតតូចជាង ២.៥មីក្រុង ឬប្រហែល៣ភាគរយនៃអង្កត់ផ្ចិតរបស់សក់មួយសរសៃ។ ភាគល្អិតទាំងនេះមានគ្រោះថ្នាក់ណាស់ ដែលអាចបង្កគ្រោះថ្នាក់ដូចជា ធ្វើអោយខូចប្រព័ន្ធដកដង្ហើម បំផ្លាញបរិស្ថាន បំផ្លាញស្រទាប់អូហ្សូន បំផ្លាញជីវមានជីវិត បំផ្លាញសុខភាព និងធ្វើឱ្យមានជំងឺផ្សេងៗ ដូចជាជំងឺសួត ជំងឺសើរស្បែក ជំងឺភ្នែក បំពង់ក ខួរក្បាល និងធ្វើឱ្យចុះខ្សោយប្រព័ន្ធរាងកាយ និងសម្ថភាពនៃបញ្ញាស្មារតី។

យោងតាមទិន្នន័យតាមដានគុណភាពខ្យល់របស់ក្រសួងបរិស្ថានបានបង្ហាញថា នៅទីក្រុងភ្នំពេញជារៀងរាល់ឆ្នាំកំហាប់ PM2.5 ជាមធ្យមមានកើនឡើងពី១៣.៥៩µg/m³ ក្នុងឆ្នាំ២០១៧ និង១៩.២៦ µg/m³ ក្នុងឆ្នាំ២០១៨ ហើយវាបានកើនឡើងដល់ ២១.១២ µg/m³ ក្នុងឆ្នាំ២០១៩ ។ បើទោះបីជាកំហាប់ភាគល្អិតនិចលស្ថិតក្រោមបន្ទាត់ស្តង់ដាជាតិ (២៥ µg/m³) ក៏ដោយ ប៉ុន្តែនិន្នាការនៃការកើនឡើងកំហាប់សារធាតុបំពុលខ្យល់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងបរិយាកាសគឺមានកម្រិតគួរឱ្យកត់សម្គាល់ ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចាត់វិធានការកាត់បន្ថយ។ ការបំពុលខ្យល់បណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើនចំពោះសុខភាពសាធារណៈ បរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចនៅទីក្រុងភ្នំពេញ។ ប្រភពនៃការបំពុលខ្យល់មានការកើនឡើងជាលំដាប់ ក្នុងនោះមានដូចជា សកម្មភាពរោងចក្រ ឧស្សាហកម្ម ពាណិជ្ជកម្ម មធ្យោបាយធ្វើដំណើរ ទេសចរណ៍ ការប្រើប្រាស់ថាមពលក្នុងដំណើរការផលិតកម្ម សេវាកម្ម លំនៅដ្ឋាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ជាដើម ដែលកត្តាទាំងអស់នេះបណ្តាលឱ្យមានកំណើននៃការបញ្ចេញឧស្ម័នបំពុលបរិយាកាស។

បើតាមមន្ត្រីបច្ចេកទេសក្រសួងបរិស្ថានដែលបានធ្វើការតាមដានគុណភាពខ្យល់ ប្រភពបំពុលសំខាន់ៗ ដែលនាំឱ្យមានការកើនឡើងយ៉ាងខ្លាំងនូវកំហាប់ភាគល្អិត និចលក្នុងខ្យល់ PM2.5 នាដើមរដូវប្រាំងឆ្នាំ២០២០

[29] សន្ទស្សន៍នៃការអនុវត្តខាងបរិស្ថាន (កម្ពុជា៖គុណភាពខ្យល់ឆ្នាំ២០១៨)។ ចូលអាន០១ កក្កដា ២០២៤

ក្នុងរាជធានីភ្នំពេញ គឺបណ្តាលមកពីប្រភពបំពុលសំខាន់ដូចជា៖ ៧០ភាគរយ មកពីការបញ្ចេញ ពីយានយន្ត ប្រើប្រាស់ប្រេងឥន្ធនៈដែលមានកំហាប់ស្ពាន់ធ័រខ្ពស់, ២០ភាគរយ ពីធូលីចេញពីការដ្ឋានសំណង់និងរោងចក្រ លាយបេតុង, ១០ភាគរយ មកពីប្រភពផ្សេងៗរួមមាន ការដុតសំរាមនៅតាមលំនៅឋាន ធូលីដីនៅតាមដងផ្លូវ ការបញ្ចេញពីរោងចក្រ និងសិប្បកម្មជាដើម។[30]

យ៉ាងណាក៏ដោយ ក្រសួងបរិស្ថានបានអះអាងថា ខ្លួននឹងបន្តតាមដានស្ថានភាពគុណភាពខ្យល់នៅតាមទីក្រុងធំៗ ពិសេសនៅក្នុងរាជធានីភ្នំពេញ ដែលជាតំបន់មមាញឹកខ្លាំងក្នុងសកម្មភាពរោងចក្រ ឧស្សាហកម្ម ពាណិជ្ជកម្ម ការធ្វើដំណើរ និងទេសចរណ៍។ ហើយក្រសួងនេះ បានសន្យាថា នឹងជូនដំណឹងដល់សាធារណជន ប្រសិនបើមានភាពមិនប្រក្រតីណាមួយកើតឡើង។[31]

វិធីបង្ការកុំឱ្យមានផលប៉ះពាល់ អគ្គនាយកដ្ឋានគាំពារបរិស្ថាន ក៏បានបង្ហាញដំណោះស្រាយជុំវិញបញ្ហាប្រឈមខាងលើនេះ ដំណោះស្រាយទី១ ដោយជំរុញការអនុវត្តស្តង់ដាប្រេងឥន្ធនៈ និងយានយន្ត តាមចរាចរ ០១ ស.រ ស្តីពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ។ ដំណោះស្រាយទី២ គឺការដាក់វិធានការហាមឃាត់ការដុតសំណល់ដូចជាកម្ទេចកំណាត់ជាដើមនៅក្នុងឡចំហាយដែលមិនអនុវត្តតាមលក្ខណៈបច្ចេកទេស។ ដំណោះស្រាយទី៣ គឺការចាត់វិធានការទប់ស្កាត់ការដុតនៅទីចំហ ដុតសំណល់កសិកម្ម និងភ្លើងឆេះព្រៃការឆេះសំណល់ទីលាន។ ដំណោះស្រាយទី៤ លើកកម្ពស់ការយល់ដឹងដល់រាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋក្នុងទប់ស្កាត់ការបំពុលខ្យល់។

### ២.៣.២ ការបំពុលទឹក

កាលណាមនុស្សបញ្ចេញសំណល់ពីប្រភពផ្សេងៗដូចជាពីលំនៅដ្ឋាន ពីទីក្រុង និងរោងចក្រ ជាដើម ចូលទៅក្នុងបឹងបួ ត្រពាំង ប្រឡាយ ព្រែក ស្ទឹង ទន្លេនានា សមុទ្រ និងមហាសមុទ្រជាដើម វាបណ្តាលឱ្យទឹកទាំងនោះកខ្វក់ ឬមានការបំពុលដល់ទឹក។ ប្រសិនបើមនុស្សដងទឹកនោះទៅផឹក ឬប្រើប្រាស់វានឹងបណ្តាលឱ្យគេមានជំងឺ។

អង្គការ UNICEF បានរកឃើញថា ប្រជាជនកម្ពុជាចំនួន ៦.៣ លាននាក់ ក្នុងចំណោម ១៤.៩ លាននាក់ មិនទាន់មានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់នៅឡើយទេ។ [32] នៅអំឡុងពេលនៃទិវាទឹកពិភពលោកឆ្នាំ២០១៤ អង្គការUNICEF នៅកម្ពុជា បានជំរុញឱ្យរដ្ឋាភិបាលដោយ ផ្តោតជាសំខាន់ពីការផ្គត់ផ្គង់ទឹក

[30] យោងតាម ក្រសួងព័ត៌មាន ចេញផ្សាយ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២០។ ចូលមើល ០១ កក្កដា ២០២៤

[31] យោងតាម EAC News Cambodiaចុះផ្សាយថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ដោយ Hun Sirivadh។ ចូលមើល ០១ កក្កដា ២០២៤

[32] អ៊ុក សៅបូរី. "ប្រហែលពាក់កណ្តាលនៃប្រជាជនកម្ពុជាមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់, ចុះផ្សាយថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤។ ចូលអាន ២៦ មិថុនា ២០២៤

ស្អាតនៅទីជនបទ។ អង្គការនេះក៏បានបញ្ជាក់ផងដែរថាមូលហេតុចម្បង ដែលប្រជាជនកម្ពុជារាប់លាននាក់មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានទឹកស្អាតប្រើប្រាស់គឺបណ្តាលមកពីរដ្ឋាភិបាលបានដាក់ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់អភិវឌ្ឍន៍ជាអាទិភាព ច្រើនជាងនៅទីជនបទ។[33]

ការបំពុលដោយសារធាតុអាសេនិច ត្រូវបានរកឃើញនៅក្នុងទឹកផឹករបស់កម្ពុជាក្នុង កំឡុងពេលនៃការសិក្សាវាយតម្លៃលើគុណភាពទឹកផឹកនៅកម្ពុជាដែលត្រូវបានធ្វើឡើងរួមគ្នា ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល នៅរវាងឆ្នាំ១៩៩៩ និងឆ្នាំ ២០០០។[34] ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពលបានបង្កើតជាស្តង់ដារ គុណភាពទឹកផឹករបស់កម្ពុជាមួយនៅក្នុងឆ្នាំ២០០៤។[35] ជាឧទាហរណ៍ ទឹកផឹកមិនគួរមានផ្ទុកសារធាតុអាសេនិចលើសពី 0.0៥ មីលីក្រាមក្នុងមួយលីត្រនោះទេ។[36]

សារធាតុអាសេនិច ជាធម្មតាអាចត្រូវបានរកឃើញនៅក្នុងទឹកក្រោមដី និងតំបន់អាងទន្លេមេគង្គ។ ខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ និងក្រចេះ ជាបណ្តាខេត្តដែលត្រូវបានរកឃើញថាមានកម្រិតកំហាប់អាសេនិចខ្ពស់បំផុតនៅកម្ពុជា។ ក្នុងចំណោមខេត្តទាំងនេះ ខេត្តកណ្តាល គឺជាខេត្តដែលមានការបំពុលអាសេនិចខ្ពស់ជាងគេបង្អស់។ នៅឆ្នាំ២០១៤ កាសែតភ្នំពេញប៉ុស្តិ៍បានរាយការណ៍ថានៅក្នុងខេត្តកណ្តាល ៣៥% នៃអណ្តូងយកទៅធ្វើសំណាកចំនួនជាង១៥,000 ត្រូវបានរកឃើញថាមានផ្ទុកសារធាតុអាសេនិចខ្ពស់ជាងកម្រិតថ្នាក់ជាតិ0.0៥ មីលីក្រាមក្នុងមួយលីត្រ ហើយអណ្តូងប្រហែល៥៤%មានផ្ទុកអាសេនិចលើសពីកម្រិតស្តង់ដាររបស់អង្គការសុខភាពពិភពលោក ចំនួន0.0១ មីលីក្រាមក្នុងមួយលីត្រ។[37]

ទឹកពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាមនុស្ស និងបរិស្ថានឱ្យមានសុខភាពល្អទោះដោយផ្ទាល់ ឬដោយប្រយោលក្តី។ ការបំពុលដោយអាសេនិចអាចនឹងធ្វើឱ្យប្រជាជនកម្ពុជារាប់លាននាក់ ប្រឈមនឹងគ្រោះថ្នាក់ ប្រសិនបើគ្មានសកម្មភាពណាមួយត្រូវបានអនុវត្ត។

នៅក្នុងសេចក្តីសង្ខេបមួយរបស់អង្គការ UNICEF បានរកឃើញថា ផលប៉ះពាល់នៃសារ ធាតុអាសេនិចដែលបានបង្កឱ្យកើតជំងឺដង្កាត់ផ្សេងៗ ត្រូវបានចងក្រងទុកប្រមាណជាង ៥00ឯកសារ ហើយមានចំនួនអ្នកស្លាប់ និងពិការអវៈយវៈជាច្រើនទៀត។[38]

---

[33] ដូចយោងខាងលើ

[34] UNICEF. "អាសេនិចនៅកម្ពុជា"។ ចូលអាន ២៦ មិថុនា ២០២៤

[35] ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល "ស្តង់ដាគុណភាពទឹកផឹក"។ ចូលអាន ២៦ មិថុនា ២០២៤

[36] ដូចយោងខាងលើ

[37] Barron, Laignee, និង David Sen. "ឃាតករសម្ងាត់ដែលសម្លាប់មនុស្សអស់ជាច្រើន." ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤។ ចូលអាន ២៧ មិថុនា ២០២៤

[38] ដូចយោងខាងលើ

## ច្បាប់ និងបទប្បញ្ញត្តិ

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៩។ នៅក្នុងអនុក្រឹត្យនេះ ចែងថាក្រសួងបរិស្ថានមានតួនាទី និងទំនួលខុសត្រូវក្នុងការដឹកនាំ ត្រួតពិនិត្យ និងរាយការណ៍អំពីសកម្មភាពនានាដែលអាចបណ្តាលឱ្យមានការបំពុលជាយថាហេតុ។ ក្រុមហ៊ុន ឬអង្គភាពនានាដែលបញ្ចេញ ឬដឹកជញ្ជូនសំណល់រាវទៅទីដទៃចាំបាច់ត្រូវសុំការអនុញ្ញាតពី ក្រសួងបរិស្ថានជាមុនសិន។[39]

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកបានចែកប្រភេទប្រភពបំពុលទឹកជាពីរៈ[40]

- ប្រភេទទី១៖ តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណ សំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ម៉ែត្រគូបក្នុងមួយថ្ងៃ។
- ប្រភេទទី២៖ ចាំបាច់តម្រូវឱ្យមានសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុនពេលបញ្ចេញចោល ឬដឹកសំណល់រាវទៅទីដទៃ។

ប្រភពបំពុលច្រើនជាង៦០ប្រភេទ សម្រាប់គម្រោងសាធារណៈ ឬឯកជននានាត្រូវបានដាក់ បញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ នៅក្នុងនោះក៏មានរាប់បញ្ចូលទាំងគម្រោងសម្រាប់ រោងចក្រកែច្នៃផលិតផលអាហារ រោងចក្រកែច្នៃផលិតផលកសិឧស្សាហកម្ម មជ្ឈមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារ ភោជនីយដ្ឋាន មន្ទីរពេទ្យ និងគ្លីនិក ឧស្សាហកម្មធុនស្រាល និងធុនធ្ងន់ ការផលិតឈើ និងក្រដាស ការរុករករ៉ែ រោងចក្រផលិតសារធាតុគីមី រោងចក្រក្រណាត់ និងរោងចក្រថាមពល។[41]

ទោះជាយ៉ាងនេះក្តី ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានរាយការណ៍ពីការលេចឡើងនូវករណីមួយចំនួនដែលទាក់ទងទៅនឹងការបំពុលទឹកដែលមិនទាន់ត្រួតពិនិត្យបានល្អ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ២០១៥ អ្នកភូមិជនជាតិដើមភាគតិចកួយ ដែលមកពីស្រុកថាឡាបរិវ៉ាត់នៅក្នុងខេត្តស្ទឹងត្រែងបានរាយការណ៍ថារោងអារឈើមួយកន្លែងបានបំពុលផ្លូវទឹកក្នុងមូលដ្ឋានរបស់គាត់ ដែលបានធ្វើ ឱ្យប៉ះពាល់ដល់ប្រភពទឹក និងដំណាំ ហើយបានបណ្តាលឱ្យមានជំងឺសើរស្បែកនានាផងដែរ។ វិទ្យុអាស៊ីសេរីបានបញ្ជាក់ដែរថា ទឹកកខ្វក់ត្រូវបានបង្ហូរចូលទៅក្នុងស្ទឹងបឹងបួរដែលជាប្រភពទឹកសម្រាប់ប្រជាជននៅក្នុងតំបន់ប្រើប្រាស់ប្រចាំថ្ងៃរួមមាន សម្រាប់ងូត ទទួលទាន បោកគក់ និងសម្រាប់ធ្វើម្ហូបអាហារផងដែរ។[42]

---

[39] មាត្រា១០ អនុក្រឹត្យលេខ២៧អ.ន.ក្រ.ប.ក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩។ ចូលអាន ២៧ មិថុនា ២០២៤

[40] មាត្រា១១ អនុក្រឹត្យលេខ២៧អ.ន.ក្រ.ប.ក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩។ ចូលអាន ២៧ មិថុនា ២០២៤

[41] ឧបសម្ព័ន្ធទី៣ អនុក្រឹត្យលេខ២៧អ.ន.ក្រ.ប.ក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩។ ចូលអាន ២៧ មិថុនា ២០២៤

[42] ម៉ែន សុធី. "អ្នកភូមិនៅក្នុងខេត្តស្ទឹងត្រែងប្រទេសកម្ពុជានិយាយថា ផ្លូវទឹកត្រូវបានធ្វើឱ្យកខ្វក់ដោយសាររោងអារឈើមួយក្នុងតំបន់." វិទ្យុអាស៊ីសេរី, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥។ ចូលអាន ២៧ មិថុនា ២០២៤

ប្រហាក់ប្រហែលនឹងគ្នានេះដែរ កាលពីដើមឆ្នាំ២០១៦ រោងចក្រកែច្នៃដំឡូងមីក្នុងតំបន់ មួយនៃខេត្ត ប៉ៃលិន ត្រូវបានគេចោទថាជាដើមហេតុដែលនាំឱ្យមានការបំពុលទឹក។ កាសែតភ្នំពេញប៉ុស្តិ៍ បានរាយការណ៍ថា សំណល់នានាដែលចេញមកពីការដាំដុះនេះ បានសម្លាប់សត្វត្រី និងបំពុលទឹកផឹក ហើយក៏បានធ្វើឱ្យប៉ះពាល់ ដល់ប្រជាជនប្រមាណជា៣០០គ្រួសារ នៅក្នុង ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបងផងដែរ។ ជាដំណោះស្រាយ អាជីកម្មនានាបានជីកត្រពាំងក្បែទីតាំងផលិតកម្មរបស់ខ្លួនសម្រាប់បង្ហូរសំណល់ ហើយ ប្រជាជនក្នុងសហគមន៍ត្រូវបានបង្ខំចិត្តទិញទឹកសុទ្ធ ឬជីកអណ្តូងសម្រាប់ប្រើប្រាស់។

### ២.៣.៣ ភាគសំណល់រឹង

រាជធានីភ្នំពេញមានការរីកចម្រើន និងការអភិវឌ្ឍន៍យ៉ាងខ្លាំងនៅក្នុងកំឡុងពេល២ទសវត្សរ៍ចុងក្រោយ នេះ។ អគារខ្ពស់ៗទំនើបៗបានកែប្រែទេសភាពរាជធានី និងផ្លូវដែលធ្លាប់តែពោរពេញទៅដោយម៉ូតូ និងរថយន្ត ជាច្រើន។ ការកើនឡើងនៃការប្រើប្រាស់ និងការកើនឡើងនៃកាកសំណល់បានដើរទៅយ៉ាងព្រមជាមួយគ្នា នឹងការអភិវឌ្ឍន៍ ហើយប្រទេសកម្ពុជាមានភាពយឺតយ៉ាវក្នុងការដោះស្រាយការគ្រប់គ្រងសំណល់រឹងនៅក្នុង រាជធានីភ្នំពេញ។ សហគមន៍ជាច្រើននៅតែមិនទាន់មានការគ្រប់គ្រងសំណល់ ហើយផ្លូវ និងផ្លូវទឹកនៅ តែបន្តមានការចោលសម្រាម និងមានជាតិពុល។ មានវិធីសាស្ត្រជាច្រើនអ្នកដឹកនាំសហគមន៍អាចប្រើប្រាស់ បានសម្រាប់ការតស៊ូមតិ ឬគាំទ្រមតិ ក្នុងការដោះស្រាយការគ្រប់គ្រងកាកសំណល់ និងធ្វើការជាមួយនឹង ក្រុមហ៊ុនគ្រប់គ្រងសម្រាមក្នុងស្រុក។[43]

យោងទៅតាមការសិក្សារបស់កម្មវិធីបរិស្ថានសហប្រជាជាតិ ដែលបានធ្វើឡើងនៅចន្លោះឆ្នាំ២០១៦ និងឆ្នាំ២០១៨ សម្រាមសំណល់រឹងប្រមាណ ៣០០០ តោនត្រូវបានបង្កើតឡើងជារៀងរាល់ថ្ងៃនៅក្នុងរាជធានី ភ្នំពេញ ក្នុងនោះប្រហែល ៥៥,៣% នៃសម្រាមសំណល់រឹងក្រុង មានប្រភពមកពីលំនៅឋាន សណ្ឋាគារ និងផ្ទះសំណាក់(១៦,៧%) ភោជនីយដ្ឋាន(១៣,៨%) ទីផ្សារ(៧,៥%) ហាង(៥,៤%) និងការិយាល័យ (១,៤%)។[44] បើយោងតាមអ្នកនាំពាក្យក្រសួងបរិស្ថាន ទីលានទុកដាក់សម្រាមសំណល់រឹង ភាគច្រើនមិនមានការបែងចែក រវាងសំណល់សរីរាង្គ និងសំណល់អសរីរាង្គឱ្យបានត្រឹមត្រូវនោះទេ។[45]

[43] សៀវភៅណែនាំស្តីអំពីការគ្រប់គ្រងកាកសំណល់សម្រាប់សហគមន៍ក្រីក្រនៅក្នុងទីក្រុង, បានចូលអាននៅខែកក្កដា ឆ្នាំ២០២៤។

[44] កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ, "ស្ថានភាពនៃការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា," ខែមិថុនា ឆ្នាំ ២០១៨, បានចូលអាននៅខែកក្កដា ឆ្នាំ២០២៤។

[45] យុត សុភចរិយា និង Sarah Taguiam, "ការកែលម្អទីលានទុកដាក់សំរាម សំណល់រឹង," ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៥, បានចូលអាននៅខែកក្កដា ឆ្នាំ២០២៤។

បច្ចុប្បន្ននេះ ទីលានទុកដាក់សម្រាមសំណល់រឹង មានច្រើនជាង ១០០ ទីតាំងនៅទូទាំងប្រទេស ដែលភាគច្រើនជាទីលានចំហ។[46] ទីលានទុកដាក់សម្រាមសំណល់រឹងអចិន្ត្រៃយ៍ថ្មីមួយនឹងត្រូវបានសាងសង់ក្នុងរយៈពេលពីរឆ្នាំខាងមុខ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការទុកដាក់សម្រាមសំណល់រឹងក្នុងរាជធានីភ្នំពេញ និងខេត្តកណ្ដាល។

### ២.៣.៤ បម្រែបម្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុ ត្រូវបានផ្តល់និយមន័យថា ជាការបកស្រាយយោងទៅតាមស្ថិតិស្តីអំពីលំនាំអាកាសធាតុដែលមានការប្រែប្រួលក្នុងរយៈពេលវែងមួយ។ ខណៈពេលអាកាសធាតុនៅលើផែនដីបានឆ្លងកាត់អំឡុងពេលនៃការប្រែប្រួលភ័ស្តុតាងតាមបែបវិទ្យាសាស្ត្រសម័យទំនើបបានបង្ហាញថាការកើនឡើង និងបំរែបំរួលធាតុអាកាសដ៏ឆាប់រហ័សកំពុងតែកើតមានឡើងនៅទូទាំងពិភពលោកហើយវាត្រូវបានហៅថា "ការប្រែប្រួលអាកាសធាតុ" ដែលជាលទ្ធផលកើតចេញពីសកម្មភាពរបស់មនុស្សទាក់ទងទៅនឹងការធ្វើឧស្សាហូបនីយកម្ម ការកាប់បំផ្លាញព្រៃឈើ និងបម្រែបម្រួលនៃការប្រើប្រាស់ដី។[47]

ប្រទេសកម្ពុជា ស្ថិតក្នុងចំណាត់ថ្នាក់ជាប្រទេសមួយក្នុងបណ្តាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។[48] របាយការណ៍គម្របព្រៃឈើឆ្នាំ២០១៤ ដែលចេញផ្សាយដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (ODC) បានបង្ហាញពីនិន្នាការដែលកំពុងកើតមានក្នុងការបាត់បង់គម្របព្រៃឈើ ជាពិសេសព្រៃស្រោងនៅទូទាំងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៣ មក។[49] ជាលើកដំបូងហើយ ក្នុងរយៈពេល ៤១ ឆ្នាំកន្លងមកដែលភាគរយនៃគម្របផ្ទៃដីមិនមែនព្រៃ (៤៨.៤ ភាគរយ) មានទំហំធំជាងគម្របព្រៃឈើ (៤៧.៧ ភាគរយ)។[50] គួរបញ្ជាក់ផងដែរថា ការកាប់បំផ្លាញព្រៃឈើដែលមានអត្រាខ្ពស់នឹងរួមចំណែកដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់។

ប្រទេសកម្ពុជា ងាយទទួលរងផលប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ ដោយសារកម្ពុជា ពឹងផ្អែកខ្លាំងលើវិស័យនានាដែលពាក់ព័ន្ធទៅនឹងធាតុអាកាសដូចជា វិស័យកសិកម្ម ដីធ្លី ធនធានទឹក ព្រៃឈើ និងជល

[46] ក្រសួងបរិស្ថាន, "របាយការណ៍ស្ថានភាពបរិស្ថានលើកទីបួន," ខែមេសា ឆ្នាំ២០២១, បានចូលអាននៅខែកក្កដា ឆ្នាំ២០២៤។

[47] របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១, ការកសាងភាពធន់៖ អនាគតរបស់អ្នកជនបទក្នុងការប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ។ ដកស្រង់ ៥ មិថុនា ២០២៤

[48] Arief A. Yusuf, Herminia A. Francisco.ការវិភាគផែនទី. ការកំណត់ផែនទីភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុចំពោះតំបន់អាស៊ីអាគ្នេយ៍. EEPSEA: ២០០៩។ ដកស្រង់ ៥ មិថុនា ២០២៤

[49] "គម្របព្រៃឈើ." អង្គការទិន្នន័យអំពីការអភិវឌ្ឍ. ១០ មេសា ២០១៥។ ដកស្រង់ ៥ មិថុនា ២០២៤

[50] ដូចលេខយោងខាងលើ

ផលជាដើម។[51] ដោយសារកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ជាមួយនឹងលទ្ធភាពឆ្លើយតបនឹងបំរែបំរួលអាកាសធាតុនៅទន់ខ្សោយ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិតនៅឡើយ ហេតុនេះជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ ជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះដទៃទៀត នឹងមានឧបសគ្គក្នុងការដោះស្រាយបញ្ហាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។[52]

យោងតាម ការសិក្សាតាមបែបវិភាគមួយ របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលបានអនុវត្តការព្យាករអាកាសធាតុសម្រាប់ឆ្នាំ២០៥០ ចំពោះសេដ្ឋកិច្ចនៅតំបន់អាងទន្លេមេគង្គនាពេលបច្ចុប្បន្ននេះ បង្ហាញឱ្យឃើញពីការខាតបង់សេដ្ឋកិច្ច ដោយសារការប្រែប្រួលអាកាសធាតុនាពេលអនាគត អាចនឹងកើនរហូតដល់ទៅ ៦១ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅតាមទីជនបទ ក្នុងមនុស្សម្នាក់នៅប្រទេសកម្ពុជា។[53] គួរកត់សម្គាល់ផងដែរថា ការព្យាករអាកាសធាតុឆ្នាំ២០៥០ នឹងប៉ះពាល់ប្រជាជនកម្ពុជាប្រមាណ៧លាននាក់ ដែលប្រកបមុខរបរក្នុងវិស័យកសិកម្ម និងប្រមាណ ២៤០,០០០នាក់ នៅក្នុងវិស័យសំណង់ ដែលបង្កឱ្យមានផលប៉ះពាល់សេដ្ឋកិច្ចសរុបប្រមាណ ១.៥ ពាន់លានដុល្លារសហរដ្ឋអាមេរិក។[54]

រាជរដ្ឋាភិបាលកម្ពុជាបានព្យាករណ៍ថា សីតុណ្ហភាពប្រចាំខែជាមធ្យម នឹងកើនឡើងចន្លោះពី ០.០១៣ អង្សាសេ និងកើនឡើង ០.០៣៦ អង្សាសេក្នុងមួយឆ្នាំ នៅឆ្នាំ២០៩៩។[55]

របាយការណ៍វិភាគអំពីការខូចខាត និងការបាត់បង់ដោយសារគ្រោះមហន្តរាយនៅកម្ពុជា បង្ហាញថា ទឹកជំនន់ប្រមាណ ៤២ភាគរយ, គ្រោះរាំងស្ងួត ១៥ភាគរយ, អគ្គីភ័យ ១៧ភាគរយ, ខ្យល់ព្យុះ ១៤ភាគរយ, រន្ទះបាញ់ ៧ភាគរយ និងការរាតត្បាតកក្តាសត្វចង្រៃ ១ភាគរយ បានកើតឡើងនៅក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០១៣។[56] គួរឱ្យកត់សម្គាល់ផងដែរថា ក្នុងកំឡុងពេលនេះ គ្រោះមហន្តរាយ បានសម្លាប់មនុស្សចំនួន ២,០៥០ នាក់ ហើយការស្លាប់ដោយសារទឹកជំនន់មានប្រមាណ ៥៣ ភាគរយ នៃទិន្នន័យសរុប។[57]

---

[51] ក្រសួងបរិស្ថាន, ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣។ ដកស្រង់ ៥ មិថុនា ២០២៤

[52] ណង ភិរុណ. ការបន្សាំការប្រែប្រួលអាកាសធាតុនិងការចិញ្ចឹមជីវិតក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច៖ ការពិនិត្យឡើងវិញនៃផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនិងការកសាងសមត្ថភាពបន្សាំនៅកម្ពុជា។ ដកស្រង់ ៥ មិថុនា ២០២៤

[53] ការប្រែប្រួលអាកាសធាតុនៅតំបន់អាងទន្លេមេគង្គក្រោម. ញូវយ៉ក៖ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ ដកស្រង់ ៥ មិថុនា ២០២៤

[54] ដូចលេខយោងខាងលើ

[55] ក្រសួងបរិស្ថាន,ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣.។ ដកស្រង់ ៥ មិថុនា ២០២៤

[56] គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅកម្ពុជា។ ដកស្រង់ ៥ មិថុនា ២០២៤

[57] គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅកម្ពុជា។ ដកស្រង់ ៥ មិថុនា ២០២៤

# ជំពូកទី៣
# ការវិភាគ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ៣.១ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា

ម្ចាស់គម្រោងអាចមានសិទ្ធិក្នុងការជ្រើសរើសក្នុងការសរសេររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបានក្នុងនោះមានពីរជម្រើសក្នុងការជ្រើសរើស។

- ទីមួយ ម្ចាស់គម្រោងអាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។
- ទីពីរ ករណីម្ចាស់គម្រោងអាចសរសេររបាយការណ៍ដោយខ្លួនឯងផ្ទាល់បាននោះ ក្រុមសរសេររបាយការណ៍ត្រូវតែមានសមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍ ដោយត្រូវមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។[58]

ចំពោះក្រុមហ៊ុនទីប្រឹក្សាទាំងឡាយដែលមានបំណងធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមតម្រូវឱ្យដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន។ សម្រាប់ក្រុមហ៊ុនទីប្រឹក្សាទាំងឡាយណាដែលមិនបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថានទេ មិនអាចធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបានឡើយ។[59] ហើយក្រសួងបរិស្ថានក៏បានកំណត់នូវលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមហ៊ុនទីប្រឹក្សាក្នុងគោលបំណងដើម្បីឱ្យក្រុមហ៊ុនទីប្រឹក្សានោះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ មិនតែប៉ុណ្ណោះក្រុមហ៊ុនទីប្រឹក្សា ត្រូវបង់ថ្លៃសេវាចុះបញ្ជីដល់ក្រសួងបរិស្ថាន។ ថ្លៃសេវានេះត្រូវបានកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[60] ចំណែកឯក្រុមហ៊ុនទីប្រឹក្សា

[58] ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ៣៧៦ ប្រ.ក.ប.ស្ត ចុះថ្ងៃទី០២ កញ្ញា ២០០៩,ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងពេញលេញ។ បានអាន០២ កក្កដា ២០២៤

[59] ប្រការ២ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

[60] ប្រការ៩ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

បរទេសវិញ ត្រូវតែសហការជាមួយក្រុមហ៊ុនទីប្រឹក្សាក្នុងស្រុកដែលបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។[61]

### ៣.១.១ លក្ខណៈវិនិច្ឆ័យ

ក្រុមហ៊ុនទីប្រឹក្សាត្រូវមាននាយកក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងជំនួយការបច្ចេកទេស។ ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពទាំងនេះ ក្រុមហ៊ុនទីប្រឹក្សា ត្រូវជូនដំណឹងមកក្រសួងបរិស្ថានត្រឹមរយៈពេលយ៉ាងយូរបំផុត៣០(សាមសិប)ថ្ងៃ។[62]

ចំពោះលក្ខណៈវិនិច្ឆ័យត្រូវមានដូចតទៅ៖[63]

- នាយកក្រុមហ៊ុនទីប្រឹក្សា
  - មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
  - មានបទពិសោធន៍ក្នុងការគ្រប់គ្រងទូទៅ ឬបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម យ៉ាងតិច០៥(ប្រាំ)ឆ្នាំ និងធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសិលា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។
- ប្រធានក្រុមបច្ចេកទេស
  - មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់សមមូលផ្នែកវិទ្យាសាស្ត្រ
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច០៥(ប្រាំ)ឆ្នាំ
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច០៥(ប្រាំ)ឆ្នាំ
  - មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផលសំណង់។ល។
- អ្នកជំនាញការបច្ចេកទេស
  - មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច០៣(បី)ឆ្នាំ
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច០៣(បី)ឆ្នាំ

---

[61] ប្រការ១១ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ក ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

[62] ប្រការ៨ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ក ចុះថ្ងៃទី១៩ ឧសភា ២០២៣,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

[63] ប្រការ៥ ប្រការ៦ ប្រការ៧ និងប្រការ៨ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ក ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផលសំណង់។ល។

- ជំនួយការបច្ចេកទេស
  - មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបរិស្ថានយ៉ាងតិច០១(មួយ)ឆ្នាំ
  - មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
  - មានការយល់ដឹងទូទៅស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បទដ្ឋានច្បាប់ និងបច្ចេកទេសនានាពាក់ព័ន្ធនឹងបរិស្ថាន។

### ៣.១.២ លក្ខខណ្ឌដែលក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញ

បន្ទាប់ពីលក្ខណៈវិនិច្ឆ័យខាងលើដើម្បីបានចុះបញ្ជី និងទទួលស្គាល់ពីក្រសួងបរិស្ថានក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖[64]

- ពាក្យស្នើសុំ ០៣ច្បាប់
- លិខិតចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ០៣ច្បាប់
- លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុនដោយអាជ្ញាធរមូលដ្ឋាន ០៣ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន ០៣ច្បាប់
- រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ០៣ច្បាប់
- សាវតាក្រុមហ៊ុន ០៣ច្បាប់
- ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ផ្សេងៗ។

ក្រសួងបរិស្ថាននឹងផ្តល់វិញ្ញាបនបត្រទទួលស្គាល់ ដែលមានសុពលភាពសម្រាប់រយៈពេល ០៥ឆ្នាំដល់ក្រុមហ៊ុនទីប្រឹក្សា ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដូចខាងលើ។[65]

[64] ប្រការ៣ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

[65] ប្រការ១០ នៃប្រកាសលេខ២១៥ ប្រ.ក.ប.ស្ត ចុះថ្ងៃទី១៩ ឧសភា ២០១៤,ស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ បានអាន០២ កក្កដា ២០២៤

### ៣.១.៣ ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

តារាង១៖ បញ្ជីឈ្មោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

| ល.រ | ឈ្មោះ | លិខិតអនុញ្ញាត | | |
|---|---|---|---|---|
| | | លេខ | | កាលបរិច្ឆេទ |
| ១ | ក្រុមហ៊ុន អ៊ែរសេសមិន & សឺលូសិន ឯ.ក | 204 | សជណ.បស្ថ | 17-02-2019 |
| ២ | ក្រុមហ៊ុន ស៊ី អ៊ី អេស | 1072 | សជណ.បស្ថ | 26-08-2019 |
| ៣ | ក្រុមហ៊ុន ភីភីអាយស៊ី ខូ អិលធីឌី | 1073 | សជណ.បស្ថ | 26-08-2019 |
| ៤ | ក្រុមហ៊ុន អ៊ី & អេ ខនសាស់ធេន | 1223 | សជណ.បស្ថ | 20-09-2019 |
| ៥ | ក្រុមហ៊ុន SBK RESEARCH AND DEVELOPMENT CO.,LTD. | 1227 | សជណ.បស្ថ | 23-09-2019 |
| ៦ | ក្រុមហ៊ុន អស៊ីប៊ីស៊ីស៊ី ខូ អិលធីឌី | 1201 | សជណ.បស្ថ | 16-08-2019 |
| ៧ | ក្រុមហ៊ុន អ៊ិនវ៉ាយរ៉ូថេក សឺវីស | 1613 | សជណ.បស្ថ | 23-12-2019 |
| ៨ | ក្រុមហ៊ុន អ៊ីអ៊ីអេ ខនសាល់ថេសិន សឺវីស ឯ.ក | 1538 | សជណ.បស្ថ | 03-12-2019 |
| ៩ | ក្រុមហ៊ុន KEY CONSULTANTS(CAMBODIA) LTD. | 1664 | សជណ.បស្ថ | 31-12-2019 |
| ១០ | ក្រុមហ៊ុន ខេមបូ ខនសាស់ធេន អ៊ិនធើណេសិនណល (ស៊ីស៊ីអាយ) | 1665 | សជណ.បស្ថ | 31-12-2019 |
| ១១ | ក្រុមហ៊ុន CREATIVE GREEN RESEARCH CO.,LTD. | 1666 | សជណ.បស្ថ | 31-12-2019 |
| ១២ | ក្រុមហ៊ុន SUSTINAT GREEN CO.,LTD. | 1667 | សជណ.បស្ថ | 31-12-2019 |
| ១៣ | ក្រុមហ៊ុន SAWAC CONSULTANTS (CAMBODIA) CO,.LTD | 1276 | សជណ.បស្ថ | 07-10-2019 |
| ១៤ | ក្រុមហ៊ុន ព្រៃក្ដួច ឌីវេឡុបមិន ខនសាល់ធេនស៊ី | 137 | សជណ.បស្ថ | 10-02-2020 |
| ១៥ | ក្រុមហ៊ុន អធីអឹម ហ្គ្រីន ខនសាស់ធេនស៊ី ឯ.ក | 409 | សជណ.បស្ថ | 31-03-2020 |
| ១៦ | ក្រុមហ៊ុន ERD CONSULTANT CO.,LTD. | 176 | សជណ.បស្ថ | 10-02-2020 |
| ១៧ | ក្រុមហ៊ុន BEETLE ENVIRONMENTAL SOLUTIONS CO.,LTD | 1123 | សជណ.បស្ថ | 31-08-2020 |
| ១៨ | ក្រុមហ៊ុន អាយមេកស៍ (ខេមបូឌា) ឯ.ក | 1352 | សជណ.បស្ថ | 19-10-2020 |
| ១៩ | ក្រុមហ៊ុន ហ្គ្រីនប៉ែឡឺនស៍ អ៊ិនវ៉ាយរ៉ិនមិនថល ខលសាស់ធីង ឯ.ក | 1351 | សជណ.បស្ថ | 19-10-2020 |
| ២០ | ក្រុមហ៊ុន ជីឌី ខនសាស់ធេនស៊ី ឯ.ក | 1582 | សជណ.បស្ថ | 24-11-2020 |
| ២១ | ក្រុមហ៊ុន វីប៊ី ខនសាស់ធេនស៊ី ឯ.ក | 147 | សជណ.បស្ថ | 28-01-2021 |

| | | | | |
|---|---|---|---|---|
| ២២ | ក្រុមហ៊ុន ចុងជីន អ៊ិនវ៉ាយរិនមិនថល ថេកណូឡជី ឯ.ក | 359 | សជណ.បស្ថ | 10-03-2021 |
| ២៣ | ក្រុមហ៊ុន អអ៊ី អ៊ីននើវេសិន ខនសាស់ធេនស៊ី ឯ.ក | 1302 | សជណ.បស្ថ | 27-09-2021 |

*(ដកស្រង់ពីសៀវភៅកម្រងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរៀបចំដោយ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន)*

## ៣.២ ប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នៅក្នុងប្រភេទនៃគម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានបែងចែកជាវិស័យផ្សេងៗគ្នា មានដូចជា៖

- វិស័យឧស្សាហកម្ម និងសុខាភិបាល
- វិស័យរ៉ែ និងថាមពល
- វិស័យធនធានទឹក និងកសិកម្ម
- វិស័យទេសចរណ៍ និងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

តារាង២៖ ចំណាត់ថ្នាក់គម្រោងដែលតម្រូវឱ្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទគម្រោង | ទំហំគម្រោង |
|---|---|---|
| **ក. វិស័យឧស្សាហកម្ម** | | |
| ១ | រោងចក្រកាត់ដេរ ចាក់ ប៉ាក់ សម្លៀកបំពាក់ | គ្រប់ទំហំ |
| ២ | រោងចក្រផលិតសំឡី | គ្រប់ទំហំ |
| ៣ | រោងចក្រផលិតឆ័ត្រ អាវភ្លៀង | គ្រប់ទំហំ |
| ៤ | រោងចក្រផលិតស្បែកជើង គ្រឿងបន្សំស្បែកជើង | គ្រប់ទំហំ |
| ៥ | រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក | គ្រប់ទំហំ |
| ៦ | រោងចក្រផ្សំអនាម័យ | គ្រប់ទំហំ |
| ៧ | រោងចក្រផលិតចាន ឆ្នាំង កែវ សម្ភារៈប្រើប្រាស់ផ្ទះបាយ | គ្រប់ទំហំ |
| ៨ | រោងចក្រផលិតទឹកសុទ្ធ | គ្រប់ទំហំ |
| ៩ | រោងចក្រផលិតក្រដាសអនាម័យពាក់កណ្តាលសម្រេច | គ្រប់ទំហំ |
| ១០ | រោងចក្រធ្វើរានទេវតា គ្រឿងបង្គុំទឹកសក្ការៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១១ | រោងចក្រផលិតបារី | គ្រប់ទំហំ |
| ១២ | រោងចក្រផលិតគ្រឿងបន្សំសម្លៀកបំពាក់ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១៣ | រោងចក្រសម្ងួតគ្រាប់ធញ្ញជាតិ | គ្រប់ទំហំ |
| ១៤ | រោងចក្រផលិតកាបូប គ្រឿងបន្សំកាបូបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៥ | រោងចក្រផលិតខ្សែយឺតចង្កេះខោសម្រាប់ផ្គត់ផ្គង់ | គ្រប់ទំហំ |
| ១៦ | រោងចក្រផលិតអំបោះ ខារអំបោះដេរ ផលិតស្កុតបិត | គ្រប់ទំហំ |
| ១៧ | រោងចក្រផលិតខ្សែក្រវ៉ាត់គ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៨ | រោងចក្រផលិតកេសកាតុង និងសម្ភារៈវេចខ្ចប់គ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៩ | រោងចក្រផលិតឡេវ ខ្សែរូតគ្រប់ប្រភេទ | គ្រប់ទំហំ |
| ២០ | រោងចក្រផលិតសម្ភារៈស្នូចត្រីគ្រប់ប្រភេទ | គ្រប់ទំហំ |
| ២១ | រោងចក្រផលិតទឹកត្រី ស៊ីអ៊ីវ សៀង ម្ទេស ប៉េងប៉ោះ | គ្រប់ទំហំ |
| ២២ | មូលដ្ឋានផលិតអាល់គុល | គ្រប់ទំហំ |
| ២៣ | មូលដ្ឋានផលិតភេសជ្ជៈ ទឹកក្រូច ទឹកផ្លែឈើគ្រប់មុខប្រភេទ | គ្រប់ទំហំ |
| ២៤ | មូលដ្ឋានផលិតគ្រឿងសង្ហារឹម | គ្រប់ទំហំ |
| ២៥ | មូលដ្ឋានផលិតម្សៅអង្ករ | គ្រប់ទំហំ |
| ២៦ | មូលដ្ឋានផលិតឥដ្ឋ ក្បឿង ឥដ្ឋក្រាល ឥដ្ឋការ៉ូ | គ្រប់ទំហំ |
| ២៧ | មូលដ្ឋានផលិតអំបិល កែច្នៃអំបិល | គ្រប់ទំហំ |
| ២៨ | មូលដ្ឋានផលិតចំណីសត្វ | គ្រប់ទំហំ |
| ២៩ | មូលដ្ឋានកែច្នៃសំណល់ទីប្រជុំ | គ្រប់ទំហំ |
| **ខ.វិស័យកសិកម្ម** | | |
| ៣០ | ប្រព័ន្ធស្រោចស្រព | <១ ០០០ហិចតា |
| ៣១ | ប្រព័ន្ធដោះទឹក | <១ ០០០ហិចតា |
| ៣២ | ផ្ទៃដីកសិ-ឧស្សាហកម្ម (ដីមិនមានគម្របព្រៃឈើ) | ≤១ ០០០ហិចតា |
| ៣៣ | កសិដ្ឋានចិញ្ចឹមសត្វពាហនៈ (គោ ក្របី សេះ ជ្រូក ពពែ ចៀម) | ២០ក្បាល-៥០០ក្បាល |
| ៣៤ | កសិដ្ឋានចិញ្ចឹមសត្វស្លាប | ២ ០០០-៥០ ០០០ក្បាល |
| ៣៥ | កសិដ្ឋានចិញ្ចឹមសត្វល្មូន | ១០០ក្បាល-១០ហិកតា |
| ៣៦ | វារីវប្បកម្មទឹកសាប ទឹកប្រៃ | ១ហិកតា-១០ហិកតា |
| ៣៧ | ទីសត្តឃាត | គ្រប់ទំហំ |

| | | |
|---|---|---|
| ៣៨ | មូលដ្ឋានស្តុក និងលក់ថ្នាំកសិកម្ម | <១០.០០០តោន/១ឆ្នាំ |
| ៣៩ | កសិដ្ឋានចិញ្ចឹមសត្វស្វា ទោច ទន្សាយ | ១០០ក្បាល-១.០០០ក្បាល |
| ៤០ | កសិដ្ឋានចិញ្ចឹមមសត្វល្អិត | គ្រប់ទំហំ |
| ៤១ | អាជីវកម្មផ្ទះត្រចៀងកាំ | គ្រប់ទំហំ |
| ៤២ | កសិដ្ឋានដាំដំណាំក្នុងផ្ទះសំណាញ់ | គ្រប់ទំហំ |
| **គ.វិស័យសុខាភិបាល** | | |
| ៤៣ | មន្ទីរ ឬបន្ទប់ពិគ្រោះ និងព្យាបាលជម្ងឺ | គ្រប់ទំហំ |
| ៤៤ | មន្ទីរពេទ្យបង្អែកស្រុក | គ្រប់ទំហំ |
| ៤៥ | មណ្ឌលលាងឈាម | គ្រប់ទំហំ |
| ៤៦ | មន្ទីរពហុព្យាបាល មន្ទីរព្យាបាល សម្ភព | គ្រប់ទំហំ |
| ៤៧ | មណ្ឌលសុខភាព | គ្រប់ទំហំ |
| ៤៨ | ឃ្លាំងឱសថ | ផ្ទៃក្រឡាសំណង់≤៣០០០ ម៉ែត្រការ៉េ |
| ៤៩ | សិប្បកម្មផលិតថ្នាំពេទ្យ និងបរិក្ខាពេទ្យ | គ្រប់ទំហំ |
| ៥០ | មូលដ្ឋានកែច្នៃសំណល់វេជ្ជសាស្ត្រ | គ្រប់ទំហំ |
| **ឃ.វិស័យទេសចរណ៍** | | |
| ៥១ | តំបន់ទេសចរណ៍(ក្រៅពីតំបន់ការពារធម្មជាតិ តំបន់បេតិកភណ្ឌ តំបន់កោះ) | <១០ហិកតា |
| ៥២ | អាជីវកម្មខារ៉ាអូខេ រង្គសាល បៀរហ្គាដេន និងឌីស្កូតែក | <៣០០ម៉ែត្រការ៉េ |
| ៥៣ | ទីលាវាយកូនគោល | <១៨ រន្ធ |
| ៥៤ | ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ | គ្រប់ទំហំ |
| ៥៥ | ភោជនីយដ្ឋានបណ្តែនទឹក | គ្រប់ទំហំ |
| ៥៦ | សេវាកម្មទូកទេសចរណ៍ | គ្រប់ទំហំ |
| **ង. វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | |
| ៥៧ | សំណង់អគារ | ៥០០-៣០០០ម៉ែត្រការ៉េ |
| ៥៨ | សណ្ឋាគារ ឬផ្ទះសំណាក់(លើកលែងតែសំណង់នៅក្នុង ឬនៅជាប់តំបន់ការពារធម្មជាតិ តំបន់បេតិកភណ្ឌ តំបន់ឆ្នេរ តំបន់មាត់ទន្លេ តំបន់កោះ | <១០០បន្ទប់ |

| | | |
|---|---|---|
| ៥៩ | សំណង់ផ្លូវជនបទ ឬផ្លូវខេត្ត | គ្រប់ទំហំ |
| ៦០ | បណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន | គ្រប់ទំហំ |
| ៦១ | បណ្តាញខ្សែកាបអុបទិកលើគោក(ក្រៅតំបន់ការពារធម្មជាតិ) | គ្រប់ទំហំ |
| **ច. វិស័យថាមពល** | | |
| ៦២ | អាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជា ថ្មកំបោរ ថ្មម៉ាប ថ្ម ភក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ ដីឥដ្ឋ ហ្វូស្វាត កៅឡាំង។ល។ និងរ៉ែផ្សេងទៀតដែលមានលក្ខណៈជាសិប្បកម្ម | ≤១ហិកតា និងមានជម្រៅ ≤៥ម៉ែត្រ |
| ៦៣ | មូលដ្ឋានស្តុកខ្សាច់ ថ្ម | គ្រប់ទំហំ |
| ៦៤ | ស្ថានីយប្រេងឥន្ធនៈ ឬដេប៉ូប្រេងឥន្ធនៈ | <៨.០០០លីត្រ |
| ៦៥ | ស្ថានីយស្តុក និងលក់ហ្គាស ឬដេប៉ូស្តុក និងលក់ហ្គាស | <៨.០០០លីត្រ |
| ៦៦ | ខ្សែបញ្ជូនអគ្គិសនីដែលមានតង់ស្យុង | ≤២២KV |
| **ឆ. វិស័យសិប្បកម្មប្រភេទខ្នាតតូច មធ្យម** | | |
| ៦៧ | សិប្បកម្មផលិតទ្វាដែក | គ្រប់ទំហំ |
| ៦៨ | សិប្បកម្មក្រឡឹងគ្រឿងម៉ាស៊ីន | គ្រប់ទំហំ |
| ៦៩ | សិប្បកម្មផលិតក្រដាស | គ្រប់ទំហំ |
| ៧០ | សិប្បកម្មបោះពុម្ពឯកសារ សារព័ត៌មាន | គ្រប់ទំហំ |
| ៧១ | សិប្បកម្មផលិតគ្រឿងសង្ហារឹម | គ្រប់ទំហំ |
| ៧២ | សហគ្រាសជួលជុលគ្រឿងយន្ត | គ្រប់ទំហំ |
| ៧៣ | សិប្បកម្មបកក្តាម បង្គារ | គ្រប់ទំហំ |
| ៧៤ | សិប្បកម្មកែច្នៃថ្មអារ | គ្រប់ទំហំ |
| ៧៥ | សិប្បកម្មអារឈើ | គ្រប់ទំហំ |
| ៧៦ | សិប្បកម្មផលិតទុយោជ័រ | គ្រប់ទំហំ |
| ៧៧ | សិប្បកម្មផលិតស្បោងប្លាស្ទិក និងសម្ភារៈពីប្លាស្ទិក ផលិតធុងជ័រ | គ្រប់ទំហំ |
| ៧៨ | សិប្បកម្មផលិតបារី | គ្រប់ទំហំ |
| ៧៩ | សិប្បកម្មផលិតសសរគ្រឹះ បង្គោលបេតុង ជើងតាង ពាង លូ ឥដ្ឋការ៉ូ | គ្រប់ទំហំ |
| ៨០ | សិប្បកម្មបញ្ចូលអាគុយ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៨១ | សិប្បកម្មហាលកសិផលកសិកម្ម | គ្រប់ទំហំ |
| ៨២ | សិប្បកម្មច្នៃអំបិលអ៊ីយ៉ូត | ≥១០០តោន/ឆ្នាំ |
| ៨៣ | សិប្បកម្មផលិតសាប៊ូទឹក | គ្រប់ទំហំ |
| ៨៤ | សិប្បកម្មផលិតធុងជ័រ | គ្រប់ទំហំ |
| ៨៥ | សិប្បកម្មផលិតទឹកផ្លែឈើកញ្ចប់ | គ្រប់ទំហំ |
| ៨៦ | សិប្បកម្មផលិតក្តាបន្ទះ កុងផ្លាកេ | គ្រប់ទំហំ |
| ៨៧ | សិប្បកម្មផលិតចំណីសត្វ | គ្រប់ទំហំ |
| ៨៨ | សិប្បកម្មផលិតស្រា ស្រាបៀ | គ្រប់ទំហំ |
| ៨៩ | សិប្បកម្មកែច្នៃសម្ភារពីកៅស៊ូ | គ្រប់ទំហំ |
| ៩០ | សិប្បកម្មកាត់ដេរ បោះពុម្ពលើសសម្លៀកបំពាក់ | គ្រប់ទំហំ |
| ៩១ | សិប្បកម្មផលិតទឹកសុទ្ធ | គ្រប់ទំហំ |
| ៩២ | សិប្បកម្មផលិតទឹកស្អាត | គ្រប់ទំហំ |
| ៩៣ | សិប្បកម្មផលិតទឹកកក | គ្រប់ទំហំ |
| ៩៤ | សិប្បកម្មផលិតសសៃគុយទាវ មី នំបញ្ចុក | គ្រប់ទំហំ |
| ៩៥ | សិប្បកម្មផលិតពពុះសណ្តែក | គ្រប់ទំហំ |
| ៩៦ | សិប្បកម្មផលិតទឹកត្រី ទឹកស៊ីអ៊ីវ ទឹកខ្មេះ ទឹកសៀង ទឹកម្ទេស | គ្រប់ទំហំ |
| ៩៧ | សិប្បកម្មផលិតនំ និងស្ករគ្រាប់ | គ្រប់ទំហំ |
| ៩៨ | សិប្បកម្មផលិតនំប៉ុង | គ្រប់ទំហំ |
| ៩៩ | សិប្បកម្មផលិតពូក ខ្នើយ | គ្រប់ទំហំ |
| ១០០ | សិប្បកម្មត្បាញសូត្រក្រម៉ា | គ្រប់ទំហំ |
| ១០១ | សិប្បកម្មកែច្នៃរតនវត្ថុ | គ្រប់ទំហំ |
| ១០២ | សិប្បកម្មផលិតចាន ឆ្នាំង និងសម្ភារផ្ទះបាយ | គ្រប់ទំហំ |
| ១០៣ | សិប្បកម្មផលិតទៀត ធូប | គ្រប់ទំហំ |
| ១០៤ | សិប្បកម្មផលិតឥដ្ឋ ក្បឿង ការ៉ូ | គ្រប់ទំហំ |
| ១០៥ | សិប្បកម្មផលិតចង្ក្រាន | គ្រប់ទំហំ |
| ១០៦ | សិប្បកម្មផលិតប្រេងសណ្តែក និងប្រេងចម្អិតផ្សេងៗ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១០៧ | សិប្បកម្មកិនស្រូវ | <៣០០០តោន/ឆ្នាំ |
| ១០៨ | សិប្បកម្មសង្កត់ពុម្ពស័ង្កសី និងលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១០៩ | សិប្បកម្មកាត់ដេរ ប៉ាក់ វេចខ្ចប់បោះពុម្ពសម្លៀកបំពាក់ | គ្រប់ទំហំ |
| ១១០ | សិប្បកម្មបោះពុម្ពស្បែកជើង | គ្រប់ទំហំ |
| ១១១ | សិប្បកម្មជ្រលក់ពណ៌ និងខាអំបោះ | គ្រប់ទំហំ |
| ១១២ | សិប្បកម្មកែច្នៃកម្ទេចកំណាត់ | គ្រប់ទំហំ |
| ១១៣ | អាជីវកម្មស្តុកស្បែកសត្វ | គ្រប់ទំហំ |
| ១១៤ | សិប្បកម្មផលិតសម្បកទូក និងអូរបរស្មាច់ | គ្រប់ទំហំ |
| ១១៥ | មូលដ្ឋានប្រមូលទិញ និងស្តុកអេតចាយ | គ្រប់ទំហំ |
| ១១៦ | យានដ្ឋានជួសជុលយានយន្ត តោន បាញ់ថ្នាំរថយន្ត | គ្រប់ទំហំ |
| ១១៧ | មូលដ្ឋានយានយន្ត | គ្រប់ទំហំ |

*(ដកស្រង់ពី តារាងឧបសម្ព័ន្ធនៃប្រកាសលេខ ៣៥៦ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន)*

## ៣.៣ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ស្ថាប័នទទួលខុសត្រូវក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺនាយកដ្ឋានអង្កេតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថានតាំងពីឆ្នាំ ១៩៩៤ មកម្លេះ។

តម្រូវការផ្នែកច្បាប់បឋមសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) នៅក្នុងប្រទេសកម្ពុជាត្រូវបានចែងក្នុងមាតិកាទី២ គន្ថីទី៥ នៃក្រមបរិស្ថាន និងធនធានធម្មជាតិ។[66] ជំពូក៣ នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦[67] និងអនុក្រឹត្យលេខ ៧២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)។[68] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងក្នុងមាត្រា ៥៩ ថារដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។[69]

[66] រាជរដ្ឋាភិបាលកម្ពុជា "ក្រមបរិស្ថាន និងធនធានធម្មជាតិ" ។ បានអាន២៥ មិថុនា ២០២៤

[67] ច្បាប់ស្តីពីការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ (មាត្រា ៦ និង ៧)។ បានអាន២៥ មិថុនា ២០២៤

[68] អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ បានអាន២៥ មិថុនា ២០២៤

[69] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ១៩៩៣ (មាត្រា ៥៩)។ បានអាន២៨ មិថុនា ២០២៤

អនុក្រឹត្យស្តីលេខ ៧២ ពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩) តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមួយរាល់គ្រប់គម្រោងសាធារណៈ ឬឯកជន ដែលពាក់ព័ន្ធនឹងសកម្មភាពដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ។ សកម្មភាពទាំងនោះរួមមាន គម្រោងកសិ-ឧស្សាហកម្ម រោងចក្រផ្នែកផលិតផលពីឈើ និងក្រដាស ការរុករករ៉ែ រោងចក្រសារធាតុគីមី វាយនភ័ណ្ឌ រោងចក្រថាមពល ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធជាដើម។ ទោះជាយ៉ាងណា អនុក្រឹត្យនេះមានការលើកលែងលើគម្រោងទាំងឡាយណាដែលមានលក្ខណៈពិសេស និងមានសារៈសំខាន់ខ្លាំង ដែលសម្រេចដោយរាជរដ្ឋាភិបាល ។[70]

### ៣.៣.១ គម្រោងស្នើសុំ

នៅពេលដែលគម្រោងស្នើសុំត្រូវបានតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ អ្នកស្នើគម្រោងត្រូវធ្វើសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ក្នុងដំណាក់កាលដំបូង ម្ចាស់គម្រោង ឬម្ចាស់ក្រុមហ៊ុនវិនិយោគត្រូវលើកយកគម្រោងវិនិយោគរបស់ខ្លួនមកពិភាក្សាជាមួយក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត (ចំពោះគម្រោង ដែលមានទុនវិនិយោគក្រោមពីរលានដុល្លារអាមេរិក) ដោយត្រូវភ្ជាប់មកនូវឯកសារទាក់ទងនឹងទីតាំងគម្រោង និងឯកសារពាក់ព័ន្ធនានា។ [71] នៅក្នុងដំណាក់កាលមួយនេះអ្វីដែលម្ចាស់គម្រោងចង់ដឹងនោះ តើគម្រោងវិនិយោគដែលក្រុមហ៊ុនបានស្នើមកក្រសួងបរិស្ថាន/មន្ទីរបរិស្ថានត្រូវបំពេញកាតព្វកិច្ចច្បាប់អ្វីខ្លះ?

ដូចនេះក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានបានធ្វើការផ្ទៀងផ្ទាត់ និងជ្រើសរើសគម្រោងទៅតាមលក្ខខណ្ឌមួយចំនួនដូចចំណុចនៅខាងក្រោម។

### ៣.៣.២ ការជ្រើសរើសគម្រោង

ជាទូទៅ ការជ្រើសរើសគម្រោងត្រូវបានកំណត់ដោយក្រសួងបរិស្ថានដូចបានបង្ហាញនៅចំណុច ៣.២ ខាងលើ។ ករណីដែលគម្រោងវិនិយោគទាំងនោះមិនមានបញ្ជាក់នៅក្នុងចំណុចខាងលើនេះ ក្រសួងអាចប្រើប្រាស់តារាងកំណត់ទំហំហេតុប៉ះពាល់ជំនួស។ តារាងកំណត់ទំហំនេះបង្ហាញឲ្យដឹងពីគម្រោងមួយត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមិនតម្រូវឲ្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានបញ្ជាក់លម្អិតខាងក្រោមៈ[72]

[70] អនុក្រឹត្យលេខ ៧២ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (មាត្រា ២ និងឧបសម្ព័ន្ធ), បានអាន២៨ មិថុនា ២០២៤

[71] មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ កក្កដា ២០២៤

[72] ដូចយោងខាងលើ

- តម្រូវឱ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញចំពោះគម្រោងដែលមានការប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ឬ
- តម្រូវឱ្យម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងចំពោះគម្រោងដែលមានហេតុប៉ះពាល់បរិស្ថានមធ្យម ឬ
- ពុំតម្រូវឱ្យមានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងទាំងបីប្រភេទដូចខាងក្រោម៖
  ១. គម្រោងដែលរដ្ឋាភិបាលកំណត់ថាជាប្រភេទគម្រោងពិសេស ឬបន្ទាន់
  ២. តម្រូវឱ្យមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន
  ៣. តម្រូវឱ្យរៀបចំកិច្ចសន្យាការពារបរិស្ថានចំពោះគម្រោងដែលមានហេតុប៉ះពាល់អវិជ្ជមានតិចតួច ដូចជារោងចក្រកាត់ដេរសម្លៀកបំពាក់ជាដើម។

### ៣.៣.៣ ការកំណត់វិសាលភាព

ការកំណត់វិសាលភាព គឺជាដំណាក់កាលដំបូងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបន្ទាប់ពីការជ្រើសរើសគម្រោងបានបញ្ចប់។ ដំណាក់កាលកំណត់វិសាលភាពនេះ មានសារៈសំខាន់ណាស់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដើម្បីកំណត់នូវសមាសភាគមួយចំនួនខាងក្រោម៖[73]

- កំណត់ប៉ារ៉ាម៉ែត្រដែលត្រូវសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- កំណត់ និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ
- កំណត់ពីវិសាលភាពនៃការសិក្សា
- ឯកភាពលើវិធីសាស្ត្រនៃការចូលរួមជាសាធារណៈ និងវិធីសាស្ត្រនៃការសិក្សា
- កំណត់ពីសញ្ញាណនៃហេតុប៉ះពាល់ដើម្បីធ្វើការសិក្សា
- បង្កើតឱ្យមានលក្ខខណ្ឌការងារ។

**តើអ្នកណាខ្លះដែលពាក់ព័ន្ធនៅក្នុងដំណាក់កាលកំណត់វិសាលភាពនេះ?**

អ្នកដែលពាក់ព័ន្ធនៅក្នុងការកំណត់ទំហំវិសាលភាព នៃគម្រោងក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានដូចខាងក្រោម៖[74]

- នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន
- ម្ចាស់គម្រោង
- ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអ្នកជំនាញនានា

[73] ដូចយោងខាងលើ

[74] ដូចយោងខាងលើ

- ភ្នាក់ងារទទួលខុសត្រូវផ្សេងៗទៀត
- សាធារណជនដែលទទួលរងការប៉ះពាល់
- សាធារណជនដែលទទួលផលប្រយោជន៍ពីគម្រោង។

### ៣.៣.៤ ការវិភាគហេតុប៉ះពាល់បរិស្ថាន

នៅក្នុងដំណាក់កាលនីមួយៗនៃប្រតិបត្តិការរបស់គម្រោងអភិវឌ្ឍន៍ នឹងមានផលប៉ះពាល់មកលើធនធានរូបវន្ត ធនធានជីវសាស្ត្រ និងធនធានសង្គមសេដ្ឋកិច្ចជាមិនខាន។ ដូច្នេះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសង្គម ត្រូវធ្វើការពិចារណាពីគ្រប់សកម្មភាពពាក់ព័ន្ធនឹងគម្រោងទាំងអស់ ដូចជាបច្ចេកវិទ្យាជាក់លាក់ជាដើម ក្នុងសេចក្ដីពិពណ៌នាសម្រាប់គម្រោងដែលត្រូវបានលើកស្នើឡើង។ ចាំបាច់ត្រូវមានការរៀបចំរបាយការណ៍ឱ្យបានល្អដើម្បីរៀបរាប់ពីផលប៉ះពាល់បង្កឡើងដោយសកម្មភាពរបស់គម្រោង។[75]

នៅក្នុងការវិភាគពីហេតុប៉ះពាល់បរិស្ថាន និងដំណាក់កាលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូងឬពេញលេញគឺតម្រូវអោយមានការវិភាគលើបីចំណុចគឺ៖[76]

១. ការកំណត់ប្រភេទនៃហេតុប៉ះពាល់

២. ការព្យាករណ៍អំពីទំហំដែលកើតមានឡើង និងវិសាលភាពនៃហេតុប៉ះពាល់

៣. ការកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់។

<u>**ចំណាំ**</u>៖ ហេតុប៉ះពាល់បរិស្ថាននាំឱ្យមានការផ្លាស់ប្តូរទម្រង់បរិស្ថានដែលមានស្រាប់ ហើយហេតុប៉ះពាល់ទាំងនោះអាចជាហេតុប៉ះពាល់ដោយផ្ទាល់ និងប្រយោល ឬជាបណ្តុំ។

**ផលប៉ះពាល់ផ្ទាល់៖** គឺផលប៉ះពាល់ដែលកើតមានឡើងនៅពេលតែមួយ និងកន្លែងតែមួយដូចគ្នានឹងសកម្មភាពរបស់គម្រោងដែលត្រូវបានលើកស្នើឡើង។

**ផលប៉ះពាល់ប្រយោល៖** គឺជាផលប៉ះពាល់ដែលកើតមានឡើងនៅក្រោយមកទៀត ឬនៅឆ្ងាយពីសកម្មភាពគម្រោង ដែលត្រូវបានលើកស្នើឡើង។

**បណ្តុះផលប៉ះពាល់៖** គឺជាផលប៉ះពាល់ដែលអាចមានទំហំតូចសម្រាប់គម្រោងណាមួយប៉ុន្តែនៅពេលដែលមានការពិនិត្យបញ្ចូលគ្នាលើគម្រោងដែលអនុវត្តកាលពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ផលប៉ះពាល់អាចមានទំហំគួរឱ្យកត់សម្គាល់។ ជាទូទៅ មានការវិភាគលើផលប៉ះពាល់ផ្ទាល់ និងប្រយោលរួមគ្នា។ ការវិភាគលើបណ្តុះផលប៉ះពាល់ គួរធ្វើឡើងសម្រាប់គ្រប់ធនធានទាំងអស់ ដែលត្រូវបានលើកឡើងថាជាបញ្ហា

[75] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

[76] មគ្គុទ្ទេសក៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ កក្កដា ២០២៤

និងអាចបញ្ចូលគ្នា ដើម្បីកំណត់ជាផលប៉ះពាល់គម្រោងដែលត្រូវបានលើកស្នើឡើង។ ដំណើរការកំណត់វិសាលភាពបឋមនឹងជួយធ្វើការកំណត់រកធនធាន ដែលរងផលប៉ះពាល់ជាបណ្តោះពីសកម្មភាពគម្រោងដែលត្រូវបានលើកស្នើឡើង។

### ៣.៣.៥ វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាសកម្មភាព ឬវិធានការជៀសវាង ឬធ្វើឲ្យមានការថយចុះនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានពីសកម្មភាពគម្រោង។ វិធានការកាត់បន្ថយសំដៅទៅលើប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច សង្គម និងវប្បធម៌។ វិធានការ និងការអនុវត្តគម្រោងអាចរួមបញ្ចូល នូវវិធានការជាច្រើនវិធីសាស្ត្រ ឬជាច្រើនជម្រើសដូចមានរៀបរាប់ខាងក្រោម៖[77]

- ការរៀបចំផែនការលើទីតាំង ឬពេលវេលានៃសកម្មភាព ដើម្បីជៀសវាងឥទ្ធិពលទៅលើធនធានជាក់លាក់មួយ ឬតំបន់ងាយទទួលរងការប៉ះពាល់
- បញ្ចូលនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន នៅក្នុងដំណាក់កាលរចនាគម្រោង ឬធ្វើផែនការ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាមុន
- ធានារ៉ាប់រងលើកម្មវិធីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតមានឡើងទន្ទឹមគ្នាជាមួយគម្រោង
- ធានារ៉ាប់រងលើកម្មវិធីកាត់បន្ថយ បន្ទាប់ពីសកម្មភាពស្តារនូវធនធានដែលប៉ះពាល់ ឬតំបន់ដែលទទួលរងការប៉ះពាល់ ឬជំនួសនូវអ្វីដែលបាត់បង់ ឬធនធានដែលខូចខាតនៅក្នុងតំបន់ រងការប៉ះពាល់ ឬតំបន់នានាដែលពាក់ព័ន្ធ។

**ក. ការកំណត់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន**

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន អាចត្រូវបានកំណត់ក្នុងអំឡុងពេលមុនប្រតិបត្តិគម្រោង (ដំណាក់កាលរចនាគម្រោង និងសាងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង ដោយ ត្រូវពិនិត្យទៅលើកត្តាសំខាន់ៗ ដូចខាងក្រោម៖[78]

- លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ ឬបទពិសោធន៍កន្លងមកផ្តល់ជាវិធានការកាត់បន្ថយដែលត្រូវបានកំណត់ភ្លាមៗនៅក្នុងដំណាក់កាលរចនាគម្រោង និងការវាយតម្លៃនៃគម្រោងស្នើសុំ។

[77] មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ កក្កដា ២០២៤

[78] ដូចយោងខាងលើ

- វិធានការកាត់បន្ថយអាចត្រូវបានបង្កើតឡើងក្នុងការឆ្លើយតបទៅនឹងហេតុប៉ះពាល់ជាក់លាក់ ដែលត្រូវបានកំណត់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងដំណាក់កាលអនុវត្តគម្រោង។
- វិធានការអាចបង្កើតទៅជាការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន រហូតដល់ការបញ្ចប់គម្រោង។

ការធ្វើផែនការដ៏ប្រុងប្រយ័ត្ន និងការអនុវត្តគម្រោងទៅតាមផែនការគ្រប់គ្រងបរិស្ថានអាចកាត់បន្ថយ ឬជៀសវាងហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដល់កម្រិតអប្បបរមា។ ផែនការនេះអាចត្រូវបានប្រតិបត្តិតាម ប្រសិនបើការបង្កើតនូវការកាត់បន្ថយត្រូវបានបញ្ចូលទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន អាចជួយឱ្យឥទ្ធិពលអាក្រក់នឹងត្រូវបានកាត់បន្ថយ និងជួយផ្តល់ជាយោបល់ក្នុងការសម្រេចចិត្ត។ ការពិពណ៌នាពីប្រភព និងទំហំនៃសក្តានុពលហេតុប៉ះពាល់បរិស្ថាន នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមូលដ្ឋានគ្រឹះ សម្រាប់រចនាការកាត់បន្ថយជាក់លាក់នៃឥទ្ធិពលអាក្រក់ទាំងនោះ។

ជាចុងបញ្ចប់ វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានត្រូវបានកំណត់នៅ ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីអង្កេតតាមដានសកម្មភាពគម្រោងឱ្យមានប្រសិទ្ធភាព។

### ៣.៣.៦ ការរៀបចំរបាយការណ៍ហេតុប៉ះពាល់បរិស្ថាន

ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលយ៉ាងតិច ០៣ខែ ដើម្បីសិក្សា និងប្រមូលទិន្នន័យដែលមានស្រាប់ (Secondary data) ទាក់ទងនឹងធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រ ព្រមទាំងការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍ជាតិ ប្រជាពលរដ្ឋរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។ ដោយឡែក ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលចាប់ពី ០៦ខែឡើងទៅដើម្បីធ្វើការសិក្សា និងប្រមូលទិន្នន័យបឋម (Primary data) ដែលទាក់ទងនឹងធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគម្រោងដូចជា អាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ សហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។[79]

គំរូនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ៖

- សេចក្តីសង្ខេប
- សេចក្តីផ្តើម
- ក្របខ័ណ្ឌច្បាប់
- ការពិពណ៌នាពីគម្រោង

[79] ដូចយោងខាងលើ

- ការពិពណ៌នាពីធនធានដែលមានស្រាប់
- ការចូលរួមជាសាធារណៈ
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ
- ផែនការគ្រប់គ្រងបរិស្ថាន
- ការវិភាគពីការខូចខាតបរិស្ថាន និងផលចំណេញផ្នែកសេដ្ឋកិច្ច (សម្រាប់តែរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ)
- សេចក្តីសន្និដ្ឋាន។

### ៣.៣.៧ ធនធានបរិស្ថានដែលមានស្រាប់

#### ៣.៣.៧.១ បរិស្ថានធម្មជាតិ

បរិស្ថានរបស់ប្រទេសកម្ពុជាផ្តល់នូវធនធានធម្មជាតិ រួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ និងសត្វព្រៃ។ ធនធានធម្មជាតិក៏រួមបញ្ចូលផងដែរនូវ រ៉ែ ថាមពល និងឧស្សាហកម្មនិស្សារណកម្ម។ បរិស្ថាន គ្របដណ្តប់ដោយទេសភាពផ្សេងៗគ្នា យ៉ាងហោចណាស់ចំនួន០៧នៅទូទាំងប្រទេស។

ប្រហែលបីភាគបួននៃប្រជាជនកម្ពុជាពឹងផ្អែកលើ កសិកម្ម ទិន្នផលព្រៃឈើ និងនេសាទដើម្បីចិញ្ចឹមជីវិត។ ដូច្នេះការថែរក្សាបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិមានសារៈសំខាន់ណាស់។[80]

បរិស្ថានរបស់ប្រទេសកម្ពុជា ក៏ត្រូវបានចាត់ទុកជាធនធានមួយសម្រាប់ពិភពលោក។ ជាផ្នែកមួយនៃតំបន់ឥណ្ឌូចិនភូមា ប្រទេសកម្ពុជាគឺជាទីកំណាប់ធនធានជីវចម្រុះ និងជាប្រទេសដែលមានរុក្ខជាតិ សត្វកម្រ និងសត្វជិតផុតពូជចំនួន ២,៤៤៩ ប្រភេទ។[81] ទោះយ៉ាងណាក្តី ការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កឱ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ ១៩៩០ ជាងមកម្ល៉េះ។

ទោះបីជាភូមិសាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានគ្រប់ដណ្តប់ដោយដោយតំបន់ទំនាបកណ្តាលប្រហែលបីភាគបួននៃប្រទេសកម្ពុជា មានទេសភាពខុសៗគ្នាជាច្រើនផ្សេងទៀតគឺ ព្រៃតំបន់ខ្ពង់រាប (រួមមានតំបន់ភ្នំក្រវាញ ដងរែក និងភ្នំឆ្លូង ព្រៃលិចទឹក បឹងទន្លេសាប និងប្រព័ន្ធទន្លេមេគង្គ វាលទំនាប ខាងកើត ឬតំបន់ខ្ពង់រាប ព្រៃឈើកណ្តាល តំបន់ឆ្នេរសមុទ្រដែលរួមមានដីល្បាប់ កោងកាង និងកោះ ឈូងសមុទ្រថៃ។

ប្រហែលពីរភាគបីនៃប្រទេសកម្ពុជារួមមាន បឹងទន្លេសាបដែលស្ថិតនៅក្នុងអាងទន្លេមេគង្គគឺជាបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីរួមចំណែកយ៉ាងសំខាន់ដល់សុខមាលភាពនៃតំបន់មេគង្គទាំងមូល ជាពិសេសតំបន់ដី

[80] អង្គការទិន្នន័យអំពីការអភិវឌ្ឍ (https://opendevelopmentcambodia.net/km/)។ បានចូលអាន ១៩ មិថុនា ២០២៤

[81] សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN). "បញ្ជីក្រហមនៃប្រភេទសត្វដែលរងការគំរាមកំហែង របស់អង្គការ IUCN" ។ ចូលអាន ១២ មិថុនា ២០២៤

សណ្តទន្លេមេគង្គ។ កាលដើមឆ្នាំ ២០០១ អង្គការស្បៀងអាហារ និងកសិកម្មបានគូសបញ្ជាក់ពីការផ្លាស់ប្តូរប្រព័ន្ធអេកូទន្លេសាបដែលបាននាំយកមកនូវកំណាល្បាប់ម៉ដ្ឋ គឺមីកសិកម្ម ការបំពុលផ្សេងៗបម្រែបម្រួល ធារាសាស្ត្រ ការស្រោចស្រព និងការដឹកជញ្ជូន ហើយជាការពិត ការផ្លាស់ប្តូរទាំងនេះនឹងមានផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ដល់ប្រព័ន្ធទន្លេមេគង្គទាំងមូល។[82]

ការសិក្សាពី ស្ថានភាពដែលមានស្រាប់នៅទីតាំងគម្រោងក្នុងដំណាក់កាលនេះពិតជាមានសារៈសំខាន់ណាស់ព្រោះជាការសិក្សាមុនពេលគម្រោងសាងសង់ និងដំណើរការ។ ចំណុចសំខាន់ៗ នៃផ្នែកនេះគឺមានដូចខាងក្រោម៖

**ក. ធនធានរូបសាស្ត្រ**

- ដី៖ ភូគព្ភសាស្ត្រ សណ្ឋានដី ឋានលេខា ប្រភេទដី ការហូរច្រោះ ចំណាត់ថ្នាក់ប្រភេទដី សណ្ឋានដី និងការប្រើប្រាស់ដី។ ក្នុងករណីរៀបចំវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវសិក្សាលំអិតបន្ថែមពីការរញ្ជួយដី ភូគសាស្ត្រ(ធនធានរ៉ែ បើសិនជាមាន)
- អាកាសធាតុ៖ សីតុណ្ហភាព របបទឹកភ្លៀង (៥ឆ្នាំ) របបនិងល្បឿនខ្យល់ សម្ពាធខ្យល់ ទិសខ្យល់ និងសំណើម។
- គុណភាពខ្យល់ (ការវិភាគគុណភាពខ្យល់ក្នុងតំបន់គម្រោង) សំឡេងរំខាន និងរំញ័រ (ការវាស់សម្លេង និងឬំញ័រក្នុងតំបន់គម្រោង)
- ជលសាស្ត្រ៖ បរិមាណ និងគុណភាពទឹកលើដី-ក្រោមដី (ការវិភាគគុណភាពទឹកក្នុងតំបន់គម្រោង) ធារទឹក ចរន្តទឹក។[83]

**ខ. ធនធានជីវសាស្ត្រ**

- ព្រៃឈើ៖ ផ្ទៃដីព្រៃឈើ ប្រភេទគម្របព្រៃឈើ និងចំណាត់ថ្នាក់ប្រភេទឈើ
- ប្រភេទសត្វព្រៃ ប្រភេទសត្វកម្រ ប្រភេទជិតផុតពូជ និងការបំលាស់ទី
- ទីជំរក
- ជីវៈចម្រុះ និងជីវសាស្ត្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី
- ប្រព័ន្ធដីសើម (ភ្ជាប់មកជាមួយនូវផែនទីពាក់ព័ន្ធ)។[84]

[82] Dirk Lambert. អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ. ២០០១. "ការនេសាទនៅបឹងទន្លេសាប ករណីសិក្សាស្តីពីការនេសាទមងក្រឡានៅតំបន់លិចទឹក". ចូលដកស្រង់ ១២ មិថុនា ២០២៤

[83] ជំពូក៤ ប្រកាសលេខ៣៧៦ប្រ.ក.ប.ស្ក ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ១១ មិថុនា ២០២៤

### ៣.៣.៧.២ ធនធានសេដ្ឋកិច្ចនិងសង្គម

សេដ្ឋកិច្ច គឺជាការសិក្សាអំពីវិធីសាស្ត្របៀបប្រើប្រាស់ធនធាន ដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្សដែលមានប្រព័ន្ធទាក់ទិន និងប្រព័ន្ធផលិតកម្ម ( ផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម ) ប្រព័ន្ធបែងចែក ( ផ្នែកពាណិជ្ជកម្ម ) និងប្រើប្រាស់ទំនាក់ទំនងសេដ្ឋកិច្ច ( ផ្នែកអតិថិជន គមនាគមន៍ និងដឹកជញ្ជូន ) ។ ធនធានសេដ្ឋកិច្ច គឺជាវត្ថុទាំងឡាយដែលប្រើប្រាស់ក្នុងសេដ្ឋកិច្ច ដើម្បីផលិតទំនិញនិងសេវានានា ដូចជាធនធានធម្មជាតិ ( រ៉ែ ដី សត្វ រុក្ខជាតិ ទឹក ខ្យល់ ) និងសេវាសម្អាតសំណល់ ឬជាតិពុលដែលមាននៅក្នុងធម្មជាតិ និងសង្គម ។[85]

ការអភិវឌ្ឍន៍សេដ្ឋកិច្ចត្រូវផ្សាភ្ជាប់ទៅនឹងធនធានសង្គម និងវប្បធម៌ ដូចនេះព័ត៌មានស្តីពីធនធានសង្គមនិងវប្បធម៌មុនសាងសង់គម្រោងពិតជាមានសារៈសំខាន់ផងដែរ។ ព័ត៌មានដែលត្រូវគិតគូរសម្រាប់ផ្នែកនេះរួមមាន៖ ចំនួនប្រជាពលរដ្ឋ ស្ថានភាពសេដ្ឋកិច្ច (មុខរបរ ប្រាក់ចំណូល) ការប្រើប្រាស់ដី ការប្រើប្រាស់ទឹកថាមពល ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ សុខភាព និងសុខុមាលភាពសាធារណៈ សម្បត្តិវប្បធម៌ (សំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ ជនជាតិភាគតិច វត្តអារាម ប្រពៃណី...។ល។) តំបន់ទេសចរណ៍។

### ៣.៣.៨ ការពិនិត្យ និងធ្វើសេចក្តីសម្រេចលើរបាយការណ៍

ជាគោលការណ៍ច្បាប់ ក្រសួងបរិស្ថានមានតួនាទីជាអ្នកពិនិត្យលើរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងផ្តល់ការឯកភាព ឬមិនឯកភាពលើរបាយការណ៍នេះ។

រយៈពេលនៃការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងអភិវឌ្ឍន៍ មានរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការចាប់ពីថ្ងៃដែលក្រសួងបរិស្ថាន ទទួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងរបាយការណ៍បុរេ/សមិទ្ធិលទ្ធភាពគម្រោង។[86]

នីតិវិធីក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញនៅក្រសួងបរិស្ថានមានដូចជា៖[87]

- កិច្ចប្រជុំរបស់មន្ត្រីជំនាញរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការចុះពិនិត្យទីតាំងជាក់ស្តែង

---

[84] ដូចយោងខាងលើ

[85] Khmerrean (ដូចម្តេចហៅថាធនធានសេដ្ឋកិច្ចនិងសង្គម)។ ចូលអាន ១២ មិថុនា ២០២៤

[86] ប្រការ១០ ប្រកាសលេខ៣៧៦ប្រ.ក.ប.ស្ត ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៤ កក្កដា ២០២៤

[87] មគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ កក្កដា ២០២៤

- កិច្ចប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងបរិស្ថាន
- កិច្ចប្រជុំអន្តរក្រសួងដែលមានការចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនឹងគម្រោងវិនិយោគដោយមាន **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន** ជាប្រធានអង្គប្រជុំ
- ជាចុងក្រោយនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានរៀបចំលិខិតផ្តល់យោបល់ ដោយបញ្ចូលនូវមតិយោបល់ដែលទទួលបានពីអង្គប្រជុំទាំងបួនខាងលើដើម្បីឱ្យម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាកែតម្រូវឡើងវិញនូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

### ៣.៣.៩ ការពិនិត្យតាមដានគម្រោង

ដើម្បីធានាបាននូវការប្រតិបត្តិតាម និងដើម្បីសម្រេចបាននូវការប្តេជ្ញាចិត្តតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាំបាច់ត្រូវការមានប្រព័ន្ធពិនិត្យតាមដាន ដែលត្រូវមានការចូលរួមពិនិត្យតាមដានផ្ទៃក្នុងដោយនាយកគ្រប់គ្រងគម្រោងផង និងការពិនិត្យតាមដានគោលបំណងដោយបណ្តាភាគីពីខាងក្រៅផង។ ការពិនិត្យតាមដានពីខាងក្រៅនេះ អាចត្រូវបានអនុវត្តដោយភាគីណាមួយ (ឬដោយភាគីទាំងពីរ) គឺស្ថាប័នរដ្ឋាភិបាល ឬអង្គការសហគមន៍។ ការពិនិត្យតាមដានគឺជាសកម្មភាពធ្វើបន្តជាប្រចាំ។ ការពិនិត្យតាមដាន នឹងជួយបំពេញចិត្តសហគមន៍ ដោយគម្រោងត្រូវបានដំណើរការអនុលោមតាមលក្ខខណ្ឌនៃការអនុម័តនេះ។ វាក៏អាចជួយឱ្យមានការឆ្លើយតបទៅនឹងបញ្ហានានា និងកង្វល់ផ្សេងៗ មុនពេលផលវិបាកធ្ងន់ធ្ងរកើតឡើងដែរ។ វាក៏ចាំបាច់ដែលគេត្រូវការឱ្យមានយន្តការមួយដើម្បីធានាថាការចូលរួមរបស់សហគមន៍ដែលគេបានប្តេជ្ញាចិត្ត នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានត្រូវបានអនុវត្តក្នុងអំឡុងពេលអនុវត្តគម្រោង។

ប្រសិនបើ ការពិនិត្យតាមដានរកឃើញថាពុំមានការប្រតិបត្តិតាម ឬមានការរំលោភបំពានលក្ខខណ្ឌនានា ដូច្នេះយន្តការដើម្បីពង្រឹងការប្រតិបត្តិតាមចាំបាច់ត្រូវតែមានជាស្រេច ហើយឲ្យអ្នកស្នើសុំគម្រោងក៏ដូចជាប្រជាជនដែលរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធផ្សេងៗ យល់។[៨៨]

## ៣.៤ គំរូក្របខ័ណ្ឌទំនួលខុសត្រូវនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន

គំរូក្របខ័ណ្ឌទំនួលខុសត្រូវនេះ កំណត់សកម្មភាពរបស់គម្រោង វិសាលភាព វិធីសាស្រ្តសិក្សាស្រាវជ្រាវ និងទម្រង់របាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សម្រាប់ប្រើប្រាស់នៅក្រសួងបរិស្ថាន ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ និងអ្នកពាក់ព័ន្ធជាមួយគម្រោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

[៨៨] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ។ បានអាន ០៤ កក្កដា ២០២៤

### ៣.៤.១ សេចក្តីផ្តើម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់នឹងពិពណ៌នានូវចំណុចសំខាន់មួយចំនួនដូចខាងក្រោម៖[89]

- ទស្សនៈវិស័យ និងគោលបំណងនៃការវិនិយោគ ក្នុងការចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈវិស័យហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។
- កាតព្វកិច្ចផ្លូវច្បាប់ ដែលតម្រូវឲ្យក្រុមហ៊ុនវិនិយោគធ្វើការរៀបចំក្របខ័ណ្ឌទំនួលខុសត្រូវលើការរៀបចំរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម។
- សារៈសំខាន់នៃក្របខ័ណ្ឌទំនួលខុសត្រូវ សម្រាប់រៀបចំរបាយការណ៍នៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សម្រាប់គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

### ៣.៤.២ គោលបំណងរបស់ក្របខ័ណ្ឌទំនួលខុសត្រូវ

គោលបំណងសំខាន់របស់ក្របខ័ណ្ឌទំនួលខុសត្រូវ គឺ៖[90]

- គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់រៀបចំរបាយការណ៍បឋម ឬពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ប្រកបដោយគុណភាពខ្ពស់ និងភាពត្រឹមត្រូវ។
- កំណត់វិសាលភាព និងវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវអំពីធនធានបរិស្ថានដែលមានស្រាប់ដូចជាធនធានរូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។
- កំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ និងសាធារណៈជន ដើម្បីធ្វើការពិគ្រោះយោបល់ ។
- កំណត់ទម្រង់របាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សមាជិកក្នុងក្រុមសិក្សាស្រាវជ្រាវ និងកាលវិភាគនៃផែនការសិក្សា។

### ៣.៤.៣ ការពិពណ៌នារបស់គម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់នឹងបង្ហាញនូវចំណុចមួយចំនួន ដូចខាងក្រោម៖[91]

- សារៈសំខាន់នៃវត្តមានរបស់គម្រោង
- ការវិភាគអំពីជម្រើសនានារបស់គម្រោង

[89] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

[90] ដូចយោងខាងលើ

[91] ជំពូក៣ ប្រកាសលេខ៣៧៦ ប្រ.ក.ប.ស្ត ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៤ កក្កដា ២០២៤។ បានអាន ០៤ កក្កដា ២០២៤

- សាវតា និងបទពិសោធន៍របស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការអនុវត្តគម្រោង
- ប្រភពទុន និងប្រភេទគម្រោង (វិស័យសាធារណៈ ឬ វិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍)
- ឧបករណ៍ផ្នែកច្បាប់ពាក់ព័ន្ធនឹងគម្រោង
- ទីតាំងភូមិសាស្ត្រ៖ បង្ហាញទីតាំងភូមិសាស្ត្រ ព្រំប្រទល់ ទំហំដី និងទីតាំងរបស់គម្រោង ដែលជាប់ទាក់ទង នឹងតំបន់សំខាន់ៗ ដោយត្រូវភ្ជាប់ជាមួយនឹងផែនទីរដ្ឋបាល (Datum Coordinate System: UTM_WGS1984_48N) and Google Map។
- សង្ខេបសកម្មភាពរបស់គម្រោង (វដ្តគម្រោង និងរយៈពេល) រួមមាន៖
    - ផែនការបែងចែកដីសម្រាប់គម្រោង (ដីសម្រាប់សាងសង់ ហេដ្ឋារចនាសម្ព័ន្ធ តំបន់បៃតង និង ចំណតឡាន ស្របទៅតាមផែនការមេ ។ល។) (មានភ្ជាប់មកជាមួយនូវទម្រង់ផែនការបែងចែងដី ផែនការអគារ គំរូព្រាងផែនការស្ថាបត្យកម្ម ការប្រើប្រាស់ដីធ្លី គំរូព្រាង អគារ និង ផែនការ ។ល។)
    - ផែនការអនុវត្តគម្រោង
    - បច្ចេកទេសសាងសង់
    - តម្រូវការគ្រឿងម៉ាស៊ីន ឧបករណ៍ សម្ភារៈ និងបរិក្ខាផ្សេងៗទៀត
    - តម្រូវការវត្ថុធាតុដើម (សម្ភារៈ និងឧបករណ៍សំណង់)
    - តម្រូវការធនធានមនុស្ស កម្លាំងពលកម្ម និងចំនួនទេសចរ (តួនាទី សញ្ជាតិ និងប្រាក់ខែកំឡុងពេលសាងសង់ និងប្រតិបត្តិការ)
    - តម្រូវការប្រើប្រាស់ថាមពល
        - អគ្គិសនីរដ្ឋ ឬ ឯកជន (ការប្រើប្រាស់ថាមពល)
        - ម៉ាស៊ីនភ្លើង (ទំហំកម្លាំងថាមពល)
        - ប្រព័ន្ធពន្លឺព្រះអាទិត្យ
    - តម្រូវការទឹក (ប្រភព និងបរិមាណ)
    - ផែនការគ្រប់គ្រងសំណល់រឹង-ទន់៖
        - សំណល់រឹង៖ ត្រូវកំណត់អត្តសញ្ញាណប្រភព និងប្រភេទសំណល់ដែលបានបង្កើតឡើង ដោយសកម្មភាពរបស់គម្រោង និងពិពណ៌នាអំពីទីតាំង ការទុកដាក់ និងការគ្រប់គ្រងសំណល់។

- សំណល់ទឹក៖ ទីតាំងរោងចក្រចម្រុះទឹក បច្ចេកទេស មុខងារ ដំណើរការនៃរោងចក្រចម្រុះទឹក ទំហំ សមត្ថភាព និងទីតាំងស្តុកសំណល់ទឹកចុងក្រោយ
- ភក់៖ ការគ្រប់គ្រងភក់ដែលចេញពីរោងចក្រចម្រាស់សំណល់ទឹក
- សំណល់ពីឧស្ម័ន៖ ការគ្រប់គ្រងឧស្ម័នចេញពីម៉ាស៊ីនភ្លើង ឬ ម៉ាស៊ីន ផ្សេងៗទៀត
- សំណល់ដែលមានគ្រោះថ្នាក់៖ (កំបោរ ថ្នាំលាប ។ល។)

- ការបង្កើតប្រព័ន្ធប្រមូលទឹកភ្លៀងនៅក្នុងតំបន់របស់គម្រោង
- ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពបុគ្គលិក/កម្មករ ទេសចរ និងប្រជាជន
- ការគ្រប់គ្រងហានិភ័យ (គ្រោះមហន្តរាយធម្មជាតិ ប្រព័ន្ធការពារភ្លើងឆេះ ការដាក់ស្លាក ផ្តល់សញ្ញាប្រមានអំពីមហន្តរាយ ជណ្តើរឡើងចុះក្នុងគ្រាអាសន្ន ការបណ្តុះ បណ្តាលអំពីការសង្គ្រោះ គិលានដ្ឋាន និងមេធាវី សម្រាប់ដោះស្រាយករណី មានហានិភ័យកើតឡើង)។
- រយៈពេលនៃសកម្មភាពរបស់គម្រោង។

### ៣.៤.៤ វិសាលភាព និងវិធីសាស្ត្រនៃការសិក្សា

ពាក់ព័ន្ធនឹងការកំណត់វិសាលភាព និងវិធីសាស្ត្រក្នុងការសិក្សាលើរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញអំពីការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ឬអំពីរបាយការណ៍ប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ ត្រូវប៉ាន់ប្រមាណធនធានបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោង និងនៅជុំវិញការដ្ឋានគម្រោងដូចជា ធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។ ក្នុងការប្រមូលទិន្នន័យម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវពឹងផ្អែកលើ៖[92]

ទិន្នន័យបន្ទាប់បន្សំ៖ ទិន្នន័យដែលត្រូវប្រមូល និងទាញយកពីឯកសារបច្ចេកទេសសំខាន់ៗរបស់គម្រោង រួមមាន របាយការណ៍បច្ចេកទេសរបស់ក្រុមហ៊ុន ផែនការមេ និងឯកសារពាក់ព័ន្ធ។

ទិន្នន័យបឋម៖ ជាទិន្នន័យដែលត្រូវប្រមូលតាមរយៈការអង្កេតនៅក្នុង និងជុំវិញតំបន់របស់គម្រោងដោយផ្តោតលើធនធានរូបវន្ត ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម និងការប្រើប្រាស់វិធីសាស្ត្រលម្អិតបែបវិទ្យាសាស្ត្រ។

#### ៣.៤.៤.១ ការចូលរួមពីសាធារណៈជន

ការពិភាក្សា និងពិគ្រោះយោបល់ជាមួយនឹងសាធារណៈជន ក្រសួងមន្ទីរ ស្ថាប័នជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន តំណាងក្រុមហ៊ុន តំណាងអង្គភាពពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន គឺជាចំណុចមួយដ៏

[92] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

សំខាន់ដែលធ្វើឡើងដើម្បីបង្ហាញនូវផលប៉ះពាល់ដែលកើតមានក្នុងដំណាក់កាលអនុវត្តគម្រោង សម្រាប់យកមកវិភាគឱ្យបានល្អិតល្អន់មូលមតិគ្នាដោះស្រាយ ក្នុងគោលបំណងទទួលបានមកវិញនូវផលល្អប្រសើរចេញពីការបាត់បង់ធនធានធម្មជាតិដោយសារគម្រោងអភិវឌ្ឍន៍ ដោយការសម្បទានគ្នាទៅវិញទៅមក និងដើម្បីឲ្យអ្នកពាក់ព័ន្ធចូលរួមទាំងអស់ជួយផ្តល់នូវមតិយោបល់ និងសំណូមពរ សម្តៅទប់ស្កាត់ការបង្កហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុតាមរយៈវិធានការកាត់បន្ថយយ៉ាងមានប្រសិទ្ធិភាព ជួយដល់ការអនុវត្តន៍គម្រោងឱ្យមានការវិវត្តន៍ទៅមុខយ៉ាងរលូនប្រកបដោយនិរន្តរភាព។[93]

ផែនការសម្រាប់ការចូលរួមជាសាធារណៈមានបីដំណាក់កាលដូចខាងក្រោម៖

### ក. ដំណាក់កាលផ្សព្វផ្សាយក្នុងតំបន់គម្រោង

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវផ្តល់ព័ត៌មានអំពីគម្រោង វិសាលភាពរបស់គម្រោង និងទំហំ នៃផលប៉ះពាល់ដែលគម្រោងនឹងមានមកលើអ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅក្នុងតំបន់ និងជុំវិញតំបន់គម្រោង ព្រមទាំងផ្តល់លទ្ធភាពឱ្យអាជ្ញាធរមូលដ្ឋាន អ្នកពាក់ព័ន្ធ និងប្រជាជនរងគ្រោះអាចទទួលបាននូវព័ត៌មានសំខាន់ៗរបស់គម្រោង។ សមាសភាពអ្នកចូលរួម មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររ៉ែ និងថាមពល មន្ទីរជំនាញ ពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ភូមិ សហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាជនរងគ្រោះ ឬអាជ្ញាធរមីន និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងមានសង្គ្រាមកាលពីអតីតកាល)។

ទីកន្លែង ការជួបជុំនេះអាចធ្វើនៅទីតាំងគម្រោង ឬកន្លែងសាធារណៈ (វត្តអារាម ឬសាលារៀន) ឬកន្លែងប្រជុំផ្សេងៗទៀត។ រយៈពេលនៃការផ្សព្វផ្សាយ យ៉ាងហោចណាស់ ០១ថ្ងៃ។[94]

### ខ. ដំណាក់កាលសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ

ការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវសម្ភាសន៍អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធ ផ្សេងៗ ដាច់ពីគ្នា ដើម្បីទទួលយោបល់ និងអនុសាសន៍លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

សមាសភាពអ្នកចូលរួម រដ្ឋបាលរាជធានី/ខេត្ត មន្ទីរបរិស្ថាន មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរ ទេសចរណ៍ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧត្តនិយម មន្ទីរសាធារណការ

[93] ឧបសម្ព័ន្ធ១ ជំពូកទី៥ ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៤ កក្កដា ២០២៤។ បានអាន ០៤ កក្កដា ២០២៤។ បានដកស្រង់ ០៤ កក្កដា ២០២៤

[94] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

និងដឹកជញ្ជូន មន្ទីរការងារ និងបណ្តុះបណ្តាវិជ្ជាជីវៈ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ នាយកដ្ឋានផែនការ មន្ទីរអភិវឌ្ឍន៍ ជនបទ មន្ទីរសុខាភិបាល និងអាជ្ញាធរមីន និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងដែលមានគ្រាប់មីន និងគ្រឿងមិនទាន់ផ្ទុះ)។

ទីកន្លែងការសម្ភាសអាចធ្វើបាននៅក្នុងទីតាំងរបស់គម្រោង ឬនៅទីសាធារណៈ (វត្តអារាម ឬសាលារៀន) ឬកន្លែងប្រជុំផ្សេងៗ។ រយៈពេលសម្ភាសន៍យ៉ាងហោចណាស់ ០១សប្តាហ៍។[95]

ការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍រងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងៗ៖ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវធ្វើការប្រជុំជាក្រុម ឬការប្រជុំដាច់ដោយឡែកជាមួយអ្នកពាក់ព័ន្ធ ដើម្បីទទួលបានយោបល់ និងអនុសាសន៍អំពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។សមាសភាពអ្នកចូលរួមអាជ្ញាធរឃុំ/សង្កាត់ និងភូមិ តំណាងសហគមន៍ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ដែលរងគ្រោះ។

ទីកន្លែង ការសម្ភាសអាចធ្វើបាននៅក្នុងទីតាំងរបស់គម្រោង ឬនៅទីសាធារណៈ (វត្តអារាម ឬសាលារៀន) ឬកន្លែងប្រជុំផ្សេងៗ។ រយៈពេលសម្ភាសន៍យ៉ាងហោចណាស់ ០៤សប្តាហ៍។[96]

### គ. ដំណាក់កាលសិក្ខាសាលាពិគ្រោះយោបល់

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់សាធារណៈមួយដើម្បីបង្ហាញលទ្ធផលពីការសិក្សាលើការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម និងលទ្ធផលពីការសម្ភាសជាមួយអ្នកពាក់ព័ន្ធខាងលើ។ សមាសភាពអ្នកចូលរួមក្រសួងបរិស្ថាន (នាយកដ្ឋានប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន) រដ្ឋបាលរាជធានី/ ខេត្ត មន្ទីរបរិស្ថាន មន្ទីររ៉ែ និងថាមពល មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរកិច្ចការនារី មន្ទីរទេសចរណ៍ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមីន និងគ្រឿងផ្ទុះ (ករណីដែលគម្រោងស្ថិតក្នុងទីតាំងដែលមានគ្រាប់មីន និងគ្រឿងមិនទាន់ផ្ទុះ) សហគមន៍ និងប្រជាពលរដ្ឋដែលរងគ្រោះ។

ទីកន្លែងការសម្ភាសអាចធ្វើបាននៅទីតាំងរបស់គម្រោង ឬនៅទីសាធារណៈ(វត្តអារាម ឬសាលារៀន) ឬកន្លែងប្រជុំផ្សេងៗ។ រយៈពេលនៃការសម្ភាសយ៉ាងហោចណាស់០១ថ្ងៃ។[97]

---

[95] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

[96] ដូចយោងខាងលើ

[97] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

### ៣.៤.៤.២ ការកំណត់សក្ដានុពលនៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

**ក. ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ**

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបញ្ជាក់ឱ្យច្បាស់អំពីវិសាលភាព និងវិធីសាស្ត្រ សម្រាប់កំណត់ផលប៉ះពាល់ជាសក្ដានុពលផ្នែកបរិស្ថាន និងសង្គម នៅដំណាក់កាលមុនពេលប្រតិបត្តិការ (ដំណាក់កាលរៀបចំគម្រោង និងដំណាក់កាលសាងសង់) ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់ ដោយត្រូវប្រើវិធានមួយចំនួនដូចខាងក្រោម៖[98]

- តារាងម៉ាទ្រិក ដែលត្រូវបង្ហាញពីទំនាក់ទំនងរវាងសកម្មភាពគម្រោង និងផលប៉ះពាល់របស់វាដែលមានមកលើធនធានបរិស្ថាន ដើម្បីកំណត់ផលប៉ះពាល់ជាសក្ដានុពល (បាទ/ចាស ឬ ទេ)
- ប្រព័ន្ធព័ត៌មានទីតាំងភូមិសាស្ត្រ (GIS) ដោយប្រើឧបករណ៍ Tool Overlay ដើម្បីកំណត់ទីតាំងដែលគម្រោងអាចនឹងធ្វើឱ្យមានផលប៉ះពាល់លើបរិស្ថាន។
- តារាងត្រួតពិនិត្យសម្រាប់ផលប៉ះពាល់លើធនធានបរិស្ថាន (តិចតួច មធ្យម ធ្ងន់ធ្ងរ)។

សម្រាប់សំណើគម្រោង ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណមួយ ដែលផ្តោតលើ ដំណាក់កាលមុនប្រតិបត្តិការ ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់របស់គម្រោង។ សម្រាប់គម្រោងដែលកំពុងបន្តម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណមួយ ដែលផ្តោតលើដំណាក់កាលសាងសង់ និង/ឬ ដំណាក់កាលប្រតិបត្តិការ និងដំណាក់កាលបញ្ចប់។[99]

- ដំណាក់កាលមុនប្រតិបត្តិការ៖ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវចែកដំណាក់កាល នេះជាពីរដំណាក់រួមមាន ដំណាក់កាលរៀបចំគម្រោង និងដំណាក់កាលសាងសង់ ដោយត្រូវកំណត់និយមន័យនៃផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ព្រមទាំងវិធានការកាត់បន្ថយ។ ដំណាក់កាលរៀបចំគម្រោង សំដៅដល់ការរៀបចំផែនការស្វែងរកដំណោះស្រាយជម្លោះដីធ្លីរហូតដល់ការកំណត់ព្រំដែនហើយដំណាក់កាលសាងសង់ សំដៅដល់ការសម្អាតដី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងទីតាំងគម្រោង។ល។
- ដំណាក់កាលប្រតិបត្តិការ៖ ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់អត្តសញ្ញាណ ផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម និងវិធានការ

[98] ដូចយោងខាងលើ

[99] ឧបសម្ព័ន្ធ១ ជំពូកទី៧ ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៤ កក្កដា ២០២៤។ បានអាន ០៤ កក្កដា ២០២៤។ បានដកស្រង់ ០៤ កក្កដា ២០២៤

កាត់បន្ថយ។ ដំណាក់កាលនេះ សំដៅដល់ការចាប់ផ្តើមសកម្មភាពសាងសង់ និង ប្រតិបត្តិការរបស់គម្រោង។

- ដំណាក់កាលបញ្ចប់គម្រោង៖ បន្ទាប់ពីបានបញ្ចប់សកម្មភាពរបស់គម្រោង ម្ចាស់គម្រោង ត្រូវផ្ទេរគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍ទៅឲ្យរាជរដ្ឋាភិបាល (សម្រាប់គម្រោងជួល ដីពីរាជរដ្ឋាភិបាលហើយសម្រាប់គម្រោងលើដីដែលជាសម្បត្តិឯកជនរបស់រដ្ឋ ម្ចាស់គម្រោងត្រូវបន្តអនុវត្តកិច្ចព្រមព្រៀងជួលពីរដ្ឋាភិបាល។ ហេតុដូច្នេះ មុនពេលផ្ទេរដី ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់ ផលប៉ះពាល់ផ្នែកបរិស្ថានលើធនធានជារូបវន្ត ធនធាន ជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ព្រមទាំងវិធានការកាត់បន្ថយ និងវិធានការស្តារឡើងវិញ។

**ខ. ផលប៉ះពាល់សរុបផ្នែកបរិស្ថានសម្រាប់របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាផលប៉ះ ពាល់ផ្នែកបរិស្ថាន និងសង្គម**

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវធ្វើការប៉ាន់ប្រមាណផលប៉ះពាល់សរុប ដែលបណ្តាលមកពីសកម្មភាពរួមគ្នារវាងគម្រោងជាច្រើន ឬសកម្មភាពផ្សេងៗដោយផ្តោតលើធនធានជារូបវន្ត ធនធានជីវសាស្ត្រ និង ធនធានសេដ្ឋកិច្ចសង្គម (ភ្ជាប់មកជាមួយផែនទីនៃទីតាំងគម្រោង ឬសកម្មភាព)។

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីទំហំ និងវិធីសាស្ត្រដើម្បីកំណត់ផល ប៉ះពាល់ជាសក្តានុពលផ្នែកបរិស្ថាន និងសង្គមសរុបតាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានទីតាំងភូមិសាស្ត្រ (GIS) ឧបករណ៍ Tool Overlay ក្នុងការកំណត់ទីតាំងដែលគម្រោងនឹងបណ្តាលឱ្យមានផលប៉ះពាល់ ផ្នែកបរិស្ថាន។[100]

**គ. អ្នកទទួលខុសត្រូវក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន**

ជាទូទៅ ភាគីស្នើសុំគម្រោង និងបង្កើតសកម្មភាពគម្រោងជានិច្ចកាលត្រូវ ទទួលខុសត្រូវក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដោយសហការ និងមានការចូលរួមពីអ្នកពាក់ព័ន្ធ។

ចុងបញ្ចប់ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាចងក្រងពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ របាយការណ៍នេះត្រូវបញ្ចូលនូវអ្វីដែលបានរកឃើញ និងសិក្សាដោយគោរពទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។ បន្ទាប់មក ម្ចាស់

[100] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានដកស្រង់ ០៤ កក្កដា ២០២៤

គម្រោង ត្រូវដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមកក្រសួងបរិស្ថានដើម្បី ពិនិត្យ និងផ្តល់យោបល់។[101]

### ៣.៤.៤.៣ ផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវពិពណ៌នាផែនការគ្រប់គ្រងបរិស្ថាន ដោយផ្តោតលើផែនការសំខាន់ៗ សម្រាប់ពិនិត្យតាមដានបរិស្ថាន និងបង្កើតតារាងកម្មវិធីពិនិត្យតាមដានបរិស្ថាន កំឡុងពេលដំណាក់កាលសាងសង់ ប្រតិបត្តិការ និងដំណាក់កាលបញ្ចប់គម្រោង ដែលក្រុមហ៊ុនត្រូវរៀបចំ៖[102]

១. សេចក្តីផ្តើម

២. មុខងារត្រួតពិនិត្យ និងគណនេយ្យភាព

ក). ស្ថាប័នត្រួតត្រាថ្នាក់ជាតិ

ខ). ស្ថាប័នត្រួតត្រាថ្នាក់ក្រោមជាតិ

គ). ស្ថាប័នទទួលខុសត្រូវ

៣. សង្ខេបផលប៉ះពាល់ និងវិធានការកាត់បន្ថយ ដែលឆ្ពោះទៅរកការកសាងផែនការគ្រប់គ្រងបរិស្ថាន

៤. កម្មវិធីបណ្តុះបណ្តាល

៥. កម្មវិធីពិនិត្យតាមដាន

ក). កំណត់អត្តសញ្ញាណធនធានបរិស្ថាន ទីតាំង ប៉ារ៉ាម៉ែត្រ និងឧបករណ៍ សម្ភារះពិនិត្យតាមដាន។

ខ). ស្ថាប័នត្រួតត្រា អ្នកទទួលខុសតក្សរូវ និងថវិកាសម្រាប់ការពិនិត្យតាមដាន

គ). កត់ត្រា និងវិភាគទិន្នន័យ និងប្រៀបធៀបទិន្នន័យទាំងនោះជាមួយនឹងទិន្នន័យមូលដ្ឋាន និង ស្តង់ដាបច្ចេកទេសអនុវត្ត។

៦. ផែនការថវិកាសម្រាប់កម្មវិធីពិនិត្យតាមដាន

៧. របាយការណ៍ពិនិត្យតាមដាន

៨. មូលនិធិសង្គមនិងបរិស្ថាន៖ មូលនិធិនេះស្របទៅតាមអនុក្រឹត្យលេខ ២៣៨ អ.ន.ក្រ.បក ចុះកាលបរិច្ឆេទ ( ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិសង្គមនិងបរិស្ថាន និងប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។

[101] មគ្គុទ្ទេសក៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា,ឆ្នាំផលិតគ.ស២០១២។ បានដកស្រង់ ០៥ កក្កដា ២០២៤

[102] ដូចយោងខាងលើ

### ៣.៤.៤.៤ ការវិភាគតម្លៃសេដ្ឋកិច្ច និងការខូចខាតផ្នែកបរិស្ថាន សម្រាប់របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវបញ្ជាក់ឱ្យច្បាស់អំពីវិសាលភាព និងវិធីសាស្ត្ររួមបន្ត គោលបំណង និងសូចនាករនៃការវិភាគផ្នែកសេដ្ឋកិច្ច និងសង្គម ដោយផ្តោតលើការវិភាគផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច និងការខូចខាតផ្នែកបរិស្ថានដោយមានបញ្ជាក់អំពីឯកសារយោង និងប្រភពច្បាស់លាស់។[103]

១. ការវិភាគផ្នែកហិរញ្ញវត្ថុ៖ ផ្អែកលើការសិក្សាអំពីការខាតបង់ប្រាក់ចំណេញរបស់ម្ចាស់គម្រោង។

២. ការវិភាគផ្នែកសេដ្ឋកិច្ច៖ ផ្អែកលើប្រាក់ចំណេញរបស់ម្ចាស់គម្រោងដែលបានបង់ទៅឱ្យរដ្ឋ

៣. ការវិភាគអំពីការខូចខាតផ្នែកបរិស្ថាន៖ ការវិភាគពីតម្លៃដោយផ្ទាល់ និងប្រយោលលើ៖ [104]

ក.) ធនធានជារូបវន្ត៖ ជាតិពុលក្នុងខ្យល់ ការរំខានដោយសំឡេង និងរំញ័រ គុណភាពទឹកលើដី និងទឹកក្រោមដី ការថយគុណភាពដី ។ល។

ខ). ធនធានជីវសាស្ត្រ៖ តម្លៃព្រៃឈើនៅសល់ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ផលិតផល និងអនុផលព្រៃឈើ ធនធានសត្វព្រៃ ធនធានក្នុងទឹក តម្លៃទេសចរណ៍បែបធម្មជាតិ តម្លៃបរិស្ថាន ។ល។

គ). ធនធានសេដ្ឋកិច្ចសង្គម៖ ការងារ ប្រាក់ចំណូល ទទួលបានអនុផលព្រៃឈើ ។ល។

### ៣.៤.៥ ការកំណត់ទម្រង់របាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់នឹងត្រូវរៀបចំរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ស្របតាមប្រកាសរបស់ក្រសួងបរិស្ថានស្តីពីគោលការណ៍ណែនាំទូទៅសម្រាប់ធ្វើរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ហើយត្រូវពិពណ៌នាដោយសង្ខេបអំពីចំណុចដែលត្រូវសិក្សានៅក្នុងផ្នែកនីមួយៗនៃរបាយការណ៍។[105]

តារាង៣៖ មាតិកានៃរបាយការណ៍បឋម ឬរបាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម

---

[103] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានអាន ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

[104] ជំពូក៤ ប្រកាសលេខ៣៧៦ ប្រ.ក.ប.ស្ក ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ បានអាន ០៤ កក្កដា ២០២៤។ បានអាន ០៤ កក្កដា ២០២៤

[105] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានអាន ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

| មាតិកា | |
|---|---|
| **របាយការណ៍បឋមនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម** | **របាយការណ៍ពេញលេញនៃការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម** |
| - បញ្ជីតារាង<br>- បញ្ជីរូបភាព<br>- បញ្ជីក្រាហ្វិក<br>- បញ្ជីផែនទី<br>- បញ្ជីអក្សរកាត់<br>- សង្ខេបប្រតិបត្តិ<br>ជំពូក១៖ សេចក្តីផ្តើម<br>ជំពូក២៖ វិសាលភាព និងវិធីសាស្ត្រសិក្សា<br>ជំពូក៣៖ ក្របខ័ណ្ឌច្បាប់<br>ជំពូក៤៖ សេចក្តីពិពណ៌នាអំពីគម្រោង<br>ជំពូក៥៖សេចក្តីពិពណ៌នាអំពីធនធានបរិស្ថាន ដែលមានស្រាប់<br>ជំពូក៦៖ ការចូលរួមជាសាធារណៈ<br>ជំពូក៧៖ ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ<br>ជំពូក៨៖ ផែនការគ្រប់គ្រងបរិស្ថាន<br>ជំពូក៩៖ ការវិភាគតម្លៃសេដ្ឋកិច្ច និងបរិស្ថាន<br>ជំពូក១០៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍<br>- ឯកសារយោង<br>- ឧបសម្ព័ន្ធ | - បញ្ជីតារាង<br>- បញ្ជីរូបភាព<br>- បញ្ជីក្រាហ្វិក<br>- បញ្ជីផែនទី<br>- បញ្ជីអក្សរកាត់<br>- សង្ខេបប្រតិបត្តិ<br>ជំពូក១៖ សេចក្តីផ្តើម រួមទាំង វិសាលភាព និងវិធីសាស្ត្រសិក្សា<br>ជំពូក២៖ ក្របខ័ណ្ឌច្បាប់<br>ជំពូក៣៖ សេចក្តីពិពណ៌នាអំពីគម្រោង<br>ជំពូក៤៖សេចក្តីពិពណ៌នាអំពីធនធានបរិស្ថាន ដែលមានស្រាប់<br>ជំពូក៥៖ ការចូលរួមជាសាធារណៈ<br>ជំពូក៦៖ ផលប៉ះពាល់ផ្នែកបរិស្ថាន និងវិធានការកាត់បន្ថយ<br>ជំពូក៧៖ ផែនការគ្រប់គ្រងបរិស្ថាន<br>ជំពូក៨៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍<br>- ឯកសារយោង<br>- ឧបសម្ព័ន្ធ |

*(ដកស្រង់ចេញពីសៀវភៅគម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិ ប្រកបដោយនិរន្តរភាពនៅកម្ពុជា រៀបចំឡើងដោយៈក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ)*

### ៣.៤.៦ សមាសភាគនៃក្រុមការងារសិក្សា

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវបង្ហាញឈ្មោះប្រធានក្រុមសិក្សាអ្នកជំនាញ និងជំនួយការសម្រាប់ការសិក្សា និងការស្រាវជ្រាវរបស់គម្រោងនានា ហើយអ្នកទាំងនោះនឹងត្រូវចុះក្នុងបញ្ជីក្រុមហ៊ុនប្រឹក្សាយោបល់។ បើសិនជាម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវជូនដំណឹងដល់ក្រសួងបរិស្ថានក្នុងរយៈពេល ០១ខែមុន។[106]

### ៣.៤.៧ កាលវិភាគការងារ/សកម្មភាពការងារសិក្សា

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវកំណត់រយៈពេល ចាប់ពីការសិក្សាដំបូងរហូតដល់ការដាក់របាយការណ៍ទៅក្រសួងបរិស្ថានដើម្បីពិនិត្យ និងផ្តល់យោបល់។[107]

### ៣.៤.៨ ឧបសម្ព័ន្ធ

ម្ចាស់គម្រោង និងក្រុមហ៊ុនប្រឹក្សាយោបល់ត្រូវភ្ជាប់មកជាមួយនូវឯកសារផ្លូវច្បាប់ ដែលពាក់ព័ន្ធនឹងគម្រោងដូចជា អនុក្រឹត្យស្តីពីការផ្តល់ចំណាត់ថ្នាក់ឡើងវិញលើដី កិច្ចសន្យាជួលដី ប័ណ្ណចុះបញ្ជីក្រុមហ៊ុនប្រឹក្សាយោបល់នៅក្រសួងបរិស្ថាន លិខិតអនុញ្ញាតពីម្ចាស់គម្រោងឱ្យក្រុមហ៊ុនប្រឹក្សាពិគ្រោះយោបល់ធ្វើការសិក្សា និងរៀបចំរបាយការណ៍ EIA ឧបករណ៍ផ្លូវច្បាប់នានារបស់ក្រសួងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ។ល។[108]

## ៣.៥ បញ្ហាប្រឈម និងដំណោះស្រាយនៃការអនុវត្តច្បាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ៣.៥.១ បញ្ហាប្រឈម

ទោះបីជាច្បាប់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានអនុម័តតាំងពីឆ្នាំ១៩៩៦មកម្លេះ ក៏ប៉ុន្តែក្រសួងបរិស្ថានបានអះអាងថាការអនុវត្តនៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះដែរក្រសួងបរិស្ថានបានរកឃើញនូវបញ្ហាប្រឈមមួយចំនួន ដែលនាំឱ្យការអនុវត្តមិនទាន់មានប្រសិទ្ធភាពខ្ពស់។ បញ្ហាប្រឈមទាំងនោះរួមមានដូចជា៖

- កង្វះឧបករណ៍វាយតម្លៃបរិស្ថានយុទ្ធសាស្ត្រសម្រាប់កំណត់តំបន់អភិវឌ្ឍន៍ និងតំបន់អភិរក្សហើយតំបន់អភិវឌ្ឍន៍នេះទៀតសោតពុំមានផែនការច្បាស់លាស់ សម្រាប់អភិវឌ្ឍន៍លើវិស័យឧស្សាហកម្មថាមពល រ៉ែ កសិកម្ម ឧស្សាហកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ
- កង្វះឧបករណ៍ច្បាប់សម្រាប់ពង្រឹងដល់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

[106] គម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC)នៅកម្ពុជា។ បានអាន ០៤ កក្កដា ២០២៤
[107] ដូចយោងខាងលើ
[108] ដូចយោងខាងលើ

- កង្វះកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធលើវិស័យអភិវឌ្ឍន៍នានា
- ក្រសួងពុំមានការដាក់ពិន័យ ឬចំណាត់ការផ្លូវច្បាប់ទៅលើម្ចាស់គម្រោងពុំអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន ជាពិសេសគម្រោងដែលគ្មានច្បាប់អនុញ្ញាតពីក្រសួងបរិស្ថាន
- នីតិវិធីរដ្ឋបាលមានភាពស្មុគស្មាញ
- ជំរុញ និងប្រមូលមូលនិធិទាយជ្ជទានបរិស្ថាននៅមានកម្រិត
- សមត្ថភាពអ្នកពាក់ព័ន្ធដូចជាវិស័យឯកជន និងសង្គមស៊ីវិលនៅមានកម្រិត
- ដៃគូរអភិវឌ្ឍន៍តែងតែអនុវត្តគោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ខ្លួនដែលតែងតែខុសគ្នានឹងគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- សមត្ថភាពរបស់មន្ត្រីរាជការមួយចំនួននៅមានកម្រិតជាពិសេសមន្ត្រីថ្នាក់រាជធានី ខេត្ត។

### ៣.៥.២ ដំណោះស្រាយ

ទន្ទឹមនឹងបញ្ហាប្រឈមខាងលើ នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានដាក់ចេញនូវទិសដៅ និងយុទ្ធសាស្ត្រដូចខាងក្រោមៈ

- ការវាយតម្លៃបរិស្ថានយុទ្ធសាស្ត្រ
- ជំរុញការកសាងលិខិតបទដ្ឋានគតិយុត្តិ និងការអនុវត្តន៍ច្បាប់
- ពង្រឹងច្បាប់ដែលមានតម្រូវការសម្រាប់បង្កភាពងាយស្រួលដល់ការអនុវត្តការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថានឱ្យមានប្រសិទ្ធភាព (ក្រមបរិស្ថាន)
- បង្កើនគោលការណ៍ណែនាំតាមវិស័យ
- ការសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការកំណត់នូវអត្តសញ្ញាណរោងចក្រ ឬគម្រោងដែលត្រូវពិនិត្យ និងវាយតម្លៃ
- បង្កើនប្រសិទ្ធភាពការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍
- ជំរុញប្រសិទ្ធភាពការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍
- ជំរុញការចូលរួមជាសាធារណៈផ្សព្វផ្សាយពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដល់សាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ
- ការបណ្តុះបណ្តាលបច្ចេកវិទ្យា និងការអភិវឌ្ឍធនធានមនុស្សទាំងថ្នាក់ជាតិ និងក្រោមជាតិ តាមរយៈកម្មវិធីសិក្ខាសាលាក្នុង និងក្រៅប្រទេសបណ្តុះបណ្តាលមន្ត្រីមន្ទីរ រាជធានី ខេត្ត ចំនួនពីរដងក្នុងមួយឆ្នាំ។

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយបំភ្លឺទៅលើចំណុចជាច្រើនទាក់ទងទៅ និងប្រធានបទស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចមក ធ្វើឱ្យយើងខ្ញុំអាចសន្និដ្ឋានឱ្យដឹងថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិតជាមានសារៈសំខាន់បំផុតចំពោះការថែរក្សាការពារបរិស្ថានធនធានធម្មជាតិ និងការអភិវឌ្ឍសង្គមជាតិទាំងមូល។ បរិស្ថានពិតជាមានតួនាទីដ៏សំខាន់នូវក្នុងជីវិតរស់នៅប្រចាំថ្ងៃ បែបនេះហើយទើបក្រសួងបានបង្កើតនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះឡើង ក្នុងគោលបំណងធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោងមុនសាងសង់នឹងធ្វើការពិនិត្យតាមដានជារៀងរាល់៦ខែម្តង។ នាយកដ្ឋាននៃក្រសួងបរិស្ថានធ្វើការពិនិត្យ និងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងសាធារណៈ និងគម្រោងវិនិយោគឯកជនក្នុងគោលបំណងថែរក្សា និងគុណភាពបរិស្ថានឱ្យមានភាពគង់វង្សដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺធ្វើឡើងដើម្បីបញ្ចៀសរាល់បញ្ហាទាំងឡាយដែលបង្ហាញថាមានការបង្កគ្រោះថ្នាក់ ឬមានផលប៉ះពាល់ដោយសារគម្រោងណាមួយ នោះគម្រោងនោះនឹងត្រូវមានការកែប្រែ ឬធ្វើការបញ្ឈប់ភ្លាមៗ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានធ្វើឱ្យគម្រោងមានប្រសិទ្ធភាពខ្ពស់ និងធ្វើឱ្យម្ចាស់គម្រោងមានអទិភាពនូវក្នុងការកែសម្រួល និងទទួលបាននូវដំណោះស្រាយ និងមតិយបល់លើដំណើរការគម្រោងរបស់ពួកគេដើម្បីកុំឱ្យមានបញ្ហារាំងស្ទះ និងផលរំខាននូវពេលខាងមុខ។ បន្ទាប់ពីបានធ្វើការពិនិត្យវាយតម្លៃយ៉ាងម៉ដ្ឋចត់នឹងធ្វើការកែសម្រួលរួចមក ធ្វើឱ្យផលអវិជ្ជមានទាំងឡាយដែលផ្តល់ផលប៉ះពាល់ដល់បរិស្ថានមានការអន់ថយ និងសង្គមធ្វើឱ្យជាតិមានការរីកចម្រើន និងអភិវឌ្ឍទៅមុខ។ ចំណែកឯប្រជាជនក៏ទទួលបាននូវស្តង់ដានៃការរស់នៅប្រកបដោយសុខសុវត្ថិភាព ដោយមិនព្រួយបារម្ភនូវការរងឥទ្ធិពលអាក្រក់ពីផលប៉ះពាល់បរិស្ថាន។

សរុបមកវិញ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិតជាចាំបាច់នូវក្នុងការអនុវត្តនូវវិធានការណ៍ផ្សេងៗដើម្បីកុំឱ្យខាតបង់ពេលវេលានៅពេលដែលគម្រោងណាមួយបង្កផលប៉ះពាល់ទៅដល់បរិស្ថាន និងសង្គម។ មួយវិញទៀតផ្តល់ភាពងាយស្រួលដល់រាជរដ្ឋាភិបាលក្រសួងបរិស្ថាននូវក្នុងការពិនិត្យតាមដានវាយតម្លៃ និងផ្តល់នូវយុទ្ធសាស្ត្រផ្សេងៗក្នុងការអនុវត្តក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ដូច្នេះហើយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពិតជាមានតួនាទីយ៉ាងសំខាន់ណាស់នូវក្នុងការការពារបរិស្ថានធម្មជាតិ និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយបំភ្លឺទៅលើប្រធានបទ និងធ្វើការសន្និដ្ឋានជារួមរួចមក ក្នុងនាមយើងខ្ញុំជានិស្សិត និងជាទំពាំងស្នងឫស្សីនៃប្រទេសជាតិ យើងខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីអាចជួយពង្រឹង និងដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតដែលក្នុងនោះរួមមានដូចជា៖

- ពិនិត្យមើលស្ថានភាពបរិស្ថាន និងធនធានធម្មជាតិនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ហើយក្រសួងគួរតែបង្កើនការសហការជាមួយក្រសួងពាក់ព័ន្ធដទៃទៀត ដើម្បីកុំឱ្យមានការរំលងនូវគម្រោងថ្មីៗដែលគ្រោងនឹងបង្កើតនៅក្នុងប្រទេស
- ជំរុញ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីថ្នាក់ក្រោមជាតិក្នុងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីឱ្យពួកគាត់យកចិត្តទុកដាក់ធ្វើការស្វែងរកគម្រោងដែលត្រូវវាយតម្លៃ និងត្រួតពិនិត្យគម្រោងជាប្រចាំតាមគោលការណ៍ដែលកំណត់
- ពិនិត្យការអនុវត្តយុទ្ធសាស្ត្រមានស្រាប់ស្តីពីបរិស្ថាន ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍដោយចីរភាព និងកត់ត្រាមេរៀនទទួលបាន
- ផ្សព្វផ្សាយឱ្យទូលំទូលាយជាងនេះទៀត អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅដល់សាធារណជនទាំងឡាយ
- អនុវត្តច្បាប់ឱ្យតឹងរឹងចំពោះគម្រោងដែលមិនគោរពតាមគោលការណ៍ណែនាំរបស់ក្រសួង។

# ឯកសារយោង


## I. លិខិតបទដ្ឋានគតិយុត្តិ

១. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

២. ក្រមបរិស្ថាន និងធនធានធម្មជាតិ ឆ្នាំ២០២៣

៣. ព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ ឆ្នាំ១៩៩៣

៣. អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩

៤. អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ឆ្នាំ១៩៩៦

៥. អនុក្រឹត្យស្តីពីរៀបចំប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ឆ្នាំ២០២១

៦. ប្រកាសលក្ខខណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ២០២៤

៧. ប្រកាស ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩

៨. ប្រកាស ស្តីពីប្រតិភូកម្មអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងវិនិយោគឯកជន ឆ្នាំ២០២២

៩. កម្រងលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធ័និងកាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ២០២៣

១០. ប្រកាសស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់កាសិក្សា និងការរៀបចំរាបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឆ្នាំ២០១៤

## II. ឯកសារជាសៀវភៅ

១. សៀវភៅស្តីពីការអប់រំបរិស្ថាន និងអភិរក្សសត្វក្រៀល ឆ្នាំ២០១៩

២. សៀវភៅមគ្គុទ្ទេសក៏នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២

៣. សៀវភៅគម្រោងតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិប្រកបដោយនិរន្តរភាព(SLEPC) នៅកម្ពុជា ឆ្នាំ២០១៩

៤. សៀវភៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ ឆ្នាំ២០១៦

## III. គេហទំព័រ

១. https://www.moe.gov.kh/

២. https://km.wikipedia.org/wiki/

៣. https://www.information.gov.kh/

# ឧបសម្ព័ន្ធ

# អនុក្រឹត្យ

# ស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាននិងបណ្តាអង្គភាពក្រោមឱវាទក្រសួង។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២ .-**

ក្រសួងបរិស្ថានត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឱ្យដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ក្រសួងបរិស្ថានជាសេនាធិការរបស់រាជរដ្ឋាភិបាលមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំទស្សនវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- តាក់តែងនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនិងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ផ្តល់យោបល់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធានាការអភិរក្ស ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- គ្រប់គ្រងទិន្នន័យបរិស្ថាននិងដឹកនាំសម្របសម្រួលការងារអប់រំនិងការផ្សព្វផ្សាយបរិស្ថាន ព្រមទាំងចាត់ចែងព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងវិស័យបរិស្ថាន
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការផ្សព្វផ្សាយព័ត៌មាននិងសកម្មភាពបង្កើនការយល់ដឹងនានា
- លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព តាមរយៈការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចនានា
- ផលិតនិងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពទាក់ទងនឹងកិច្ចគាំពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិជូនសាធារណជន

- គ្រប់គ្រងនិងសម្របសម្រួលកិច្ចគាំពារបរិស្ថាន រួមមានការគ្រប់គ្រងគុណភាពទឹក ខ្យល់ និងដី ការគ្រប់គ្រងសំឡេងនិងរំញ័រ និងការគ្រប់គ្រងការបំភាយកាំរស្មីវិទ្យុសកម្មនិងអេឡិចត្រូម៉ាញ៉េទិក
- រៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- គ្រប់គ្រងនិងសម្របសម្រួលការងារការពារនិងអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព
- ប្រមូលវិភាគនិងគ្រប់គ្រងទិន្នន័យបរិស្ថាននិងធនធានធម្មជាតិ
- ជំរុញនិងលើកទឹកចិត្តឱ្យមានការវិនិយោគក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- កៀរគរនិងគ្រប់គ្រងធនធានសម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- សហការជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងពិភពលោក អង្គការជាតិ អង្គការអន្តរជាតិ និងសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យមានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការចូលរួមក្នុងកិច្ចព្រមព្រៀង អនុសញ្ញា និងពិធីសារអន្តរជាតិនានា ដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះនិងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងអនុវត្តកិច្ចការជំនាញពាក់ព័ន្ធសម្រាប់ជាមូលដ្ឋានជូនរាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ច និងការទទួលខុសត្រូវនៅក្រោមកិច្ចព្រមព្រៀងអនុសញ្ញានិងពិធីសារទាំងនេះ
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានទៀងទាត់
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។

**មាត្រា៤ .-**

ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**ក- អង្គភាពថ្នាក់ជាតិ**

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ
- អគ្គនាយកដ្ឋានគាំពារបរិស្ថាន
- អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ
- អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន
- អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- អង្គភាពថ្នាក់ក្រោមជាតិ

- មន្ទីរបរិស្ថានរាជធានី ខេត្ត។

គ- គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ

- គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថាន។

**មាត្រា៥ .-**

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូបនិងអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាននិងអង្គភាពថ្នាក់ស្មើនាយកដ្ឋានដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

មន្ទីរបរិស្ថានរាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់ក្រសួងបរិស្ថានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យនីមួយៗនិងអង្គភាពនានាក្រោមឱវាទនាយកដ្ឋាន និងអង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងបរិស្ថានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី១២
## នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៥៥ ៖**

នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងកិច្ចការពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងនិងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- រៀបចំនិងអនុវត្តវិធានផ្ទៃក្នុង សម្រាប់គ្រប់គ្រងការពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វិភាគ និងវាយតម្លៃសម្រាប់កំណត់ទីតាំងគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ពិនិត្យនិងវាយតម្លៃលើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីតម្រូវការសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន
- កំណត់លក្ខខណ្ឌការងារនិងគោលការណ៍បច្ចេកទេសសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង កិច្ចសន្យាការពារបរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានជាមួយម្ចាស់គម្រោងដែលរួមទាំងកម្រៃដែលត្រូវបង់ចូលមូលនិធិទាយជ្ជទានបរិស្ថាននិងមូលនិធិបរិស្ថាននិងសង្គម
- ពិនិត្យនិងផ្តល់យោបល់លើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមនៃគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន ព្រមទាំងដំណើរការទាំងមូលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ពិនិត្យនិងរៀបចំកិច្ចសន្យាការពារបរិស្ថាននិងផែនការគ្រប់គ្រងបរិស្ថានសម្រាប់គម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ពិនិត្យនិងវាយតម្លៃលើរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងវិនិយោគសាធារណៈនិងគម្រោងវិនិយោគឯកជន
- ជំរុញការអនុវត្តការបង់សេវាការងារសាធារណៈ មូលនិធិទាយជ្ជទានបរិស្ថាន និងថវិកាពិន័យអន្តរការណ៍
- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តការប្រមូលនិងការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម
- គ្រប់គ្រង ទទួលខុសត្រូវ និងសម្របសម្រួលការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ គណនេយ្យ ផែនការថវិការយៈពេលខ្លី មធ្យម និងវែង និងអង្កេតតាមដានការងារផ្ទៃក្នុងរបស់នាយកដ្ឋាន
- ជំរុញឱ្យមានការចូលរួមជាប្រចាំរបស់សាធារណជននិងការទទួលបានព័ត៌មាននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- កំណត់នីតិវិធីនិងលក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃក្រុមហ៊ុនដែលស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- សម្របសម្រួលការងារជាមួយបណ្តាអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងបរិស្ថាន អង្គភាពពាក់ព័ន្ធដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៅក្នុងកិច្ចដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- បំពេញការកិច្ចពង្រឹងសមត្ថភាពជំនាញការងារវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដល់អង្គភាពថ្នាក់ជាតិនិងអង្គភាពថ្នាក់ក្រោមជាតិ វិស័យឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍ និងភាគីពាក់ព័ន្ធ
- បំពេញការកិច្ចជាអង្គភាពបង្គោលជាតិនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។

## ជំពូកទី១៣
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា៥៦ .-**

នៅតាមរាជធានី ខេត្តនីមួយៗមានមន្ទីរបរិស្ថានរាជធានី ខេត្ត ចំនួនមួយ ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង។

ការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរបរិស្ថានរាជធានី ខេត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី១៤
## គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ

**មាត្រា៥៧ .-**

គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈនានាដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ជំពូកទី១៥
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា៥៨ .-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី១៦
## អន្តរប្បញ្ញត្តិ

**មាត្រា៥៩ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការបង្កើតអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ឧបសម្ព័ន្ធ

## នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន



# ប្រកាស

# ស្តីពី

# លក្ខខណ្ឌ និងនីតិវិធី សម្រាប់ចុះបញ្ជីទទួលស្គាល់

# ក្រុមហ៊ុនទីប្រឹក្សា

# វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:........០៧ ប្រ.ក......ប.ស្ត/៤២២

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌ និងនីតិវិធី សម្រាប់ចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលមាត្រា៤, មាត្រា៦, មាត្រា៨, មាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- បានឃើញប្រកាសលេខ៣៦៦ ប្រក ប.ស្ត ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ៣៧៦ ប្រក ប.ស្ត ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ
- យោងតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១**.-

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ នីតិវិធី និងលក្ខណៈសម្បត្តិសម្រាប់ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងលក្ខខណ្ឌនៃការព្យួរ និងការលុបចោលការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ដើម្បីឆ្លើយតបទៅនឹងភាពស្អាត ភាពបៃតង និងចីរភាព។

**ប្រការ២**.-

ក្រុមហ៊ុនដែលមានបំណងធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវស្នើសុំចុះបញ្ជីទទួលស្គាល់នៅក្រសួងបរិស្ថាន ឬតាមប្រព័ន្ធអនឡាញ ផ្អែកលើគោលការណ៍ណែនាំដែលកំណត់ដោយក្រសួងបរិស្ថាន។

ក្រុមហ៊ុនទាំងឡាយណាដែលមិនបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន មិនអាចធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានឡើយ។

**ប្រការ៣**.-

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះគ្រប់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤**.-

បច្ចេកសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** សំដៅដល់ក្រុមហ៊ុនដែលបានទទួលស្គាល់ពីក្រសួងបរិស្ថាន សម្រាប់ធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។
- **លិខិតឯកភាពការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** សំដៅដល់លិខិតឯកភាព ដែលចេញដោយក្រសួងបរិស្ថានចំពោះក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ជំពូកទី២
## លិខិតឯកភាពលើការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា
## វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**ប្រការ៥**.-

ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចបំពេញបែបបទ ដើម្បីទទួលបានការចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន ជាក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ការឯកភាពលើការចុះបញ្ជីទទួលស្គាល់ជាក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបាន ផ្តល់ជូនក្រុមហ៊ុន បន្ទាប់ពីក្រសួងបរិស្ថានបានពិនិត្យឃើញថា ក្រុមហ៊ុនបានបំពេញបែបបទស្នើសុំត្រឹមត្រូវ និងលទ្ធផលនៃការចុះត្រួតពិនិត្យវាយតម្លៃនៅទីតាំងផ្ទាល់បានឆ្លើយតបតាមការតម្រូវ។

**ប្រការ៦**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិ ស្តីពីគោលការណ៍ណែនាំក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ព្រមទាំងលិខិត បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។

**ប្រការ៧**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងអាជ្ញាធរ មានសមត្ថកិច្ចពាក់ព័ន្ធលើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ជំពូកទី៣
## លក្ខខណ្ឌ និងលក្ខណៈសម្បត្តិក្នុងការទទួលបាន
## ការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**ប្រការ៨**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ពាក្យស្នើសុំ ០៣ច្បាប់
- លិខិតចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ០៣ច្បាប់
- លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុន/កន្លែងស្នាក់នៅដោយអាជ្ញាធរមូលដ្ឋាន ០៣ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន ០៣ច្បាប់
- វចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ០៣ច្បាប់
- សារពើក្រុមហ៊ុន ០៣ច្បាប់
- ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ផ្សេងៗ។

**ប្រការ៩**.-

ក្រុមហ៊ុនទីប្រឹក្សាបរទេសត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៨ និងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**ប្រការ១០**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងយ៉ាងតិច នាយកក្រុមហ៊ុន អ្នកគ្រប់គ្រងទូទៅ ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងជំនួយការបច្ចេកទេស។ ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពទាំងនេះ ក្រុមហ៊ុនត្រូវជូនដំណឹងជាមុនមកក្រសួងបរិស្ថាន មិនឱ្យលើសពីរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ១១**.-

នាយកក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
- មានបទពិសោធន៍ក្នុងការគ្រប់គ្រងទូទៅ ឬបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម យ៉ាងតិច ០៥(ប្រាំ)ឆ្នាំ និងធ្លាប់បានចូលរួមបណ្តុះបណ្តាល ឬសិក្ខាសាលា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**ប្រការ១២**.-

អ្នកគ្រប់គ្រងទូទៅក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) ឬសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានបទពិសោធន៍បោះពុម្ពឯកសារស្រាវជ្រាវនៅក្នុងស្រុក ឬក្រៅស្រុកយ៉ាងតិច ០៣(បី)ឆ្នាំ
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល និងសំណង់។ល។

**ប្រការ១៣**.-

ប្រធានក្រុមបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានលក្ខណៈ-សម្បត្តិដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) ឬសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ

- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល និងសំណង់។ល។

**ប្រការ១៤.-**

អ្នកជំនាញការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៣(បី)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៣(បី)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល និងសំណង់។ល។

**ប្រការ១៥.-**

អ្នកជំនួយការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬបរិញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០១(មួយ)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានការយល់ដឹងទូទៅស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បទដ្ឋានច្បាប់ និងបច្ចេកទេសនានាពាក់ព័ន្ធនឹងបរិស្ថាន។

## ជំពូកទី៤
## ការបង់កម្រៃសេវា

**ប្រការ១៦.-**

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបង់ថ្លៃសេវាសាធារណៈសម្រាប់ការចុះបញ្ជីទទួលស្គាល់ដល់ក្រសួងបរិស្ថាន អនុលោមតាមប្រកាសអន្តរក្រសួង របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## ជំពូកទី៥
## សុពលភាព ការព្យួរ និងការលុបចោល
## លិខិតឯកភាពលើការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា
## វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**ប្រការ១៧**.-

លិខិតឯកភាពលើការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសុពលភាព ០៥(ប្រាំ)ឆ្នាំ។

**ប្រការ១៨**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានបំណងបន្តផ្តល់សេវាសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ឡើងវិញមកក្រសួងបរិស្ថានយ៉ាងតិចបំផុតរយៈពេល ០៣(បី) ខែ មុនថ្ងៃផុតសុពលភាព។

**ប្រការ១៩**.-

លិខិតឯកភាពលើការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានព្យួរពីរយៈពេល ០៦(ប្រាំមួយ)ខែ ដល់ ០៣(បី)ឆ្នាំ ក្នុងករណីណាមួយដូចខាងក្រោម៖

- ក្រុមហ៊ុនទីប្រឹក្សាមានកំហុសដោយធ្វេសប្រហែសនៅក្នុងការចុះសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ក្រុមហ៊ុនទីប្រឹក្សាបានចម្លងទិន្នន័យពីឯកសារ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមផ្សេងៗ ដោយគ្មានឯកសារយោង
- ក្រុមហ៊ុនទីប្រឹក្សាខកខានមិនបានជូនដំណឹងមកក្រសួងបរិស្ថាន ដូចមានចែងក្នុងប្រការ១៨។

**ប្រការ២០**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានលុបចោល ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនទីប្រឹក្សានៅតែបំពានលក្ខខណ្ឌក្នុងប្រការ១៩
- ក្រុមហ៊ុនទីប្រឹក្សាមានកំហុសចេតនាដោយមិនបង្ហាញពីហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានតាមលទ្ធផលជាក់ស្តែងនៃការសិក្សា
- ក្រុមហ៊ុនទីប្រឹក្សាត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ក្នុងករណីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គ្មានគុណភាព និង/ឬមានការភូតកុហកក្លែងបន្លំធ្ងន់ធ្ងរ ដែលបណ្តាលឱ្យខូចខាតដល់ផលប្រយោជន៍ជាតិ។

**ប្រការ២១**.-

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនអាចដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ឡើងវិញឡើយ ក្នុងរយៈពេល ០៥(ប្រាំ)ឆ្នាំ បន្ទាប់ពីលិខិតឯកភាពការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានលុបចោល។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**ប្រការ២២.-**

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះបញ្ជីនៅក្រសួងបរិស្ថានរួចរាល់មុនខែសីហា ឆ្នាំ២០២៣ ត្រូវចុះបញ្ជីទទួលស្គាល់ឡើងវិញនៅក្រសួងបរិស្ថាន។

ក្នុងករណីដែលលិខិតឯកភាពការចុះបញ្ជីទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនត្រូវបានផ្តល់ឡើងវិញដូចចែងក្នុងកថាខណ្ឌខាងលើ ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ចប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលនៅសេសសល់ក្នុងរយៈពេល ០៦ខែ គិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គាធិការ ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត និងគ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨ រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ប្រកាស

# ស្តីពី

## គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

# ប្រកាស

# ស្តីពី

# ប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៣៥៦ ប្រ.ក ប.ស្ថ

# ប្រកាស
## ស្តីពី
## ប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន



អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- បានឃើញប្រកាសលេខ៣៦៦ ប្រក ប.ស្ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសអន្តរក្រសួងលេខ១៧៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ ដោយក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ៣៧៦ ប្រក ប.ស្ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ
- បានឃើញប្រកាសលេខ០២១ ប្រក ប.ស្ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១..**

ប្រកាសនេះមានគោលបំណងធ្វើប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីពិនិត្យ ផ្តល់យោបល់ និងសម្រេច លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន ដែលមានទំហំទុនវិនិយោគក្រោម ៥(ប្រាំ) លានដុល្លារអាមេរិកចុះ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២..**

គម្រោងវិនិយោគដូចខាងក្រោម មិនត្រូវឆ្លងការពិនិត្យ ផ្តល់យោបល់ និងសម្រេច លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ពីមន្ទីរបរិស្ថានរាជធានី ខេត្ត ទេ ដោយត្រូវឆ្លងតាមយន្តការក្រសួងបរិស្ថាន៖

- គម្រោងវិនិយោគ ដែលមានទុនវិនិយោគចាប់ពី ៥(ប្រាំ) លានដុល្លារអាមេរិក ឡើងទៅ
- គម្រោងវិនិយោគ ដែលមានទីតាំងស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ចាប់ពី ២(ពីរ) ឡើងទៅ
- គម្រោងវិនិយោគ ដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស
- គម្រោងវិនិយោគ ដែលស្ថិតក្រោមច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន

- គម្រោងវិនិយោគ ដែលមានវេទយិតភាពខាងនយោបាយ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬប៉ះពាល់ដល់សន្តិសុខជាតិ ឬប៉ះពាល់ដល់ការងារអភិរក្ស និងការពារជីវៈចម្រុះ ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ជាតិ
- គម្រោងវិនិយោគ ពាក់ព័ន្ធនឹងការរុករក និងធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិ
- គម្រោងវិនិយោគ ពាក់ព័ន្ធនឹងវិស័យថាមពល
- គម្រោងវិនិយោគ ដែលស្ថិតនៅក្នុងបញ្ជីអវិជ្ជមានដែលនៅជាធរមាន។

## ជំពូកទី២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត មានតួនាទី និងភារកិច្ចពិនិត្យ ផ្តល់យោបល់ និងសម្រេច លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ដោយអនុលោមតាមអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ប្រការ ៤.-**

ក្នុងករណី មន្ទីរបរិស្ថានរាជធានី ខេត្ត ស្នើសុំក្រសួងបរិស្ថានពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាននៃគម្រោងវិនិយោគឯកជន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ក្រសួងបរិស្ថានទទួលយកមកពិនិត្យ និងសម្រេច លើគម្រោងស្នើសុំ ដោយផ្អែកលើទំហំនៃគម្រោង និងការប៉ះពាល់ដល់បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**ប្រការ ៥.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ជូនក្រសួងបរិស្ថាន លើការពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬកិច្ចសន្យាការពារបរិស្ថាន តាមរយៈការប្រគិភូកម្មសិទ្ធិអំណាច ដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងការអនុវត្តការងារដែលបានទទួលប្រគិភូកម្មសិទ្ធិអំណាច ដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាននៃក្រសួងបរិស្ថាន អគ្គាធិការ ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គ្រប់ប្រធានអង្គភាពចំណុះក្រសួងបរិស្ថាន និងប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១៥ រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៨ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ......៣៥៦..........ចុះថ្ងៃទី......២៣..........ខែ....វិច្ឆិកា......ឆ្នាំ២០២២
ស្តីពីប្រតិភូកម្មសិទ្ធិអំណាចជូនមន្ទីរបរិស្ថានរាជធានី ខេត្ត
លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងវិនិយោគឯកជន

| ល.រ | ប្រភេទគម្រោង | ទំហំគម្រោង |
|---|---|---|
| ក. វិស័យឧស្សាហកម្ម | | |
| ១ | រោងចក្រកាត់ដេរ ចាក់ ប៉ាក់ សម្លៀកបំពាក់ | គ្រប់ទំហំ |
| ២ | រោងចក្រផលិតសំឡី | គ្រប់ទំហំ |
| ៣ | រោងចក្រផលិតឆ័ត្រ អាវភ្លៀង | គ្រប់ទំហំ |
| ៤ | រោងចក្រផលិតស្បែកជើង គ្រឿងបន្សំស្បែកជើង | គ្រប់ទំហំ |
| ៥ | រោងចក្រផលិតម្សៅសាប៊ូ សាប៊ូដុំ សាប៊ូទឹក | គ្រប់ទំហំ |
| ៦ | រោងចក្រផលិតធ្យូងអនាម័យ | គ្រប់ទំហំ |
| ៧ | រោងចក្រផលិតចាន ឆ្នាំង កែវ សម្ភារប្រើប្រាស់ផ្ទះបាយ | គ្រប់ទំហំ |
| ៨ | រោងចក្រផលិតទឹកសុទ្ធ | គ្រប់ទំហំ |
| ៩ | រោងចក្រផលិតក្រដាសអនាម័យពាក់កណ្តាលសម្រេច | គ្រប់ទំហំ |
| ១០ | រោងចក្រធ្វើរានទេវតា គ្រឿងបង្គុំទីសក្ការៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១១ | រោងចក្រផលិតបាវ | គ្រប់ទំហំ |
| ១២ | រោងចក្រផលិតគ្រឿងបន្សំសម្លៀកបំពាក់ | គ្រប់ទំហំ |
| ១៣ | រោងចក្រសម្ងួតគ្រាប់ធញ្ញជាតិ | គ្រប់ទំហំ |
| ១៤ | រោងចក្រផលិតកាបូប គ្រឿងបន្សំកាបូបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៥ | រោងចក្រផលិតខ្សែយឺតចង្កេះខោសម្រាប់ផ្គត់ផ្គង់ | គ្រប់ទំហំ |
| ១៦ | រោងចក្រផលិតអំបោះ ខារអំបោះដេរ ផលិតស្តុកបិត | គ្រប់ទំហំ |
| ១៧ | រោងចក្រផលិតខ្សែក្រវ៉ាត់គ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៨ | រោងចក្រផលិតកេសកាតុង និងសម្ភារវេចខ្ចប់គ្រប់ប្រភេទ | គ្រប់ទំហំ |
| ១៩ | រោងចក្រផលិតឡេវ ខ្សែរូតគ្រប់ប្រភេទ | គ្រប់ទំហំ |
| ២០ | រោងចក្រផលិតសម្ភារស្ទូចត្រីគ្រប់ប្រភេទ | គ្រប់ទំហំ |

| | | |
|---|---|---|
| ២១ | រោងចក្រផលិតទឹកត្រី ស៊ីអ៊ីវ សៀង ម្ទេស ប៉េងប៉ោះ | គ្រប់ទំហំ |
| ២២ | មូលដ្ឋានផលិតអាកុល | គ្រប់ទំហំ |
| ២៣ | មូលដ្ឋានផលិតភេសជ្ជៈ ទឹកក្រូច ទឹកផ្លែឈើគ្រប់ប្រភេទ | គ្រប់ទំហំ |
| ២៤ | មូលដ្ឋានផលិតគ្រឿងសង្ហារិម | គ្រប់ទំហំ |
| ២៥ | មូលដ្ឋានផលិតម្សៅអង្ករ | គ្រប់ទំហំ |
| ២៦ | មូលដ្ឋានផលិតឥដ្ឋ ក្បឿង ឥដ្ឋក្រាល ឥដ្ឋការ៉ូ | គ្រប់ទំហំ |
| ២៧ | មូលដ្ឋានផលិតអំបិល កែច្នៃអំបិល | គ្រប់ទំហំ |
| ២៨ | មូលដ្ឋានផលិតចំណីសត្វ | គ្រប់ទំហំ |
| ២៩ | មូលដ្ឋានកែច្នៃសំណល់ទីប្រជុំជន | គ្រប់ទំហំ |
| ខ. វិស័យកសិកម្ម | | |
| ៣០ | ប្រព័ន្ធស្រោចស្រព | <១ ០០០ហិកតា |
| ៣១ | ប្រព័ន្ធដោះទឹក | < ១ ០០០ហិកតា |
| ៣២ | ផ្ទៃដីកសិ-ឧស្សាហកម្ម ( ដីមិនមានគម្របព្រៃឈើ) | ≤១០០ហិកតា |
| ៣៣ | កសិដ្ឋានចិញ្ចឹមសត្វពាហនៈ (គោ ក្របី សេះ ជ្រូក ពពែ ចៀម ) | ២០ក្បាល - ៥០០ក្បាល |
| ៣៤ | កសិដ្ឋានចិញ្ចឹមសត្វស្លាប | ២.០០០ក្បាល - ៥០.០០០ក្បាល |
| ៣៥ | កសិដ្ឋានចិញ្ចឹមសត្វល្មូន | ១០០ក្បាល - ៥០០ក្បាល |
| ៣៦ | វារីវប្បកម្មទឹកសាប ទឹកប្រៃ | ១ហិកតា - ១០ហិកតា |
| ៣៧ | ទីសត្តឃាត | គ្រប់ទំហំ |
| ៣៨ | មូលដ្ឋានស្តុក និងលក់ថ្នាំកសិកម្ម | < ១០.០០០ តោន/១ឆ្នាំ |
| ៣៩ | កសិដ្ឋានចិញ្ចឹមសត្វស្វា ទោច ទន្សាយ | ១០០ក្បាល - ១.០០០ក្បាល |
| ៤០ | កសិដ្ឋានចិញ្ចឹមសត្វល្អិត | គ្រប់ទំហំ |
| ៤១ | អាជីវកម្មផ្ទះត្រចៀកកាំ | គ្រប់ទំហំ |
| ៤២ | កសិដ្ឋានដាំដំណាំក្នុងផ្ទះសំណាញ់ | គ្រប់ទំហំ |
| គ. វិស័យសុខាភិបាល | | |
| ៤៣ | មន្ទីរ ឬបន្ទប់ពិគ្រោះ និងព្យាបាលជម្ងឺ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៤៤ | មន្ទីរពេទ្យបង្អែកស្រុក | គ្រប់ទំហំ |
| ៤៥ | មណ្ឌលលាងឈាម | គ្រប់ទំហំ |
| ៤៦ | មន្ទីរពហុព្យាបាល មន្ទីរព្យាបាល សម្ភព | គ្រប់ទំហំ |
| ៤៧ | មណ្ឌលសុខភាព | គ្រប់ទំហំ |
| ៤៨ | ឃ្លាំងឱសថ | ផ្ទៃក្រឡាសំណង់ ≤ ៣០០០ ម៉ែត្រការ៉េ |
| ៤៩ | សិប្បកម្មផលិតថ្នាំពេទ្យ និងបរិក្ខារពេទ្យ | គ្រប់ទំហំ |
| ៥០ | មូលដ្ឋានកែច្នៃសំណល់វេជ្ជសាស្ត្រ | គ្រប់ទំហំ |
| **ឃ. វិស័យទេសចរណ៍** | | |
| ៥១ | តំបន់ទេសចរណ៍ (ក្រៅពីតំបន់ការពារធម្មជាតិ តំបន់បេតិកភណ្ឌ តំបន់កោះ) | < ១០ហិកតា |
| ៥២ | អាជីវកម្មខារ៉ាអូខេ រង្គសាល បៀរហ្គាដេន និងឌីស្កូតែក | < ៣០០០ម៉ែត្រការ៉េ |
| ៥៣ | ទីលានវាយកូនគោល | < ១៨ រន្ធ |
| ៥៤ | ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ | គ្រប់ទំហំ |
| ៥៥ | ភោជនីយដ្ឋានបណ្តែតទឹក | គ្រប់ទំហំ |
| ៥៦ | សេវាកម្មទូកទេសចរណ៍ | គ្រប់ទំហំ |
| **ង. វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | |
| ៥៧ | សំណង់អាគារ | ៥០០ម៉ែត្រការ៉េ - ៣០០០ម៉ែត្រការ៉េ |
| ៥៨ | សណ្ឋាគារ ឬផ្ទះសំណាក់ (លើកលែងតែសំណង់នៅក្នុង ឬនៅជាប់តំបន់ការពារធម្មជាតិ តំបន់បេតិកភណ្ឌ តំបន់ឆ្នេរ តំបន់មាត់ទន្លេ តំបន់កោះ) | < ១០០បន្ទប់ |
| ៥៩ | សំណង់ផ្លូវជនបទ ឬផ្លូវខេត្ត | គ្រប់ទំហំ |
| ៦០ | បណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន | គ្រប់ទំហំ |
| ៦១ | បណ្តាញខ្សែកាបអុបទិកលើគោក (ក្រៅតំបន់ការពារធម្មជាតិ) | គ្រប់ទំហំ |
| **ច. វិស័យរ៉ែ ថាមពល** | | |
| ៦២ | អាជីវកម្មរ៉ែសំណង់គ្រប់ប្រភេទ មានដូចជា ថ្មកំបោរ ថ្មម៉ាប ថ្មភក់ ថ្មបំបែក ថ្មបាយក្រៀម ក្រួស ខ្សាច់ ឡាតេរីត អាចម៍ដី ដីឥដ្ឋ ហ្វូស្វាត កៅឡាំង ។ល។ និងរ៉ែផ្សេងទៀតដែលមាន | ≤ ១ ហិកតា និងមានជម្រៅ≤ ៥ម៉ែត្រ |

| | | |
|---|---|---|
| | លក្ខណៈជាសិប្បកម្ម | |
| ៦៣ | មូលដ្ឋានស្តុកខ្សាច់ ថ្ម | គ្រប់ទំហំ |
| ៦៤ | ស្ថានីយប្រេងឥន្ធនៈ ឬដេប៉ូប្រេងឥន្ធនៈ | < ៨.០០០លីត្រ |
| ៦៥ | ស្ថានីយស្តុក និងលក់ហ្គាស ឬដេប៉ូស្តុក និងលក់ហ្គាស | < ៨.០០០លីត្រ |
| ៦៦ | ខ្សែបញ្ជូនអគ្គិសនីដែលមានតង់ស្យុង | ≤ ២២KV |
| **ធ. វិស័យសិប្បកម្មប្រភេទខ្នាតតូច មធ្យម** | | |
| ៦៧ | សិប្បកម្មផលិតទ្វារដែក ផ្សារដែក កញ្ចក់ | គ្រប់ទំហំ |
| ៦៨ | សិប្បកម្មក្រឡឹងគ្រឿងម៉ាស៊ីន | គ្រប់ទំហំ |
| ៦៩ | សិប្បកម្មផលិតក្រដាស | គ្រប់ទំហំ |
| ៧០ | សិប្បកម្មបោះពុម្ពឯកសារ សារព័ត៌មាន | គ្រប់ទំហំ |
| ៧១ | សិប្បកម្មផលិតគ្រឿងសង្ហារិម | គ្រប់ទំហំ |
| ៧២ | សហគ្រាសជួសជុលគ្រឿងយន្ត | គ្រប់ទំហំ |
| ៧៣ | សិប្បកម្មបកក្លាម បង្គារ | គ្រប់ទំហំ |
| ៧៤ | សិប្បកម្មកែច្នៃថ្មអារ | គ្រប់ទំហំ |
| ៧៥ | សិប្បកម្មអារឈើ | គ្រប់ទំហំ |
| ៧៦ | សិប្បកម្មផលិតទុយោជ័រ | គ្រប់ទំហំ |
| ៧៧ | សិប្បកម្មផលិតស្បោងប្លាស្ទិក និងសម្ភារៈពីប្លាស្ទិក ផលិតធុងជ័រ | គ្រប់ទំហំ |
| ៧៨ | សិប្បកម្មផលិតបារី | គ្រប់ទំហំ |
| ៧៩ | សិប្បកម្មផលិតសសរគ្រឹះ បង្គោលបេតុង ជើងតាង ពាង លូ ឥដ្ឋការ៉ូ | គ្រប់ទំហំ |
| ៨០ | សិប្បកម្មបញ្ចូលអាគុយ | គ្រប់ទំហំ |
| ៨១ | សិប្បកម្មហាលកសិផលកសិកម្ម | គ្រប់ទំហំ |
| ៨២ | សិប្បកម្មកែច្នៃអំបិលអ៊ីយ៉ូត | ≥ ១០០តោន/ឆ្នាំ |
| ៨៣ | សិប្បកម្មផលិតសាប៊ូទឹក | គ្រប់ទំហំ |
| ៨៤ | សិប្បកម្មផលិតធុងជ័រ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៨៥ | សិប្បកម្មផលិតទឹកផ្លែឈើកញ្ចប់ | គ្រប់ទំហំ |
| ៨៦ | សិប្បកម្មផលិតក្តារបន្ទះ កុងផ្លាកេ | គ្រប់ទំហំ |
| ៨៧ | សិប្បកម្មផលិតចំណីសត្វ | គ្រប់ទំហំ |
| ៨៨ | សិប្បកម្មផលិតស្រា ស្រាបៀ | គ្រប់ទំហំ |
| ៨៩ | សិប្បកម្មកែច្នៃសម្ភារពីកៅស៊ូ | គ្រប់ទំហំ |
| ៩០ | សិប្បកម្មកាត់ដេរ បោះពុម្ពលើសម្លៀកបំពាក់ | គ្រប់ទំហំ |
| ៩១ | សិប្បកម្មផលិតទឹកសុទ្ធ | គ្រប់ទំហំ |
| ៩២ | សិប្បកម្មផលិតទឹកស្អាត | គ្រប់ទំហំ |
| ៩៣ | សិប្បកម្មផលិតទឹកកក | គ្រប់ទំហំ |
| ៩៤ | សិប្បកម្មផលិតសសៃគុយទាវ មី នំបញ្ចុក | គ្រប់ទំហំ |
| ៩៥ | សិប្បកម្មផលិតពពុះសណ្តែក | គ្រប់ទំហំ |
| ៩៦ | សិប្បកម្មផលិតទឹកត្រី ទឹកស៊ីអ៊ីវ ទឹកខ្មេះ ទឹកសៀង ទឹកម្ទេស | គ្រប់ទំហំ |
| ៩៧ | សិប្បកម្មផលិតនំ និងស្ករគ្រាប់ | គ្រប់ទំហំ |
| ៩៨ | សិប្បកម្មផលិតនំប៉័ង | គ្រប់ទំហំ |
| ៩៩ | សិប្បកម្មផលិតពូក ខ្នើយ | គ្រប់ទំហំ |
| ១០០ | សិប្បកម្មត្បាញសូត្រ ក្រម៉ា | គ្រប់ទំហំ |
| ១០១ | សិប្បកម្មកែច្នៃរតនវត្ថុ | គ្រប់ទំហំ |
| ១០២ | សិប្បកម្មផលិតចាន ឆ្នាំង ខ្ទះ និងសម្ភារផ្ទះបាយ | គ្រប់ទំហំ |
| ១០៣ | សិប្បកម្មផលិតទៀន ធូប | គ្រប់ទំហំ |
| ១០៤ | សិប្បកម្មផលិតឥដ្ឋ ក្បឿង ការ៉ូ | គ្រប់ទំហំ |
| ១០៥ | សិប្បកម្មផលិតចង្ក្រាន | គ្រប់ទំហំ |
| ១០៦ | សិប្បកម្មផលិតប្រេងសណ្តែក និងប្រេងចំអិនផ្សេងៗ | គ្រប់ទំហំ |
| ១០៧ | សិប្បកម្មកិនស្រូវ | < ៣០០០ តោន/ឆ្នាំ |
| ១០៨ | សិប្បកម្មសង្កត់ពុម្ពស័ង្កសី និងលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១០៩ | សិប្បកម្មកាត់ដេរ ប៉ាក់ វេចខ្ចប់បោះពុម្ពសម្លៀកបំពាក់ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១១០ | សិប្បកម្មផលិតពុម្ពស្បែកជើង | គ្រប់ទំហំ |
| ១១១ | សិប្បកម្មជ្រលក់ពណ៌ និងខាត់អំបោះ | គ្រប់ទំហំ |
| ១១២ | សិប្បកម្មកែច្នៃកម្ទេចកំណាត់ | គ្រប់ទំហំ |
| ១១៣ | អាជីវកម្មស្តុកស្បែកសត្វ | គ្រប់ទំហំ |
| ១១៤ | សិប្បកម្មផលិតសម្បកទូក និងអូរបេរស្នាច់ | គ្រប់ទំហំ |
| ១១៥ | មូលដ្ឋានប្រមូលទិញ និងស្តុកអេតចាយ | គ្រប់ទំហំ |
| ១១៦ | យានដ្ឋានជួសជុលយានយន្ត តោន បាញ់ថ្នាំរថយន្ត | គ្រប់ទំហំ |
| ១១៧ | មូលដ្ឋានលាងរថយន្ត | គ្រប់ទំហំ |

# ប្រកាស

# ស្តីពី

## ការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃ

## ហេតុប៉ះពាល់បរិស្ថាន និងសង្គម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ :....២១៤....ប្រក.... ប.ស្ក

# ប្រកាស
# ស្តីពី
# ការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន និងសង្គម

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ ៣៤៦ ប្រក.សសរ.បស្ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញប្រកាសលេខ ៣៧៦ ប្រក.បស្ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១**.-

ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខខណ្ឌនៃការចុះបញ្ជី និងលក្ខណៈវិនិច្ឆ័យរបស់ក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ប្រកបដោយគុណភាព ប្រសិទ្ធភាព និងតម្លាភាព ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព។

**ប្រការ២**.-

ក្រុមហ៊ុនទីប្រឹក្សាដែលមានបំណងធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន។

ក្រុមហ៊ុនទីប្រឹក្សាទាំងឡាយណាដែលមិនបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន មិនអាចធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមបានឡើយ។

**ប្រការ៣**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ពាក្យស្នើសុំ ០៣ច្បាប់
- លិខិតចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ០៣ច្បាប់
- លិខិតបញ្ជាក់ទីតាំងការិយាល័យក្រុមហ៊ុនដោយអាជ្ញាធរមូលដ្ឋាន ០៣ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន ០៣ច្បាប់
- រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ០៣ច្បាប់
- សាវតាក្រុមហ៊ុន ០៣ច្បាប់
- ឯកសារពាក់ព័ន្ធ និងបទពិសោធន៍ផ្សេងៗ

**ប្រការ៤**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវមាននាយកក្រុមហ៊ុន ប្រធានក្រុមបច្ចេកទេស អ្នកជំនាញការបច្ចេកទេស និងជំនួយការបច្ចេកទេស។ ក្នុងករណីមានការផ្លាស់ប្តូរសមាសភាពទាំងនេះ ក្រុមហ៊ុនទីប្រឹក្សាត្រូវជូនដំណឹងមកក្រសួងបរិស្ថាន ត្រឹមរយៈពេលយ៉ាងយូរបំផុតត្រឹម ៣០(សាមសិប)ថ្ងៃ។

**ប្រការ៥**.-

នាយកក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
- មានបទពិសោធន៍ក្នុងការគ្រប់គ្រងទូទៅ ឬបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គម យ៉ាងតិច ០៥(ប្រាំ)ឆ្នាំ និងធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។



ម៉ា

**ប្រការ៦**.-

ប្រធានក្រុមបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់សមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៥(ប្រាំ)ឆ្នាំ
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់ ។ល។

**ប្រការ៧**.-

អ្នកជំនាញការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថានទូទៅយ៉ាងតិច ០៣(បី)ឆ្នាំ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថានយ៉ាងតិច ០៣(បី)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានសមត្ថភាពបច្ចេកទេសខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬជំនាញបរិស្ថាន ព្រៃឈើ ជលផល សំណង់ ។ល។

**ប្រការ៨**.-

អ្នកជំនួយការបច្ចេកទេសរបស់ក្រុមហ៊ុនទីប្រឹក្សា ត្រូវមានលក្ខណៈវិនិច្ឆ័យ ដូចតទៅ៖

- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលផ្នែកវិទ្យាសាស្ត្រ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារបរិស្ថានយ៉ាងតិច ០១(មួយ)ឆ្នាំ
- មានវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មានការយល់ដឹងទូទៅស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បទដ្ឋានច្បាប់ និងបច្ចេកទេសនានាពាក់ព័ន្ធនឹងបរិស្ថាន។

**ប្រការ៩**.-

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបង់ថ្លៃសេវាចុះបញ្ជីដល់ក្រសួងបរិស្ថាន។ ថ្លៃសេវានេះ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១០**.-

ក្រសួងបរិស្ថានផ្តល់វិញ្ញាបនបត្រទទួលស្គាល់ ដែលមានសុពលភាពសម្រាប់រយៈពេល ០៥(ប្រាំ)ឆ្នាំ ដល់ក្រុមហ៊ុនទីប្រឹក្សា ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងប្រការ៣ ដល់ប្រការ៩ នៃប្រកាសនេះ។

**ប្រការ១១**.-

ក្រុមហ៊ុនទីប្រឹក្សាបរទេស ត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាក្នុងស្រុកដែលបានចុះបញ្ជីទទួលស្គាល់ពីក្រសួងបរិស្ថាន ដើម្បីធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។



ៀ

**ប្រការ១២**.-

ក្រុមហ៊ុនទីប្រឹក្សា ដែលមានបំណងបន្តផ្តល់សេវាសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់សារជាថ្មី មកក្រសួងបរិស្ថានយ៉ាងតិចបំផុតរយៈពេល ០៣ (បី) ខែ មុនថ្ងៃអស់សុពលភាពនៃវិញ្ញាបនបត្រនេះ។

**ប្រការ១៣**.-

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិស្តីពីគោលការណ៍ណែនាំក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ព្រមទាំងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។

**ប្រការ១៤**.-

វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានព្យួរពីរយៈពេល ០៦ (ប្រាំមួយ) ខែ ដល់ ០៣ (បី) ឆ្នាំ ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនមានកំហុសដោយការធ្វេសប្រហែសនៅក្នុងការចុះសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- ក្រុមហ៊ុនបានចម្លងទិន្នន័យពីឯកសារ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមផ្សេងៗ ដោយគ្មានឯកសារយោង
- ក្រុមហ៊ុនខកខានមិនបានជូនដំណឹងមកក្រសួងបរិស្ថានដូចមានចែងក្នុងប្រការ៤។

**ប្រការ១៥**.-

វិញ្ញាបនបត្រទទួលស្គាល់ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានលុបចោល ក្នុងករណីដូចខាងក្រោម៖

- ក្រុមហ៊ុនទីប្រឹក្សានៅតែបំពានលក្ខខណ្ឌចែងក្នុងប្រការ១៤
- ក្រុមហ៊ុនមានកំហុសចេតនាដោយមិនបង្ហាញពីហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមានតាមលទ្ធផលជាក់ស្តែងនៃការសិក្សា
- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គ្មានគុណភាព និង/ឬមានការភូតកុហកក្លែងបន្លំធ្ងន់ធ្ងរ ដែលបណ្តាលឱ្យខូចខាតដល់ផលប្រយោជន៍ជាតិ
- ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ។

**ប្រការ១៦**.-

ក្រុមហ៊ុនទីប្រឹក្សាមិនអាចដាក់ពាក្យស្នើសុំចុះបញ្ជីទទួលស្គាល់ឡើងវិញ ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីវិញ្ញាបនបត្រទទួលស្គាល់ត្រូវបានលុបចោល។

**ប្រការ១៧**.-

ក្រុមហ៊ុនទីប្រឹក្សាត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ លើការសិក្សា និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

**ប្រការ១៨**.-

ក្រុមហ៊ុនទីប្រឹក្សា ដែលបានចុះបញ្ជីមុនការចូលជាធរមាននៃប្រកាសនេះ ត្រូវដាក់ពាក្យសុំចុះបញ្ជីទទួលស្គាល់ឡើងវិញមកក្រសួងបរិស្ថាន។



ក

ក្នុងករណីដែលវិញ្ញាបនបត្រទទួលស្គាល់ឡើងវិញមិនត្រូវបានផ្តល់ជូន ក្រុមហ៊ុនទីប្រឹក្សាក្នុងកថាខណ្ឌខាងលើ មានរយៈពេល១២ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃប្រកាសនេះ ដើម្បីបញ្ចប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលនៅសេសសល់។

**ប្រការ ១៩**.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០**.-

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង អគ្គាធិការ នាយកខុទ្ទកាល័យរដ្ឋមន្ត្រី ប្រធានក្រុមការងារបច្ចេកទេសពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធាននាយកដ្ឋាន និងប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ